**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Économiques**
**Royal University of law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន នៅសាលាដំបូងរាជធានីភ្នំពេញ

ស្រាវជ្រាវពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២១ ដល់ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០២១

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **សោម រតនា**

សាស្ត្រាចារ្យណែនាំ
លោក **ហេង ប៊ូរ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **សោម រតនា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** ជំនាន់ទី ២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០២១-២០២២។

**សូមគោរពលំឱនកាយវាចាចិត្តសម្តែងនូវកតញ្ញូតាធម៌**

**យ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះ ៖**

**លោកឪពុក សោម ចឿង និង អ្នកម្តាយ រិន សល**

ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាអប់រំទូន្មាន ព្រមទាំងជួយទំនុកបម្រុងដល់រូបកូនទាំងស្មារតី និងសម្ភារៈគ្រប់បែបយ៉ាង។ ម្យ៉ាងវិញទៀត លោកអ្នកមានគុណទាំងទ្វេបានផ្តល់នូវដំបូន្មានល្អៗ ជាច្រើនដល់រូបកូន ចាប់តាំពីពេលដែលកូនកើតមករហូតដល់ធំពេញវ័យ នឹងបានបញ្ជូនរូបកូនទៅសាលាដើម្បីទទួលបានការសិក្សាបណ្តុះបណ្តាលតាំងពីថ្នាក់បឋមរហូតដល់ថ្នាក់ឧត្តមសិក្សា។ លោកអ្នកមានគុណទាំងពីរ គឺបានខិតខំព្យាយាមប្រឹងប្រែងអស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ដើម្បីជួយឧបត្ថម្ភដល់រូបកូនឱ្យបានសិក្សារៀនសូត្របានខ្ពង់ខ្ពស់ ទទួលបានអនាគតភ្លឺស្វាង នឹងក្លាយជាមនុស្សម្នាក់ដែលមានប្រយោជន៍ដល់សង្គមជាតិ។

ឯកឧត្តម **លុយ ចណ្ណា** សាកលវិទ្យាធិការ ព្រមទាំងសាកលវិទ្យាធិការរង ជាមួយនឹងព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយបង្ហាត់បង្រៀនដល់រូបខ្ញុំ តាំងពីឆ្នាំសិក្សាថ្នាក់មូលដ្ឋានរហូតបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ ប្រកបដោយក្រមវិជ្ជាជីវៈ។

លោកសាស្ត្រាចារ្យ **ហេង បូរ៉ា** ដែលលោកបានដឹកនាំបង្ហាញនូវគំនិត និងវិធីសាស្ត្រល្អៗទាក់ទងនឹងប្រធានបទសារណា រួមទាំងបានចំណាយពេលវេលាដ៏មានតម្លៃរបស់លោក តាំងពីដើមរហូតដល់បញ្ចប់ការស្រាវជ្រាវមួយនេះ។ ស្នាដៃដែលកើតចេញពីការស្រាវជ្រាវមួយនេះ ពិបាកនឹងទទួលបានការជោគជ័យ ប្រសិនបើគ្មានការជួយជ្រោមជ្រែងអំពីរូបលោក។

លោក **កួយ សៅ** អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ ដែលលោកបានអនុញ្ញាតឱ្យខ្ញុំបាទបានចូលជួបពិភាក្សា និងចំណាយពេលដ៏មានតម្លៃក្នុងការជួយផ្តល់គំនិតយោបល់ ក៏ដូចជាឯកសារនានាសម្រាប់ជាប្រយោជន៍ដល់រូបខ្ញុំ ដើម្បីឱ្យសារណាមួយនេះកាន់តែមានភាពល្អប្រសើរឡើង។

ជាទីបញ្ចប់ ខ្ញុំបាទគ្មានអ្វីតបស្នងនូវគុណូបការៈគុណដ៏ធំធេងរបស់អស់លោកអ្នកមានគុណទាំងអស់នោះទេ មានតែលើកដៃទាំងទ្វេបួងសួងដល់គុណបុណ្យព្រះរតនត្រៃទាំងបី ជួយបីបាច់ថែរក្សាលោកអ្នកមានគុណទាំងពួង ឱ្យជួបប្រទះនូវតែសេចក្តីសុខសេចក្តីចម្រើន ព្រមទាំងប្រកបនូវពុទ្ធពរទាំងឡាយបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពេលពីបានធ្វើការសិក្សា ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ អស់រយៈពេល ៤ ឆ្នាំកន្លងមក នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដោយកិច្ចខិតខំប្រឹងប្រែងក្នុងការសិក្សារៀនសូត្រពីសំណាក់លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យនៃសាកលវិទ្យាល័យ ក្នុងគោលបំណងដើម្បីទទួលបានចំណេះដឹង ខ្ញុំបាទត្រូវបានលើកទឹកចិត្ត នឹងត្រូវទទួលបានការអនុញ្ញាតពីសាកលវិទ្យាធិការដើម្បីសរសេរសារណាបញ្ចប់ការសិក្សាក្រោមប្រធានបទ «**ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជននៅសាលាដំបូងរាជធានីភ្នំពេញ**»។

ប្រធានបទមួយនេះ គឺកើតចេញពីភាពចម្ងល់ និងការចង់ដឹងឱ្យកាន់តែច្បាស់ស៊ីជម្រៅរបស់ខ្ញុំ ទៅលើកិច្ចទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់អនីតិជន នៅពេលដែលខ្លួនបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ។ ការស្រាវជ្រាវប្រធានបទមួយនេះ គឺផ្តោតសំខាន់ទៅលើសិទ្ធិ និងករណីយកិច្ចរបស់អនីតិជនក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ជាមួយនឹងនីតិវិធីដែលអនុវត្តទៅលើអនីតិជន ដែលធ្វើយ៉ាងណាត្រូវតែធានាដល់ឧត្តមប្រយោជន៍របស់អនីតិជន ព្រមទាំងបញ្ហាប្រឈម និងដំណោះស្រាយមួយចំនួនចំពោះអនីតិជននៅពេលដែលពួកគេបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។ លើសពីនេះទៅទៀត សារណាមួយនេះដែលអាចលេចចេញជារូបរាង និងទទួលបានជោគជ័យ ដោយសារតែមានការជួយជ្រោមជ្រែងណែនាំពីសំណាក់លោកគ្រូសាស្ត្រាចារ្យ **ហេង បូរ៉ា** ដែលលោកគ្រូបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការចែករំលែកនូវចំណេះដឹង ក៏ដូចជាបទពិសោធន៍ និងគោលគំនិតល្អៗសម្រាប់រូបខ្ញុំបាទ។

ហើយម្យ៉ាងវិញទៀត ថ្វីត្បិតតែសារណាមួយនេះ ខ្ញុំបាទបានពិនិត្យផ្ទៀងផ្ទាត់រួចជាស្រេចហើយក្តី ក៏គង់តែមានភាពខុសឆ្គងអាចកើតឡើងជាពុំខាន។ ដូច្នេះហើយ ខ្ញុំបាទសូមធ្វើការអធ្យាស្រ័យនូវរាល់កំហុសខុសឆ្គងទាំងឡាយដែលកើតឡើងដោយភាពអចេតនា នៅក្នុងកិច្ចការស្រាវជ្រាវមួយនេះ ហើយក៏រង់ចាំទទួលនូវការកែលម្អពីសំណាក់អស់លោក-លោកស្រី ក្នុងន័យដើម្បីស្ថាបនា ដើម្បីធ្វើយ៉ាងណាឱ្យស្នាដៃមួយនេះកាន់តែមានភាពល្អប្រសើរឡើងថែមទៀត។

ជាទីបញ្ចប់ ក្នុងនាមខ្ញុំបាទជាអ្នករៀបរៀងសារណាមួយនេះ ក៏សង្ឃឹមថាឯកសារមួយនេះអាចនឹងក្លាយទៅជាប្រយោជន៍ ក៏ដូចជាផ្តល់ចំណេះដឹងបន្ថែមទៀតសម្រាប់ជាគន្លឹះ និងជាការជំនួយស្មារតីដល់ប្អូនៗជំនាន់ក្រោយផ្សេងទៀតអាចធ្វើការស្រាវជ្រាវបន្តទៀតបាន។ ហើយម្យ៉ាងវិញទៀត ខ្ញុំបាទក៏សូមជូនពរដល់អស់លោក-លោកស្រីដែលកំពុងតែអានសៀវភៅមួយនេះ ជួបប្រទះនូវតែសេចក្តីសុខ សេចក្តីចម្រើន ជាពិសេសប្រកបនូវពុទ្ធពរទាំងឡាយបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លាតក្លាយទៅជាបការៈដទៃឡើយ។

# មាតិកា

ទំព័រ

## សេចក្តីផ្តើម


១ ពុហ្វហេតុនៃការស្រាវជ្រាវ .......... ១

២ ចំណោទបញ្ហានៃការស្រាវជ្រាវ .......... ២

៣ គោលបំណងនៃការសិក្សាស្រាវជ្រាវ .......... ២

៤ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ .......... ២

៥ សារៈសំខាន់នៃការស្រាវជ្រាវ .......... ៣

៦ វិធីសាស្រ្តនៃការសិក្សាស្រាវជ្រាវ .......... ៣

៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ .......... ៣


## ជំពូកទី១

## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

## និងនីតិវិធីនៃការអនុវត្តនៅសាលាដំបូង


១.១ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន .......... ៥

១.១.១ អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ .......... ៦

១.១.២ អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ .......... ៧

១.២ នីតិវិធីនៃការអនុវត្តនៅសាលាដំបូង .......... ៨

១.២.១ នីតិវិធីនៃការស៊ើបអង្កេត និងចំណាត់ការសំណុំរឿង .......... ៩

១.២.១.១ ការស៊ើបអង្កេតរបស់មន្រ្តីនគរបាលយុត្តិធម៌ .......... ៩

១.២.១.២ ចំណាត់ការសំណុំរឿងដោយអយ្យការ .......... ១២

១.២.២ នីតិវិធីនៃការស៊ើបសួរ និងការជំនុំជម្រះ .......... ១៣

១.២.២.១ ការស៊ើបសួរធ្វើឡើងដោយចៅក្រមស៊ើបសួរ .......... ១៤

១.២.២.២ ការជំនុំជម្រះ .......... ១៦


## ជំពូកទី២

## ការអនុវត្តទោស


២.១ ការអនុវត្តទោសដាក់ពន្ធនាគារ .......... ១៦

២.១.១ ការឃុំឃាំងអនីតិជនក្នុងពន្ធនាគារ .......... ១៧

២.១.២ ការត្រួតពិនិត្យការអនុវត្តទោសក្នុងពន្ធនាគារ ........ ១៩
២.២ ការអនុវត្តទោសពិន័យចំពោះអនីតិជន ........ ២០
២.២.១ ការដាសតឿនឱ្យបង់ប្រាក់ពិន័យ ........ ២០
២.២.២. ការរួចខ្លួនពីការបង្ខំដល់រូបកាយ ........ ២១

## ជំពូកទី៣

## បញ្ហាប្រឈម និងដំណោះស្រាយ

៣.១. បញ្ហាប្រឈម ........ ២៣
៣.១.១ ការអនុវត្តទោសលើអនីតិជនច្រើនពេក ........ ២៥
៣.១.២ ការឃុំខ្លួនបណ្តោះអាសន្នអនីតិជនលើសច្បាប់កំណត់ ........ ២៧
៣.២. ដំណោះស្រាយ ........ ៣០
៣.២.១ ការអនុវត្តទោសលើអនីតិជនគឺត្រូវធ្វើឡើងតាមលក្ខខណ្ឌច្បាប់ ........ ៣២
៣.២.២ ការឃុំខ្លួនបណ្តោះអាសន្នអនីតិជនត្រូវតែធ្វើឡើងតាមការកំណត់នៃច្បាប់ ........ ៣៥
**សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ........ ៣៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.ពុម្ពហេតុនៃការស្រាវជ្រាវ

ជាគោលការណ៍ទូទៅ នៅក្នុងនីតិព្រហ្មទណ្ឌនៅពេលដែលមានបទល្មើសណាមួយបានកើតឡើង ត្រូវតែមាននូវបុគ្គលណាម្នាក់ទទួលខុសត្រូវចំពោះបទល្មើសនោះ។ ដូច្នេះព្រហ្មទណ្ឌ គឺជានីតិវិធីទាំងឡាយដែលចែងមកសម្រាប់ដាក់ទោសរាល់បុគ្គលទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយពីនីតិវិធីព្រហ្មទណ្ឌ។ បុគ្គលដែលប្រព្រឹត្តបទល្មើសអាចជា រូបវន្តបុគ្គល ឬនីតិបុគ្គល។ ហើយរូបវន្តបុគ្គល មានការបែងចែកជាពីរទៀតគឺ នីតិជន និងអនីតិជន។ នីតិជន សំដៅទៅលើជនដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ។ ចំណែកឯ អនីតិជន វិញគឺសំដៅទៅលើជនដែលមានអាយុតិចជាង ១៨ ឆ្នាំ។ បានជាដូច្នោះហើយ នៅពេលមានបទល្មើសមួយកើតឡើងត្រូវតែមានការទទួលខុសត្រូវព្រហ្មទណ្ឌ។ បុគ្គលម្នាក់ៗ ទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់របស់ខ្លួនប៉ុណ្ណោះ។ នេះគឺជាគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលបានបញ្ញត្តិនៅមាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ។

យោងតាមអនុសញ្ញាស្តីពីសិទ្ធិកុមារត្រង់បញ្ញត្តិនៃមាត្រា ៤០ បានតម្រូវឱ្យរដ្ឋភាគីដែលក្នុងនោះក៏មានព្រះរាជាណាចក្រកម្ពុជាផងដែរ ត្រូវធ្វើការកំណត់កម្រិតអាយុអប្បបរមានៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់កុមារ។ មានន័យថា កុមារដែលមានអាយុក្រោមអប្បបរមានេះត្រូវបានសន្មតជាមុនថា ពុំមានសមត្ថភាពនឹងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌឡើយ។ សមត្ថភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺជាលទ្ធភាពរបស់មនុស្សនៅពេលដែលបានប្រព្រឹត្តអំពើគ្រោះថ្នាក់ដល់សង្គម ហើយជននោះអាចយល់ដឹងអំពីចរិតគ្រោះថ្នាក់នៃអំពើរបស់ខ្លួន នឹងអាចបញ្ជានូវរាល់អំពើទាំងនោះបាន។ មនុស្សម្នាក់ត្រូវបានចាត់ទុកថាមានសមត្ថភាពទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ប្រសិនបើពេលប្រព្រឹត្តអំពើគ្រោះថ្នាក់ដល់សង្គម ហើយជននោះបានឈានដល់កម្រិតអាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។ ការកំណត់អំពីកម្រិតអាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌនេះ នឹងបង្កើតបានទៅជាមូលដ្ឋានផ្នែកគតិយុត្តមួយ សម្រាប់កំណត់អំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់អនីតិជនផ្ទាល់តែម្តង។ ហើយម្យ៉ាងវិញទៀត ការកម្រិតអាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ក៏មានការប្រែប្រួលទៅតាមប្រទេសផ្សេងៗគ្នា ស្របតាមគោលនយោបាយព្រហ្មទណ្ឌ ការរីកចម្រើនផ្នែករាងកាយ និងប្រាជ្ញាស្មារតីរបស់អនីតិជននោះផងដែរ។

ហើយម្យ៉ាងវិញទៀត បើយើងពិនិត្យមើលទៅលើក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាត្រង់បញ្ញត្តិនៃមាត្រា ៣៨ បានកំណត់ពីនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ បានសេចក្តីថានីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌគឺចាប់ពីអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ។ មានន័យថាអនីតិជន ដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ តុលាការអាចប្រកាស

ទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅបានផងដែរ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ជាគោលការណ៍ គេមិនអាចឱ្យជនដែលមិនដឹងខុសត្រូវពីភាពធ្ងន់ធ្ងរនៃអំពើរបស់ខ្លួនឱ្យទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។ ការយល់ដឹងខុសត្រូវ គឺជាកត្តាមួយដែលនាំឱ្យបុគ្គលម្នាក់ៗ ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។ ចុះកាលបើអនីតិជនបានប្រព្រឹត្តបទល្មើស តើអនីតិជននោះ អាចទទួលខុសត្រូវព្រហ្មទណ្ឌដែរឬទេ? នៅពេលដែលអនីតិជនប្រព្រឹត្តបទល្មើស គេអនុវត្តទោសចំពោះអនីតិជនយ៉ាងដូចម្តេចទៅ? ហើយការអនុវត្តទោសរបស់អនីតិជនមានបញ្ហាប្រឈម និងដំណោះស្រាយយ៉ាងដូចម្តេចខ្លះ?

ដោយសារតែមាននូវចំណោទបញ្ហាគតិយុត្តទាំងអស់នេះហើយ ទើបខ្ញុំបានសម្រេចចិត្តសរសេរសារណាបញ្ចប់ការសិក្សាលើប្រធានបទស្តីពី «**ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជននៅសាលាដំបូងរាជធានីភ្នំពេញ**» ក្នុងគោលបំណងដើម្បីស្រាយនូវរាល់ចម្ងល់ទាំងឡាយដែលបានចោទសួរខាងលើនេះ។

"**ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជននៅសាលាដំបូងរាជធានីភ្នំពេញ**" គឺសំដៅដល់ការទទួលរងនូវទណ្ឌកម្មព្រហ្មទណ្ឌរបស់អនីតិជន ចំពោះបទល្មើសព្រហ្មទណ្ឌដែលខ្លួនបានប្រព្រឹត្ត។ ពាក្យថា ទណ្ឌកម្មព្រហ្មទណ្ឌ ក្នុងន័យនេះ គឺសំដៅដល់ការប្រកាសផ្តន្ទាទោសដែលធ្វើឡើងដោយស្ថាប័នតុលាការផ្ទាល់តែម្តង។ ចំណែកពាក្យថា សាលាដំបូងរាជធានីភ្នំពេញវិញ គឺសំដៅដល់ស្ថាប័នតុលាការជាន់ទាប ឬជាន់ដំបូង ដែលមានសមត្ថកិច្ចជំនុំជម្រះរឿងក្តីគ្រប់ប្រភេទ ក្នុងដែនដីរបស់ខ្លួន (លើកលែងតែបទល្មើសយោធា)។ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជននៅសាលាដំបូងរាជធានីភ្នំពេញ មានន័យថា គឺជាគោលការណ៍មួយដែលបានធ្វើការកំណត់ ពាក់ព័ន្ធអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់អនីតិជន នៅសាលាដំបូងរាជធានីភ្នំពេញ ឬអាចនិយាយបានថាជាការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់អនីតិជននៅតុលាការជាន់ទាប។

## ៣.គោលបំណងនៃការសិក្សាស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវសារណានេះ គឺខ្ញុំធ្វើឡើងក្នុងគោលបំណងដើម្បីធ្វើការសិក្សាឈ្វេងយល់អំពីភាពមិនច្បាស់លាស់មួយចំនួន ក៏ដូចជាការចង់ស្រាយបំភ្លឺអំពីចំណោទបញ្ហាគតិយុត្តដែលបានលើកឡើងពីខាងដើម។ លើសពីនេះតទៅទៀត គឺបំណងចង់ពង្រឹង និងពង្រីកនូវសមត្ថភាពផ្ទាល់ខ្លួនបន្ថែមទៀតដែលទាក់ទងនឹងវិស័យព្រហ្មទណ្ឌ។ ហើយម្យ៉ាងវិញទៀត ក៏ដូចជាការចូលរួមចំណែកក្នុងការអភិវឌ្ឍនូវវិស័យព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជាផងដែរ។

## ៤.ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ដើម្បីចងក្រងសរសេរសារណានេះឡើង ខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវនៅសាលាដំបូងរាជធានីភ្នំពេញ ដោយកិច្ចសម្ភាសជាមួយនឹងចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីតុលាការនៅសាលាដំបូងរាជធានីភ្នំពេញមួយចំនួន។ ក្រៅពីកិច្ចសម្ភាសនៅសាលាដំបូងរាជធានីភ្នំពេញ ខ្ញុំបាទក៏បានស្រាវជ្រាវតាមរយៈឯកសារមួយចំនួនដែលមានចែងនៅក្នុងច្បាប់របស់កម្ពុជាផងដែរ។ ហើយឯកសារទាំងនោះ អនុសញ្ញាស្តីពីសិទ្ធិកុមារ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៩ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦ ច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១ និងរួមទាំងឯកសារដែលពាក់ព័ន្ធមួយចំនួនផ្សេងទៀត ដូចដែលខ្ញុំបានលើកឡើងនៅក្នុងឯកសារពិគ្រោះស្រាប់។

នៅក្នុងកិច្ចការស្រាវជ្រាវនេះផងដែរ ខ្ញុំបាទផ្តោតសំខាន់តែទៅលើករណីដែលអនីតិជនបានប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ ហើយត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌបែបណាខ្លះ ជាមួយនឹងការអនុវត្តទោសរបស់អនីតិជននៅក្នុងពន្ធនាគារ និងចំណុចមួយទៀត គឺទាក់ទងទៅនឹងបញ្ហាប្រឈមមួយចំនួននៅពេលដែលពួកគេបានប្រព្រឹត្តល្មើសនឹងច្បាប់ព្រហ្មទណ្ឌ ព្រមទាំងទទួលបានដំណោះស្រាយបែបណាបែបណាខ្លះតាមផ្លូវច្បាប់។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃការសិក្សាស្រាវជ្រាវនេះ នឹងអាចក្លាយទៅជាប្រយោជន៍ ក៏ដូចជាដើមទុនមួយសម្រាប់ប្អូនៗនិស្សិតជំនាន់ក្រោយ ឬជាឯកសារជំនួយស្មារតីមួយ ដែលប្អូនៗនិស្សិតច្បាប់អាចយកទៅធ្វើការសិក្សាឈ្វេងយល់ ដើម្បីជាការផ្តល់នូវចំណេះដឹងបន្ថែមដែលទាក់ទងផ្នែកនីតិព្រហ្មទណ្ឌ ក៏ដូចជាការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់អនីតិជននៅក្នុងដំណាក់កាលនៃតុលាការជាន់ទាបផងដែរ។

## ៦.វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

សារណានេះ ខ្ញុំបានរៀបរៀង និងចងក្រងឡើង ដោយបានប្រើសប្រាស់នូវវិធីសាស្ត្របែបពិពណ៌នា និងវិភាគ។ ហើយខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវ ដោយធ្វើការប្រមូលនូវទិន្នន័យ និងព័ត៌មានទាំងឡាយ ក៏ដូចជាឯកសារដែលពាក់ព័ន្ធទៅនឹងប្រធានបទនៃសារណានេះ ដើម្បីធ្វើឱ្យសារណាមួយនេះកាន់តែមានភាពត្រឹមត្រូវ និងច្បាស់លាស់បន្ថែមទៀត។ ព័ត៌មានទាំងឡាយត្រូវបានជ្រើសរើស និងដកស្រង់ចេញពីប្រភពដូចជា ការបកស្រាយរបស់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី មន្ត្រីតុលាការនៅសាលាដំបូងរាជធានីភ្នំពេញ អ្នកមានបទពិសោធន៍នៅក្នុងវិស័យព្រហ្មទណ្ឌ មតិយោបល់ពីអ្នកជំនាញខាងច្បាប់ព្រហ្មទណ្ឌ ព្រមទាំងច្បាប់សំខាន់របស់ព្រះរាជាណាចក្រកម្ពុជា និងឯកសារដែលពាក់ព័ន្ធមួយចំនួនផ្សេងទៀត។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទសារណាមួយនេះ ត្រូវបានធ្វើការបែងចែកជា ៣ ជំពូកធំៗ គឺរួមមាន ៖

**ជំពូកទី ១ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន និងនីតិវិធីនៃការអនុវត្តនៅសាលាដំបូង**

**ជំពូកទី ២ ការអនុវត្តទោស**

**ជំពូកទី ៣ បញ្ហាប្រឈម និងដំណោះស្រាយ**

# ជំពូកទី១

# ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន និងនីតិវិធីនៃការអនុវត្តនៅសាលាដំបូង

# ជំពូកទី១
# ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន និងនីតិវិធីនៃការអនុវត្តនៅសាលាដំបូង

នៅក្នុងនីតិព្រហ្មទណ្ឌជាគោលការណ៍ទូទៅ នៅពេលដែលមានបទល្មើសណាមួយកើតឡើង ទោះអំពើនោះប្រព្រឹត្តឡើងដោយចេតនាក្តី ឬដោយអចេតនាក្តី ដែលជាហេតុបណ្តាលឱ្យមានព្យសនកម្មដល់បុគ្គលដទៃ គឺជាលក្ខខណ្ឌចម្បងនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។ ដូច្នេះ នីតិព្រហ្មទណ្ឌ គឺជាបាទដ្ឋានគតិយុត្តចែងកំណត់អំពីការដាក់ទណ្ឌកម្ម ចំពោះបុគ្គលដែលបានប្រព្រឹត្តអំពើដែលប៉ះពាល់ដល់ប្រយោជន៍បុគ្គល ឬសាធារណៈ និងសណ្តាប់ធ្នាប់សង្គម។ ហេតុនេះ បានជាក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាកម្រិតអំពីការទទួលខុសត្រូវព្រហ្មទណ្ឌយ៉ាងច្បាស់លាស់ ដែលក្នុងនោះមាត្រា ៣៨ បានចែងថានីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ[1]។

ហើយម្យ៉ាងវិញទៀត នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមាត្រា ៣៨ បានកំណត់ថាការទទួលខុសត្រូវព្រហ្មទណ្ឌបាន លុះត្រាតែមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ដោយហេតុថា អាយុក្រោម ១៨ ឆ្នាំគឺជាអនីតិជន ដូចនេះការយល់ដឹងរបស់ពួកគេនៅមានភាពខ្វះខាតនៅឡើយ។ ក៏ប៉ុន្តែនៅក្នុងមាត្រា ៣៩ បានបញ្ញត្តិបន្ថែមថា តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅបាន ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។

ហើយចំពោះនីតិវិធីដែលត្រូវលើកយកមកអនុវត្តចំពោះអនីតិជន ក៏មានលក្ខណៈដូចគ្នាទៅនឹងនីតិវិធីអនុវត្តចំពោះនីតិជនផងដែរ។ ដោយហេតុថា នីតិវិធីនេះតម្រូវឱ្យមានការឆ្លងកាត់ពីសំណាក់ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ចំណាត់ការសំណុំរឿងដោយស្ថាប័នអយ្យការ។

## ១.១ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

ជាគោលការណ៍ គេមិនអាចឱ្យជនដែលមិនដឹងខុសត្រូវពីភាពធ្ងន់ធ្ងរនៃអំពើរបស់ខ្លួនឱ្យទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។ ការយល់ដឹងខុសត្រូវគឺជាកត្តាមួយដែលនាំឱ្យបុគ្គលម្នាក់ៗ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។ កាលបើអនីតិជនដែលមានអាយុមិនដល់ ១០ ឆ្នាំផងបានសម្លាប់មនុស្ស តើអនីតិជននោះ អាចទទួលខុសត្រូវព្រហ្មទណ្ឌដែរ ឬទេ? ជាគោលការណ៍អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ដោយឡែកអនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំឡើង មិនអាចអះអាងថាខ្លួនមិនដឹងអ្វីនោះទេ។ ដោយអនុលោមតាមមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ បានកំណត់នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌនៅអាយុ ១៨

[1] ក្រមព្រហ្មទណ្ឌ, មាត្រា ៣៨ ឆ្នាំ២០០៩

ឆ្នាំ មានន័យថា អនីតិជនដែលមានអាយុក្រោម ១៨ ឆ្នាំមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ[2]។ ថ្វីត្បិតតែអនីតិជនមិនទទួលខុសត្រូវព្រហ្មទណ្ឌ ក៏ប៉ុន្តែក្រមព្រហ្មទណ្ឌតម្រូវឱ្យមានវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ សម្រាប់អនីតិជនដែលបានប្រព្រឹត្តបទល្មើស។ មិនតែប៉ុណ្ណោះ បើកាលៈទេសៈនៃការប្រព្រឹត្តបទល្មើស និងបុគ្គលិកលក្ខណៈនៃការប្រព្រឹត្តបទល្មើសរបស់អនីតិជនតម្រូវ ក្រមព្រហ្មទណ្ឌតម្រូវឱ្យតុលាការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ ឆ្នាំឡើងទៅបាន ដោយអនីតិជននោះត្រូវតែទទួលរងនូវការផ្តន្ទាទោសដោយឡែក។

### ១.១.១ អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ

អនីតិជនប្រភេទនេះ នៅពេលដែលប្រព្រឹត្តបទល្មើសគឺច្បាប់បានកំណត់ថា មិនអាចទទួលរងនូវការផ្តន្ទាទោសណាមួយឡើយ ទោះបីជាអនីតិជននោះបានប្រព្រឹត្តបទល្មើសប្រភេទណាក៏ដោយ។ ម្យ៉ាងវិញទៀត អនុសញ្ញាស្តីពីសិទ្ធិកុមារមាត្រា ៤០ ត្រង់ចំណុចទី ៣ កថាខណ្ឌ "ក" បានកំណត់ថា រដ្ឋភាគីទាំងអស់នៃអនុសញ្ញានេះ ដែលក្នុងនោះក៏មានព្រះរាជាណាចក្រកម្ពុជាផងដែរ ត្រូវតែធ្វើការកំណត់កម្រិតអាយុអប្បបរមានៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់កុមារដែលក្រោមអាយុអប្បបរមានេះ កុមារត្រូវបានសន្មតជាមុនថា ពុំមានសមត្ថភាពនឹងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌឡើយ[3]។ ចំណែកមាត្រា ១៤ កថាខណ្ឌទី ១ នៃច្បាប់ស្តីពីយុត្តិធម៌-អនីតិជន ប្រកាសឱ្យប្រើនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ បានចែងថា អនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើសពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់អនីតិជននោះទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់។ រីឯមាត្រា ២៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនកថាខណ្ឌទី១ ក៏បានចែងផងដែរថា ក្នុងករណីអនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំគិតមកត្រឹមថ្ងៃដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស នោះព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងត្រូវប្រគល់អនីតិជនទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់វិញភ្លាម។ ទន្ទឹមជាមួយគ្នានេះផងដែរ ក៏មានបញ្ញត្តិនៃមាត្រា ៣៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ត្រង់កថាខណ្ឌទី១ វាក្យខណ្ឌទី១ បានកំណត់ផងដែរថា អនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនត្រូវបានឃុំខ្លួនបណ្តោះអាសន្នឡើយ។

តាមខ្លឹមសារដែលបកស្រាយមកពីខាងលើនេះ យើងអាចសន្និដ្ឋានបានថា អាយុ ១៤ ឆ្នាំគឺជាកម្រិតអាយុអប្បបរមានៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ឬអនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំពុំអាចទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនោះទេ។

[2] នីតិព្រហ្មទណ្ឌទូទៅ, សាស្ត្រាចារ្យ មីន សំអុល, ទំព័រ ៣៣

[3] អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ៤០ ចំណុចទី ៣ កថាខណ្ឌ "ក"

**ឧទាហរណ៍** ៖ ក្មេងប្រុសម្នាក់អាយុ ៩ ឆ្នាំបានលេងចោលដុំថ្មដោយមិនប្រយ័ត្ន បណ្តាលឱ្យត្រូវក្បាលក្មេងប្រុសម្នាក់ទៀតរងរបួសបែកក្បាល។ ក្នុងករណីនេះ យើងអាចសន្និដ្ឋានបានថា ក្មេងប្រុសដែលបានប្រព្រឹត្តអំពើល្មើសនោះ មិនអាចត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌបានឡើយ ដោយហេតុថាក្មេងនោះនៅមិនទាន់មានការយល់ដឹងខុសត្រូវចំពោះអំពើរបស់ខ្លួននៅឡើយ។

គួរកត់សម្គាល់ថា អាយុក្រោម ១៤ ឆ្នាំ សច្ចធារណ៍មិនអាចប្រកែកបាននៃការមិនទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដែលរារាំងមិនឱ្យតុលាការធ្វើការប្រកាសទោសទៅលើអនីតិជននោះឡើយ។ ប៉ុន្តែ មិនមែនមានន័យថា បានរារាំងចំពោះការចូលខ្លួនមកកាន់តុលាការ និងការប្រកាសសេចក្តីសម្រេចនោះទេ។ ដូច្នេះ តុលាការក៏នៅតែអាចធ្វើការកោះហៅអនីតិជននោះឱ្យចូលមកកាន់តុលាការបានផងដែរ ក្នុងគោលបំណងដើម្បីប្រកាសសេចក្តីសម្រេចដាក់ឱ្យអនុវត្តនូវវិធានការណាមួយដែលតុលាការបានធ្វើការសម្រេចលើអនីតិជននោះ។ វិធានការនោះរួមមាន វិធានការអប់រំ វិធានការតាមដាន វិធានការការពារ និងវិធានការឧបត្ថម្ភ ឬក៏ប្រគល់អនីតិជននោះឱ្យទៅសាច់ញាតិ សេវាសាធារណៈ អង្គការឯកជនដែលមាននីតិសម្បទា មន្ទីរពេទ្យ ឬស្ថាប័នឯកទេស និងអាចដាក់អនីតិជននោះឱ្យស្ថិតក្រោមការការពាររបស់តុលាការបានផងដែរ[4]។

### ១.១.២ អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ

ចំពោះអនីតិជនប្រភេទនេះវិញ នៅពេលដែលជននោះបានប្រព្រឹត្តបទល្មើស គឺត្រូវទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្តនោះ។ ហេតុដែលច្បាប់តម្រូវឱ្យជននោះមានការទទួលខុសត្រូវ ដោយយល់ឃើញថាអនីតិជនប្រភេទនេះ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌហើយ។ សមត្ថភាពទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ គឺជាលទ្ធភាពរបស់មនុស្សនៅពេលដែលប្រព្រឹត្តអំពើបង្កគ្រោះថ្នាក់ដល់សង្គម ហើយជននោះអាចយល់ដឹងអំពីចរិតគ្រោះថ្នាក់នៃអំពើរបស់ខ្លួន នឹងអាចបញ្ជានូវរាល់អំពើទាំងនោះបាន។ ការយល់ឃើញបែបនេះ អាស្រ័យដោយហេតុថា នីតិករបានពិចារណាដោយផ្អែកទៅលើការរីកចម្រើនអំពីរូបរាងកាយ ប្រាជ្ញា ស្មារតី និងការសន្សំនូវរាល់បទពិសោធន៍នៃជីវិតក្នុងជីវភាពរស់នៅកន្លងមករបស់អនីតិជននោះ។ កត្តាទាំងអស់នេះហើយ ដែលជាហេតុនាំឱ្យច្បាប់សន្មតបានថា អនីតិជនប្រភេទនេះអាចពិចារណាយល់ដឹងបានគ្រប់គ្រាន់នូវបណ្តាការទាមទារ និងរបបកំណត់របស់សង្គម ព្រមទាំងអាចបញ្ជាបាននូវរាល់អំពើរបស់ខ្លួនថែមទៀតផង។ ថ្វីត្បិតតែច្បាប់បានតម្រូវឱ្យអនីតិជនមានការទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្តក៏ពិតមែន ប៉ុន្តែការទទួលខុសត្រូវនេះ មិនមានលក្ខណៈពេញដូចនីតិជនឡើយ ពោលគឺស្ថានភាពដែលជននោះត្រូវទទួលរងគឺមានកម្រិតស្រាលជាងនីតិជន។ ហើយដើម្បីអាចសម្រេចផ្តន្ទាទោសលើអនីតិជនបាន តុលាការត្រូវពិនិត្យ

[4] ក្រមព្រហ្មទណ្ឌ, មាត្រា ៤០ ឆ្នាំ២០០៩

ពិចារណាថ្លឹងថ្លែងជាមុន ពាក់ព័ន្ធទៅនឹងកាលៈទេសៈនៃបទល្មើសដែលអនីតិជននោះបានប្រព្រឹត្ត និងរួមទាំងបុគ្គលិកលក្ខណៈរបស់គាត់ផងដែរ[5]។

សូមបញ្ជាក់ផងដែរថា បើទោះបីជាអនីតិជនអាចទទួលរងនូវទោសបែបនេះក៏ដោយ ក៏កម្រិតនៃទោសដែលទទួលរងគឺត្រូវបន្ថយមកត្រឹមពាក់កណ្ដាល បើប្រៀបធៀបទៅនឹងទោសដែលមានចែងចំពោះនីតិជន។ ជារួមគេអាចសន្និដ្ឋានបានថា ការបន្ថយទោសចំពោះអនីតិជនអាចបណ្ដាលមកពីមូលហេតុ ***អនីតិភាពនៃទណ្ឌិត*** នេះឯង។

**ឧទាហរណ៍** ៖ ក្នុងករណីបទឃាតកម្ម ធម្មតាត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១០ ឆ្នាំ ទៅ ១៥ ឆ្នាំ។ ក៏ប៉ុន្តែ ចំពោះជនល្មើសដែលជាអនីតិជនមានអាយុចន្លោះពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ទោសគឺត្រូវកាត់បន្ថយមកពាក់កណ្ដាលពោលគឺមកត្រឹមពី ៥ ឆ្នាំ ទៅ ៧ ឆ្នាំ កន្លះវិញ។ ក្នុងករណីបទល្មើសដែលត្រូវជាប់ពន្ធនាគារអស់មួយជីវិត គឺត្រូវបន្ថយមកនៅត្រឹម ២០ ឆ្នាំ វិញ។ ចំពោះទោសពិន័យជាប្រាក់ក៏ត្រូវកាត់បន្ថយពាក់កណ្ដាលដូចគ្នាផងដែរ។ ដូច្នេះ យើងអាចសន្មតបានថា ទោសដែលត្រូវអនុវត្តចំពោះអនីតិជននោះ គឺត្រូវបន្ថយមកត្រឹមពាក់កណ្ដាលតែប៉ុណ្ណោះ បើប្រៀបធៀបទៅនឹងទោសដែលអនុវត្តចំពោះនីតិជន។

### ១.២ នីតិវិធីនៃការអនុវត្តនៅសាលាដំបូង

នៅក្នុងប្រទេសកម្ពុជាប្រព័ន្ធតុលាការមានការផ្លាស់ប្ដូរជាច្រើនសម័យកាល គឺចាប់តាំងពី ឆ្នាំ ១៩៧៩ រហូតដល់ ឆ្នាំ ១៩៨៥ នៅកម្ពុជាមានតុលាការតែមួយថ្នាក់ប៉ុណ្ណោះ គឺតុលាការខេត្ត-ក្រុងដែលដើរតួនាទីជាតុលាការដំបូងក្នុងការកាត់ក្ដី ឬជំនុំជម្រះក្ដីលើកទីមួយ និងចុងក្រោយបង្អស់ មានន័យថាគ្រប់សាលក្រមទាំងអស់ដែលចេញដោយតុលាការនេះ មានប្រសិទ្ធភាពក្នុងការអនុវត្ត ហើយសាលក្រមទាំងនេះត្រូវមានការត្រួតពិនិត្យដោយក្រសួងយុត្តិធម៌ និងសម្រេចចុងក្រោយដោយក្រុមប្រឹក្សារដ្ឋ ប្រសិនបើមានការស្នើរបស់ក្រសួងយុត្តិធម៌ដោយរកឃើញថាមានកំហុស។ លុះមកដល់សម័យអ៊ុនតាក់ តុលាការនៅព្រះរាជាណាចក្រកម្ពុជាត្រូវបានបង្កើតឱ្យមានពីរថ្នាក់គឺ តុលាការជាន់ទាប ដែលមានតុលាការខេត្ត-ក្រុង និងតុលាការយោធា និងតុលាការជាន់ខ្ពស់ដែលមានសាលាឧទ្ធរណ៍ និងតុលាការកំពូល។ ប៉ុន្តែមកដល់ពេលបច្ចុប្បន្នយើងឃើញថា តុលាការនៅព្រះរាជាណាចក្រកម្ពុជាត្រូវបានបែងចែកជាបីថ្នាក់ គឺតុលាការថ្នាក់ទីមួយ (សាលាដំបូងរាជធានី-ខេត្ត) តុលាការថ្នាក់ទីពីរ (សាលាឧទ្ធរណ៍) និងតុលាការកំពូល។

នីតិវិធីដែលត្រូវលើកយកមកអនុវត្តចំពោះអនីតិជន ក៏មានលក្ខណៈដូចគ្នាទៅនឹងនីតិវិធីអនុវត្តចំពោះនីតិជនផងដែរ។ ដោយហេតុថា នីតិវិធីនេះតម្រូវឱ្យមានការឆ្លងកាត់ពីសំណាក់ការស៊ើបអង្កេតរបស់មន្ត្រីនគរ-

[5] នីតិព្រហ្មទណ្ឌទូទៅ, លោក កៅ សីហា ទំព័រ ២០៣

បាលយុត្តិធម៌ ចំណាត់ការសំណុំរឿងដោយស្ថាប័នអយ្យការ (ការចោទប្រកាន់) ការស៊ើបសួរធ្វើឡើងដោយចៅក្រមស៊ើបសួរ និងដំណាក់កាលនៃការជំនុំជម្រះធ្វើឡើងនៅក្នុងសាវនាការជាអាទិ៍។ ក៏ប៉ុន្តែ អ្វីដែលខុសគ្នានោះនៅត្រង់ថា អនីតិជនជាជនដែលមានសមត្ថភាពយល់ដឹងខាងអំពើនៅមានកម្រិតនៅឡើយ ។ ដូច្នោះ ត្រង់ចំណុចនេះទើបច្បាប់បានពិចារណាទៅលើកម្រិតនៃការយល់ដឹងរបស់ពួកគេ តម្រូវឱ្យមានការអនុវត្តនីតិវិធីយ៉ាងពិសេសមួយចំនួនចំពោះពួកគាត់។

### ១.២.១ នីតិវិធីនៃការស៊ើបអង្កេត និងចំណាត់ការសំណុំរឿង

ជាទូទៅ រឿងក្តីព្រហ្មទណ្ឌចាប់ផ្តើមឡើងដោយការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលអាចស្វែងរកឃើញថា អង្គហេតុមួយចំនួនត្រូវចាត់ទុកថាជាបទល្មើស។ ការស៊ើបអង្កេតគឺជាដំណាក់កាលត្រៀមនៃរឿងក្តីព្រហ្មទណ្ឌ ដែលប្រព្រឹត្តទៅមុនពេលការចាប់ផ្តើមចោទប្រកាន់ ក្នុងគោលបំណងស្វែងរកនូវភស្តុតាង[6]។ ក្រោយពីបានបញ្ចប់នូវការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនសំណុំរឿងទៅកាន់ស្ថាប័នអយ្យការដើម្បីមានចំណាត់ការបន្ត។ សំណុំរឿងនៃនីតិវិធី ដែលបានកសាងឡើងដោយការស៊ើបអង្កេតយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធភាព ព្រះរាជអាជ្ញាដែលមានតួនាទីបន្ទាប់ ត្រូវសម្រេចថានឹងមានចំណាត់ការយ៉ាងណាបន្តទៅទៀត ដោយយោងទៅលើភាពជាក់ស្តែង និងស្ថានភាពភស្តុតាងដែលប្រមូលបាន[7]។

#### ១.២.១.១ ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌ មានភារកិច្ចស៊ើបអង្កេតលើបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ដែលពាក់ព័ន្ធទៅនឹងជនសង្ស័យដែលជាអនីតិជន[8]។ រាល់ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌គឺត្រូវធ្វើឡើងក្រោមការដឹកនាំ និងសម្របសម្រួលសកម្មភាពពីព្រះរាជអាជ្ញា[9]។ នៅក្នុងដំណើរការស៊ើបអង្កេតនេះ មន្ត្រីនគរបាលយុត្តិធម៌មានតួនាទីកំណត់ពីប្រភេទនៃបទល្មើស អត្តសញ្ញាណប្រមូលភស្តុតាង ដែលពាក់ព័ន្ធដើម្បីឃាត់ខ្លួន ឬចាប់ខ្លួនជនល្មើសក្នុងករណីដែលជាចាំបាច់។ ដូច្នេះ ការស៊ើបអង្កេតនេះត្រូវបង្ហាញ និងប្រព្រឹត្តទៅតាមដំណាក់កាលនៃនីតិវិធីដូចខាងក្រោម ៖

**ការចាប់ខ្លួន**

បន្ទាប់ពីរកឃើញថា អនីតិជនបានប្រព្រឹត្តបទល្មើស ឬជនសង្ស័យថាបានប្រព្រឹត្តបទល្មើស មន្ត្រីនគរ-បាលយុត្តិធម៌ត្រូវធ្វើការឃាត់ខ្លួនអនីតិជននោះ និងរាយការណ៍ទៅព្រះរាជអាជ្ញាភ្លាម ដើម្បីអាចធ្វើការចាប់ខ្លួនអនីតិជនដែលជាប់សង្ស័យនោះ។

---

[6] មេរៀននីតិវិធីព្រហ្មទណ្ឌ, រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ឆ្នាំ២០០៨ ទំព័រ ៩

[7] មេរៀននីតិវិធីព្រហ្មទណ្ឌ, រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ឆ្នាំ២០០៨ ទំព័រ ២៩

[8] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ១២ ឆ្នាំ២០១៦

[9] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៥៨ ឆ្នាំ២០០៧

លក្ខណៈពិសេសនៃការចាប់ខ្លួន គឺមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការចាប់ខ្លួនបានចំពោះតែអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំដែលប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងតែប៉ុណ្ណោះ[10]។ ក្នុងការអនុវត្តការចាប់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជៀសវាងជាដាច់ខាត ក្នុងការធ្វើឱ្យអាម៉ាស់មុខ និងបាត់បង់សេចក្តីថ្លៃថ្នូរដល់អនីតិជន។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវប្រើប្រាស់កម្លាំងក្នុងកម្រិតស្រាលបំផុតដែលអាចធ្វើទៅបាន ដោយជៀសវាងការប្រើប្រាស់នូវឧបករណ៍មួយចំនួនដែលមានលក្ខណៈបង្ខំ ដូចជាខ្នោះដៃ អាវុធ កាំភ្លើង ឬឧបករណ៍ប្រហាក់ប្រហែល ហើយត្រូវបញ្ជូនអនីតិជនទៅឱ្យផ្នែក ឬអង្គភាពនគរបាលយុត្តិធម៌ជំនាញទាក់ទងទៅនឹងអនីតិជនដែលនៅជិតបំផុត។ មួយវិញទៀត មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរទៅលើបុគ្គលដែលជាអនីតិជនដែលមានភេទដូចគ្នាប៉ុណ្ណោះ ក្នុងករណីដែលគ្មានជម្រើស មន្ត្រីនគរបាលយុត្តិធម៌អាចអនុញ្ញាត នឹងធ្វើការចាត់តាំងនីតិជនដែលមានភេទដូចគ្នាណាម្នាក់ ឱ្យធ្វើការឆែកឆេរលើអនីតិជនដែលមានភេទដូចគ្នា តែត្រូវប្រាកដថា អ្នកដែលធ្វើការឆែកឆេរនោះមិនមានជាប់ពាក់ព័ន្ធនឹងបទល្មើស ពុំមានទំនាស់ ឬមិនជាប់សាច់ញាតិ ឬមានទំនាក់ទំនងជិតស្និតជាមួយអនីតិជននោះឡើយ (លើកលែងតែក្នុងករណីដែលមិនអាចជៀសវាងបាន)[11]។

បន្ទាប់ពីធ្វើការចាប់ខ្លួនអនីតិជនភ្លាម មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់នូវសិទ្ធិមួយចំនួនទៅកាន់អនីតិជនដូចជា[12] ៖

- សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី
- សិទ្ធិមិនទទួលការបង្ខិតបង្ខំឱ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង
- សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន
- សិទ្ធិទទួលបានបានការពិនិត្យសុខភាព និងការព្យាបាល
- សិទ្ធិទទួលបានការឱ្យដំណឹងអំពីបទចោទប្រកាន់
- សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់
- សិទ្ធិទទួលបានជំនួយពីមេធាវីដោយការជ្រើសរើស ឬដោយការចាត់តាំងដោយមិនយកកម្រៃស្របតាមលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចាប់តាំងពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី

[10] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ១៥ ឆ្នាំ២០១៦

[11] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ១៦ ឆ្នាំ២០១៦

[12] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៦ ឆ្នាំ២០១៦

- សិទ្ធិឱ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការរឿងក្តី ប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន
- សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃកាលបើមានការចាំបាច់
- សិទ្ធិបង្ហាញភស្តុតាង
- សិទ្ធិស្នើសុំឱ្យកោះហៅសាក្សី និងសួរសាក្សី
- សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស
- សិទ្ធិផ្សេងៗទៀតដូចដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តជាធរមាន។

**ការឃាត់ខ្លួន**

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឃាត់ខ្លួនអនីតិជនបាន ប្រសិនបើជឿជាក់ថា អនីតិជនអាចរត់គេចខ្លួន និងបង្កផលប៉ះពាល់ទៅដល់ជនរងគ្រោះ ឬសន្តិសុខសាធារណៈ ឬក្នុងគោលបំណងការពារសុវត្ថិភាពអនីតិជននោះ។ ដោយឡែក ករណីអនីតិជនដែលមានអាយុ ចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ ការឃាត់ខ្លួនអាចធ្វើទៅបានតែក្នុងករណីដែលអនីតិជននោះ បានប្រព្រឹត្តបទមជ្ឈិមដោយចេតនាប៉ុណ្ណោះ ហើយរាល់ការឃាត់ខ្លួនអនីតិជនត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម (ការឃាត់ខ្លួននេះគឺសម្រាប់តែវិធានការចុងក្រោយប៉ុណ្ណោះ)[13]។

ប្រសិនបើនីតិវិធីឃាត់ខ្លួនត្រូវបានអនុវត្ត លក្ខណៈពិសេសនៃការអនុវត្តការឃាត់ខ្លួនលើអនីតិជននោះ គឺមន្ត្រីនគរបាលយុត្តិធម៌មិនត្រូវយកអនីតិជនដាក់បង្ហាញមុខជាជួរឡើយ ក្នុងករណីគ្មានការយល់ព្រមជាមុនពីអនីតិជន ចាំបាច់ត្រូវមានការពិគ្រោះយោបល់ជាមួយមេធាវី និងអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជននោះជាមុន[14]។ ប្រសិនបើ អនីតិជនយល់ព្រម ត្រូវមានកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងផ្តិតម្រាមដៃពីសំណាក់អនីតិជននោះផងដែរ។ នីតិវិធីមួយទៀត ដែលចាំបាច់បំផុតរបស់មន្ត្រីនគរបាលយុត្តិធម៌ គឺត្រូវធានាថាអនីតិជនដែលត្រូវបានឃាត់ខ្លួន មិនត្រូវបានទទួលរងទារុណកម្ម ការបង្ខិតបង្ខំ ការគំរាមកំហែង ការសម្លុតបំភិតបំភ័យ ឬទង្វើណាមួយផ្សេងទៀត ដែលនាំឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់អនីតិជន ឬទទួលរងអំពើអមនុស្សធម៌ណាមួយឡើយ ដែលស្របទៅនឹងគោលការណ៍ក្នុងសន្ធិសញ្ញាស្តីពីសិទ្ធិកុមារអន្តរជាតិ និងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សអន្តរជាតិ ព្រមទាំងលិខិតតុបករណ៍អន្តរជាតិនានា។

មន្ត្រីនគរបាលយុត្តិធម៌ ចាំបាច់ត្រូវតែបញ្ចប់ដំណើរការស៊ើបអង្កេតរបស់ខ្លួនឱ្យបានលឿនបំផុតតាមតែដែលអាចធ្វើទៅបានសម្រាប់ជាឧត្តមប្រយោជន៍របស់អនីតិជន។ ចំពោះរយៈពេលនៃការឃាត់ខ្លួនវិញ មន្ត្រីនគរបាល

[13] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ១៧ ឆ្នាំ២០១៦

[14] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ២៣ ឆ្នាំ២០១៦

អាចឃាត់ខ្លួនអនីតិជនត្រឹមរយៈពេល ៤៨ ម៉ោងប៉ុណ្ណោះ ប្រសិនបើគ្មានតម្រុយពីបទល្មើសដែលអនីតិជនបានប្រព្រឹត្តទេនោះ មន្ត្រីនគរបាលយុត្តិធម៌មិនអាចបន្តរយៈពេលឃាត់ខ្លួនបានទៀតនោះទេ គឺត្រូវធ្វើការដោះលែងអនីតិជននោះឱ្យត្រឡប់ទៅវិញ ដោយមានការធានាពីឪពុកម្តាយ ឬអាណាព្យាបាលរបស់អនីតិជន។

**ការស្តាប់ចម្លើយ**[15]

ការស្តាប់ចម្លើយអនីតិជនត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ ព្រមទាំងវិធានមួយចំនួនទៀតដូចដែលមានចែងនៅក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ មេធាវី និងសេវាសង្គមកិច្ចជាកត្តាចាំបាច់ដែលមិនអាចខ្វះបាននៅពេលអនីតិជននោះត្រូវបាននាំខ្លួនមកដល់អង្គភាពនគរបាលយុត្តិធម៌។ ក្រោយពីអនីតិជនត្រូវបាននាំខ្លួនមកដល់អង្គភាពនគរបាលយុត្តិធម៌រួចមក មន្ត្រីនគរបាលនគរបាលយុត្តិធម៌ ត្រូវធ្វើការជូនដំណឹងភ្លាមទៅកាន់ភ្នាក់ងារសង្គមកិច្ច និងមេធាវីរបស់អនីតិជនផ្ទាល់។

មុនពេលចាប់ផ្តើមស្តាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់ដល់អនីតិជនអំពីសិទ្ធិជាមូលដ្ឋាន និងសិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានរបស់មេធាវីដូចទៅនឹងនីតិវិធីអនុវត្តចំពោះបុគ្គលដែលជានីតិជនដែរ។ ការស្តាប់ចម្លើយអនីតិជនគឺត្រូវធ្វើឡើងជាលក្ខណៈឯកជន និងសម្ងាត់ ដោយប្រើប្រាស់នីតិវិធីកុមារមេត្រី និងចាំបាច់ត្រូវមានវត្តមានរបស់មេធាវី។ បន្ទាប់ពីស្តាប់ចម្លើយភ្លាម អនីតិជន និងបុគ្គលដែលបានរៀបរាប់ខាងលើអាចអាន និងធ្វើការពិនិត្យកំណត់ហេតុស្តាប់ចម្លើយបាន។ អនីតិជនក៏អាចសុំធ្វើការកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបានផងដែរ មុននឹងចុះហត្ថលេខា ឬផ្តិតមេដៃ។

**១.២.១.២ ចំណាត់ការសំណុំរឿងដោយអយ្យការ**

អង្គការអយ្យការត្រូវបានបង្កើតដំបូងបង្អស់នៅឆ្នាំ ១៩៣៧ ដោយការបញ្ចូលតំណែងនេះទៅក្នុងក្រមពិភាក្សាព្រហ្មទណ្ឌ (ភាសាសម័យយើងនេះ គេហៅថាក្រមនីតិវិធីព្រហ្មទណ្ឌ)។ មុនឆ្នាំ ១៩៣៧ គេហៅថាក្រមលក្ខណពិភាក្សាព្រហ្មទណ្ឌ។ យោងតាមក្រមនេះ នៅអមសាលាដំបូងនីមួយៗមានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ហើយនៅអមសាលាជាន់ខ្ពស់មាន «ព្រះរាជបំរើ» និង«ភូឈួយព្រះរាជបំរើ»។ មកទល់ពេលនោះតំណែង ព្រះរាជអាជ្ញាមិនទាន់មាននៅគ្រប់សាលាដំបូងគ្រប់ខេត្តទេ គឺមានតែនៅភ្នំពេញតែប៉ុណ្ណោះ។ ដោយមានការខ្វះខាតថវិកា គេបានជ្រើសយកប្រធានសាលាដំបូងឱ្យដើរតួនាទីពីរៈ ជាព្រះរាជអាជ្ញានៅអមសាលានេះផង និងជាចៅក្រមជំនុំជម្រះផង។ តួនាទីព្រះរាជអាជ្ញានេះមកជំនួសតួនាទីរបស់ចៅក្រមស៊ើបសួរ ឬសភាចារបុរស ដែលដើមឡើយជាអ្នកបង្កសំណុំរឿងចោទប្រកាន់ទៅសាលាមជ្ឈឹម (ដែលជាផ្នែកនៃសាលាដំបូងសម្រាប់វិនិច្ឆ័យរឿងមជ្ឈឹមដែលមានទោសពី ៥ ថ្ងៃ ដល់ ៥ ឆ្នាំ) ឬទៅសាលាក្រុមចោទ (ដែលជាសាខាមួយរបស់សាលាឧទ្ធរណ៍ដែលពិនិត្យរឿងឧក្រិដ្ឋ និងរឿងដែលប្តឹងជំទាស់នឹងដីការបស់សភាចារបុរស)។

[15] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ២២ ឆ្នាំ២០១៦

ក្រោយពីបានទទួលសំណុំរឿងបន្តពីមន្ត្រីនគរបាលយុត្តិធម៌ហើយ តំណាងអយ្យការនឹងធ្វើការអនុវត្តបណ្តឹងអាជ្ញា ដោយត្រួតពិនិត្យទៅលើសំណុំរឿង នឹងធ្វើការចោទប្រកាន់លើបទល្មើសព្រហ្មទណ្ឌដែលទាក់ទងទៅនឹងអនីតិជន[16]។ ក្នុងករណីដែលមានវិមតិសង្ស័យអំពីអាយុរបស់អនីតិជន ព្រះរាជអាជ្ញាត្រូវបើកការស៊ើបអង្កេតបឋមឱ្យបានឆាប់រហ័សបំផុត ដើម្បីស្វែងរកឱ្យឃើញអាយុពិតប្រាកដរបស់អនីតិជននោះ[17]។ នីតិវិធីរបស់ព្រះរាជអាជ្ញា ក៏មិនមានលក្ខណៈអ្វីខុសប្លែកពីនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌នោះទេ ដោយព្រះរាជអាជ្ញាធ្វើការស្តាប់ចម្លើយរបស់អនីតិជន និងធ្វើការសន្និដ្ឋានទៅលើសំណុំរឿងនោះ ដោយអនុវត្តតាមគោលការណ៍កាលានុវត្តភាព។

***គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ចំពោះអនីតិជន***[18]

ក្រោយពីបានថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យបណ្តឹងហើយ ព្រះរាជអាជ្ញាអាចសម្រេចធ្វើការចោទប្រកាន់ទៅលើអនីតិជននោះបាន។ ព្រះរាជអាជ្ញា អាចចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅកាន់ចៅក្រមស៊ើបសួរ ដើម្បីបើកការស៊ើបសួរបន្ថែមទៅលើអនីតិជនដែលជាជនជាប់ចោទនោះ។ បន្ទាប់ពីធ្វើការចោទប្រកាន់ព្រះរាជអាជ្ញា ត្រូវឱ្យដំណឹងអំពីបទចោទប្រកាន់នោះទៅអនីតិជនដែលជាជនជាប់ចោទភ្លាម និងឪពុកម្តាយ ឬអាណាព្យាបាល និងមេធាវីរបស់អនីតិជន ដើម្បីរៀបចំមធ្យោបាយការពារអនីតិជន[19]។

ក្នុងករណីដែលមានការបារម្ភថា អនីតិជនអាចនឹងរត់គេចខ្លួន ព្រះរាជអាជ្ញាធ្វើការស្នើសុំទៅចៅក្រមស៊ើបសួរ ដើម្បីឃុំខ្លួនអនីតិជននោះបាន (ការស្នើនេះសម្រាប់តែមធ្យោបាយចុងក្រោយបង្អស់តែប៉ុណ្ណោះ)។ ជាមួយគ្នានេះ ព្រះរាជអាជ្ញាក៏ត្រូវពិចារណាដល់វិធានការផ្សេងទៀត ដែលមានលក្ខណៈគាប់ប្រសើរដូចជា វិធានការបង្វែរជាដើម ដែលបម្រើដល់ឧត្តមប្រយោជន៍របស់អនីតិជននោះផងដែរ។

### ១.២.២ នីតិវិធីនៃការស៊ើបសួរ និងការជំនុំជម្រះ

ការស៊ើបសួរ គឺជាដំណាក់កាលដែលចៅក្រមស៊ើបសួរ ប្រមូលផ្តុំនូវធាតុផ្សំចាំបាច់សម្រាប់ការកាត់សេចក្តី និងសម្រេចថានឹងធ្វើដូចម្តេចចំពោះការចោទប្រកាន់[20]។ យោងតាមមាត្រា ១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា "ចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរទាំងអស់ដែលខ្លួនយល់ឃើញថា មានប្រយោជន៍សម្រាប់បង្ហាញឱ្យឃើញការពិតដោយអនុលោមតាមច្បាប់។ ចៅក្រមស៊ើបសួរមានករណីកិច្ចស៊ើបសួរទាំងដាក់បន្ទុក

[16] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ២៤ ឆ្នាំ២០១៦

[17] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ២៥ ឆ្នាំ២០១៦

[18] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៤០ ឆ្នាំ២០០៧

[19] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ២៩ ឆ្នាំ២០១៦

[20] មេរៀននីតិវិធីព្រហ្មទណ្ឌ, រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ឆ្នាំ២០០៨ ទំព័រ ៤០

និងដោះបន្ទុក”។ ក្រោយពីបានបិទបញ្ចប់នូវកិច្ចស៊ើបសួរហើយចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងនោះទៅចៅក្រមជំនុំជម្រះដើម្បីធ្វើការជំនុំជម្រះ ដោយហេតុថាមានតែចៅក្រមទេដែលមានសិទ្ធិជំនុំជម្រះក្តី[21]។

**១.២.២.១ ការស៊ើបសួរធ្វើឡើងដោយចៅក្រមស៊ើបសួរ**

បន្ទាប់ពីបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរតំណាងអយ្យការ ចៅក្រមស៊ើបសួរត្រូវបើកការស៊ើបសួរភ្លាម នឹងត្រូវលើកយករឿងក្តីរបស់អនីតិជនយកមកចាត់ការជាអាទិភាព ពិសេសរឿងក្តីដែលអនីតិជនកំពុងជាប់បណ្តោះអាសន្ន[22]។ ការស៊ើបសួរករណីទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងអនីតិជន ជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ ដែលមានជំនាញទាក់ទងទៅនឹងអនីតិជន។ នៅពេលដែលអនីតិជនបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរត្រូវពិនិត្យអត្តសញ្ញាណអនីតិជន ហើយប្រាប់អនីតិជនឱ្យបានដឹងអំពីសិទ្ធិទាក់ទងនឹងដំណាក់នៃការស៊ើបសួរ។ ជនត្រូវចោទជាអនីតិជនត្រូវមានមេធាវីអមជានិច្ចក្នុងកំឡុងពេលស្តាប់ចម្លើយ និងនៅចំពោះមុខចៅក្រមស៊ើបសួរ។ ក្នុងករណីគ្មានការជ្រើសរើស ចៅក្រមស៊ើបសួរត្រូវចាត់តាំងមេធាវីនៅក្នុងលក្ខខណ្ឌដូចដែលចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី[23]។ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ចអំពីការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យនេះ។

ចំពោះការស្តាប់ចម្លើយអនីតិជន[24] ត្រូវធ្វើជាសម្ងាត់ ដោយប្រើប្រាស់នីតិវិធីកុមារមេត្រី និងត្រូវមានវត្តមានមេធាវីការពារ ភ្នាក់ងារសង្គមកិច្ច អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជនផងដែរ។ ចៅក្រមស៊ើបសួរ អាចមិនអនុញ្ញាតឱ្យអ្នកតំណាងដែលច្បាប់បានកំណត់ចូលរួមស្តាប់ចម្លើយបានប្រសិនបើវត្តមានអ្នកទាំងនោះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន។ ការមិនអនុញ្ញាតនេះ ត្រូវមានការពិគ្រោះយោបល់ជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជន។

ច្បាប់ស្តីពីយុត្តិធម៌អនីតិជនក៏បានផ្តល់សិទ្ធិអំណាចដល់ចៅក្រមស៊ើបសួរក្នុងការអនុវត្តនូវផែនការបង្វែរនេះផងដែរ។ ក្នុងករណីដែលអនីតិជនត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទមជ្ឈិម ឬបទមជ្ឈិមដែលមានស្ថានទម្ងន់ទោស ចៅក្រមស៊ើបសួរត្រូវធ្វើការពិចារណាជាបឋមទៅលើការបង្វែរ មុននឹងប្រើនូវវិធានការផ្សេងពីនេះ (ដូចមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន)។

ជាគោលការណ៍ការឃុំខ្លួនអនីតិជនជាបណ្តោះអាសន្នត្រូវតែជាវិធានការចុងក្រោយបំផុត។ ប៉ុន្តែ ការឃុំខ្លួនអនីតិជនជាបណ្តោះអាសន្ននេះ ក៏អាចធ្វើឡើងបានផងដែរនៅក្នុងករណី ដែលចៅក្រមស៊ើបសួរយល់ឃើញ

[21] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៨, មាត្រា ១២៩ ថ្មី (មាត្រា ១១០ ចាស់) កថាខណ្ឌ២ វាក្យខណ្ឌ១

[22] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៣៤ ឆ្នាំ២០១៦

[23] ច្បាប់ស្តីពីយុត្តិធម៌ងនីតិជន, មាត្រា ៣២ ឆ្នាំ២០១៦

[24] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៣៥ ឆ្នាំ២០១៦

ថា អនីតិជនជំទាស់នឹងច្បាប់អាចបង្កភាពចលាចលនៅកំឡុងពេលស៊ើបអង្កេត។ បន្ថែមលើបញ្ញត្តិស្តីពីលក្ខខណ្ឌមូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្នដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ ចៅក្រមស៊ើបសួរមុននឹង សម្រេចអំពីការឃុំខ្លួនជាបណ្ដោះអាសន្ន ត្រូវពិចារណាលើរបាយការណ៍ប៉ាន់ប្រមាណសុខុមាលភាព និង ស្ថានភាពសង្គមរបស់អនីតិជនផងដែរ (ប្រសិនបើមាន)[25]។

ចៅក្រមស៊ើបសួរ អាចដាក់អនីតិជនដែលជាជនត្រូវចោទឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ជំនួសឱ្យការឃុំខ្លួនជាបណ្ដោះអាសន្ន ប្រសិនបើអនីតិជនត្រូវចោទនោះ ត្រូវបានចោទប្រកាន់អំពីបទល្មើសដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ។ បន្ថែមលើបទបញ្ញត្តិស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការនៃក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរអាចបង្គាប់អនីតិជនដែលនៅក្រៅឃុំឱ្យគោរពកាតព្វកិច្ចមួយ ឬច្រើនដូចតទៅ[26] ៖

ដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពីឪពុកម្ដាយ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ឬក្រុមគ្រួសារណាមួយសមស្របឱ្យស្ថិតនៅក្រោមការគ្រប់គ្រង និងការថែទាំនៅក្នុងមណ្ឌលណាមួយរបស់រដ្ឋ ឬមណ្ឌលណាមួយរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលមាននីតិសម្បទាទទួល និងថែទាំអនីតិជនបង្គាប់មិនឱ្យអនីតិជនចេញដើរហួសម៉ោងកំណត់ ឬសេពគ្រឿងស្រវឹង ឬវិធានការផ្សេងទៀតដែលតុលាការយល់ឃើញថាសមស្រប។

មុននឹងចេញដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរត្រូវពិនិត្យ និងពិចារណាទៅលើរបាយការណ៍ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន។ ក្នុងករណីរបាយការណ៍ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនមិនទាន់មានលក្ខណៈគ្រប់គ្រាន់ ចៅក្រមស៊ើបសួរត្រូវបង្គាប់ឱ្យភ្នាក់ងារសង្គមកិច្ច ផ្ដល់របាយការណ៍បន្ថែមក្នុងរយៈពេលឆាប់បំផុតតាមដែលអាចធ្វើទៅបាន ដោយមិនឱ្យលើសរយៈពេល ១០ ថ្ងៃនៃថ្ងៃធ្វើការ។

បន្ទាប់ពីចៅក្រមស៊ើបសួរបានចេញសេចក្ដីសម្រេចរបស់ខ្លួនរួចមកហើយ ព្រះរាជអាជ្ញាអាចធ្វើការប្ដឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍បាន ចំពោះដីកាដែលសម្រេចដោយចៅក្រមស៊ើបសួរក្នុងករណីដែលយល់ឃើញថា សេចក្ដីសម្រេចរបស់ចៅក្រមស៊ើបសួរមិនសមស្រប ដោយពិចារណាជាចម្បងពីឧត្ដមប្រយោជន៍របស់អនីតិជននោះ។

[25] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៣៩ ឆ្នាំ២០១៦

[26] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៤០ ឆ្នាំ២០១៦

**១.២.២.២ ការជំនុំជម្រះ**

កាលបើសំណុំរឿងត្រូវបានកសាងរួចហើយ រឿងក្តីអាចត្រូវបានបញ្ជប់ លុះត្រាតែបានឆ្លងកាត់នូវការជំនុំជម្រះដែលធ្វើឡើងនៅក្នុងសវនាការ និងរួមទាំងប្រកាសសាលក្រមផងដែរ។ ការជំនុំជម្រះលើរឿងក្តីអនីតិជនត្រូវធ្វើឡើងដោយចៅក្រមជំនុំជម្រះដែលមានជំនាញទាក់ទងទៅនឹងអនីតិជន ដែលមានសមាសភាពចៅក្រមជំនុំជម្រះចំនួន ៣ រូបធ្វើការសិក្សា និងសម្រេចថាអនីតិជនមាន ឬគ្មានបទល្មើស[27]។

ការពិភាក្សាដេញដោល និងការប្រកាសសាលក្រមរឿងក្តីអនីតិជន ត្រូវធ្វើឡើងក្នុងសវនាការជាអសាធារណៈ[28]។ មានតែបុគ្គលដែលមានសិទ្ធិ និងកាតព្វកិច្ច ឬផលប្រយោជន៍ដែលពាក់ព័ន្ធនឹងរឿងក្តីប៉ុណ្ណោះដែលមានសិទ្ធិចូលរួមសវនាការបាន។ អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជនត្រូវចូលរួមក្នុងសវនាការ លើកលែងតែមានសំណូមពរពីអនីតិជនផ្ទុយពីនេះ ឬតុលាការយល់ឃើញថាការចូលរួមរបស់បុគ្គលទាំងនោះមិនបម្រើឱ្យឧត្តមប្រយោជន៍របស់អនីតិជន។

នៅពេលសវនាការ តុលាការត្រូវប្រើនីតិវិធីកុមារមេត្រី[29]។ ក្នុងកាលៈទេសៈពិសេសមេធាវីរបស់អនីតិជនភ្នាក់ងារសង្គមកិច្ច ឬព្រះរាជអាជ្ញា អាចស្នើសុំឱ្យតុលាការប្រើប្រាស់របាំងក្នុងពេលសវនាការ ឬប្រើវិធីសមស្របណាមួយក្នុងការស្តាប់ចម្លើយ។ ជាមួយគ្នានេះ ជំនួយរបស់មេធាវីត្រូវមានជាដាច់ខាតនៅពេលសវនាការ។ ក្នុងករណី ដែលគ្មានការជ្រើសរើសដោយអនីតិជន មេធាវីត្រូវបានចាត់តាំងដោយមិនយកកម្រៃតាមគំនិតផ្តើមរបស់ប្រធានតុលាការនៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

នៅពេលចាប់ផ្តើមសវនាការតុលាការត្រូវប្រាប់អនីតិជនដោយប្រើប្រាស់ភាសាដែលអនីតិជនអាចយល់បានអំពីសិទ្ធិមួយចំនួនដូចខាងក្រោម[30] ៖

- សិទ្ធិដែលទាក់ទងទៅនឹងដំណាក់កាលនៃការជំនុំជម្រះ
- សិទ្ធិមានវត្តមាននៅពេលជំនុំជម្រះក្តី
- សិទ្ធិទទួលបានការការពារពីតុលាការនូវទង្វើមិនគប្បី ឬការសួរដេញដោលមិនសមរម្យ
- សិទ្ធិប្តឹងជិតចិត្តចៅក្រមជំនុំជម្រះ
- សិទ្ធិធ្វើសំណូមពរចុងក្រោយ និង
- សិទ្ធិប្តឹងឧទ្ធរណ៍ ជាអាទិ៍។

---

[27] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៤៤ ឆ្នាំ២០១៦
[28] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៤៧ ឆ្នាំ២០១៦
[29] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៤៨ ឆ្នាំ២០១៦
[30] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៥១ ឆ្នាំ២០១៦

វិធានការបង្វែរ ក៏ត្រូវបានលើកយកមកពិចារណាក្នុងដំណាក់កាលនៃការជំនុំជម្រះ ដូចទៅនឹងដំណាក់កាលព្រះរាជអាជ្ញា និងដំណាក់កាលចៅក្រមស៊ើបសួរផងដែរ។ ដោយចៅក្រមជំនុំជម្រះមានអំណាចក្នុងការអនុវត្តនូវវិធានការបង្វែរចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ដែលជាប់ចោទពីបទលហុ បទមជ្ឈិម ឬបទមជ្ឈិមមានស្ថានទម្ងន់ទោស។ ចៅក្រមត្រូវពិនិត្យ និងពិចារណាទៅលើលក្ខខណ្ឌអប្បបរមាដែលតម្រូវឱ្យបំពេញដោយអនីតិជនដើម្បីអាចអនុវត្តវិធានការនេះបាន។ មួយវិញទៀត ប្រសិនបើអនីតិជនបានសារភាពនូវកំហុសរបស់ខ្លួនដែលបានប្រព្រឹត្តក្នុងពេលជំនុំជម្រះ តុលាការត្រូវតែពិនិត្យថ្លឹងថ្លែង និងបញ្ជាក់ថាចម្លើយសារភាពទទួលយកពិរុទ្ធភាពរបស់អនីតិជននៅពេលសវនាការ ត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្ត និងគ្មានការគំរាមកំហែង ឬការបង្ខិតបង្ខំណាមួយឡើយ។ រាល់ចម្លើយសារភាពរបស់អនីតិជន ដែលផ្ទុយនឹងបញ្ញត្តិខាងលើនេះ មិនត្រូវចាត់ទុកជាភស្តុតាងនៃពិរុទ្ធភាពឡើយ។ ហើយចំពោះការសារភាពទទួលយកផែនការបង្វែរមិនត្រូវចាត់ទុកជាភស្តុតាង សម្រាប់ពិរុទ្ធភាពក្នុងបទល្មើសដដែលសម្រាប់នីតិវិធីព្រហ្មទណ្ឌបន្តបន្ទាប់នោះឡើយ។ ក្នុងពេលសវនាការ តុលាការត្រូវផ្ទៀងផ្ទាត់ពីភាពស៊ីចង្វាក់នៃចម្លើយសារភាព និងភស្តុតាងផ្សេងទៀតនៃបទល្មើស។

សាលក្រមត្រូវប្រកាសនៅពេលសវនាការ ក្រោយពីធ្វើការពិភាក្សាដេញដោល ឬនៅពេលសវនាការលើកក្រោយ។ ជាគោលការណ៍ សាលក្រមត្រូវប្រកាសឡើងជាអសាធារណៈនៅចំពោះមុខអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវី ឬភ្នាក់ងារសង្គមកិច្ច និងភាគីដែលមានប្រយោជន៍នៅក្នុងរឿងក្តី។ សាលក្រមអាចប្រកាសកំបាំងមុខអនីតិជនបាន ក្នុងករណីដែលការប្រកាសសាលក្រមចំពោះមុខធ្វើឱ្យខូចដល់ឧត្តមប្រយោជន៍របស់អនីតិជននោះ។

# ជំពូកទី២

## ការអនុវត្តទោស

# ជំពូកទី២

# ការអនុវត្តទោស

ការអនុវត្តទោស គឺជាដំណើរការនៃការអនុវត្តតាមនីតិវិធីដែលតុលាការបានធ្វើការផ្តន្ទាទោសចំពោះជនល្មើស ពោលគឺក្រោយពីតុលាការធ្វើការប្រកាសទណ្ឌកម្មចំពោះទណ្ឌិតណាម្នាក់រួចហើយ។ យោងតាមស្មារតីនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន រាល់ការអនុវត្តទោសចំពោះអនីតិជន គឺធ្វើឡើងក្នុងគោលបំណងដើម្បីស្តារនីតិសម្បទាដល់អនីតិជននោះតែប៉ុណ្ណោះ ហើយអនីតិជនមិនអាចត្រូវបានធ្វើការឃុំខ្លួន ឬអនុវត្តទោសដូចទៅនឹងនីតិជនឡើយ។ រាល់ការឃុំខ្លួនអនីតិជនធ្វើឡើងក្នុងគោលបំណងស្តារនីតិសម្បទាជាអាទិ៍ ការបណ្តុះបណ្តាល ការព្យាបាល ការថែទាំ ការការពារ ការអប់រំ និងផ្តល់ជំនាញវិជ្ជាជីវៈក្នុងទស្សនៈជួយឱ្យអនីតិជនក្លាយទៅជាពលរដ្ឋសុចរិត និងមានប្រយោជន៍ដល់សង្គមជាតិ[31]។ ដោយឡែក ថ្វីត្បិតតែច្បាប់នេះបញ្ញត្តិមកមានគោលបំណងបែបនេះក៏ពិតមែន ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង គេពុំទាន់ឃើញមាននៅមណ្ឌលយុវនីតិសម្បទាសម្រាប់អនុវត្តទោសចំពោះអនីតិជននៅឡើយ។ ជាមួយនេះដែរ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនដដែលនេះ ក៏បានបញ្ញត្តិផ្តល់សិទ្ធិដល់តុលាការក្នុងការប្រកាសទោសចំពោះអនីតិជនដែលប្រព្រឹត្តបទល្មើស ក្នុងស្ថានភាពបែបនេះផងដែរ ដែលមានបញ្ញត្តិនៅមាត្រា ៨៨ កថាខណ្ឌទី១ ដែលមានខ្លឹមសារ "ក្នុងករណីមិនទាន់មានមណ្ឌលយុវនីតិសម្បទា វិធានការទាំងឡាយដែលកំពុងអនុវត្តទៅលើអនីតិជន ត្រូវបន្តអនុវត្តរហូតដល់មានមណ្ឌលយុវនីតិសម្បទា" ។ ដូច្នេះ ការអនុវត្តទោសចំពោះអនីតិជន ក្នុងស្ថានភាពបច្ចុប្បន្ននឹងប្រព្រឹត្តទៅមានលក្ខណៈដូចខាងក្រោម ៖

## ២.១ ការអនុវត្តទោសដាក់ពន្ធនាគារ

ពន្ធនាគារ សំដៅដល់កន្លែងប្រើសម្រាប់ធ្វើការឃុំឃាំងជនជាប់ឃុំតាមលិខិតឃុំខ្លួនចេញដោយអាជ្ញាធរតុលាការ រួមមានមណ្ឌលឃុំខ្លួន និងមណ្ឌលអប់រំកែប្រែផង[32]។ ការដាក់ពន្ធនាគារអនីតិជនដែលរកឃើញថាល្មើសនឹងច្បាប់ព្រហ្មទណ្ឌ ត្រូវតែជាវិធានការចុងក្រោយបង្អស់ ដែលត្រូវបានប្រើតែក្នុងករណីពិសេសប៉ុណ្ណោះ[33]។ គោលបំណងចម្បងក្នុងការអនុវត្តទោសចំពោះអនីតិជនក្នុងពន្ធនាគារ គឺដើម្បីធ្វើការអប់រំ កែប្រែ បណ្តុះបណ្តាលវិជ្ជាជីវៈ និងស្តារនីតិសម្បទាដល់ទណ្ឌិតដែលជាអនីតិជននោះតែប៉ុណ្ណោះ។ ក្នុងគោលដៅដើម្បីក្រោយពីការអនុវត្តទោសត្រូវបានបញ្ចប់រួចហើយ អាចឱ្យអនីតិជននោះចូលរួមរស់នៅក្នុងសង្គមដូចដើមវិញ។ ទិដ្ឋភាពក្នុងការអនុវត្តទោសចំពោះអនីតិជនក្នុងពន្ធនាគារនេះ នឹងត្រូវបង្ហាញតាមរយៈពីរចំណុចសំខាន់ៗដូចខាងក្រោមគឺ ៖

[31] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៧៩ ឆ្នាំ២០១៦

[32] ច្បាប់ស្តីពីពន្ធនាគារ, មាត្រា ៤ ចំណុច ១ ឆ្នាំ២០១១

[33] អនុសញ្ញាស្តីពីសិទ្ធិកុមារ, មាត្រា ៣៧ (ខ)

### ២.១.១ ការឃុំឃាំងអនីតិជនក្នុងពន្ធនាគារ

ការឃុំឃាំងក្នុងពន្ធនាគារ គឺជាវិធីមួយដែលធ្វើការឃុំអនីតិជនដែលជាជនជាប់ឃុំនៅក្នុងបន្ទប់ឃុំឃាំង ហើយការណ៍ដែលឃុំឃាំងនេះ ទៀតសោតត្រូវបានបែងចែកទៅតាមប្រភេទនៃជនជាប់ឃុំនីមួយៗនោះផងដែរ ។ ជនជាប់ឃុំ សំដៅដល់ជនត្រូវចោទ ឬជនជាប់ចោទ ឬពិរុទ្ធជន ឬទណ្ឌិត ដែលត្រូវបានបញ្ជូនមកឃុំខ្លួននៅក្នុងពន្ធនាគារ តាមលិខិតឃុំខ្លួនដែលចេញដោយអាជ្ញាធរតុលាការ[34]។ ជនជាប់ឃុំជាអនីតិជន ត្រូវដាក់ដោយឡែកពីជនជាប់ឃុំជានីតិជន។ ជនជាប់ឃុំ ដែលជាជនត្រូវចោទ ជនជាប់ចោទ ឬពិរុទ្ធជនត្រូវដាក់បំបែកពីជនជាប់ឃុំជាទណ្ឌិត[35]។ ក្រៅពីនេះ ជនជាប់ឃុំជាស្ត្រីត្រូវដាក់ដាច់ដោយឡែកពីជនជាប់ឃុំជាបុរស ចំពោះជនជាប់ឃុំដែលមានជំងឺផ្លូវចិត្ត ក៏ត្រូវដាក់បំបែកដាច់ដោយឡែក ពីជនជាប់ឃុំដទៃទៀតផងដែរ។ គេសង្កេតឃើញថា ការបែងចែកការឃុំខ្លួនអនីតិជននៅក្នុងពន្ធនាគារទៅតាមប្រភេទខាងលើនេះ គឺមានលក្ខណៈខុសប្លែកគ្នាពីការអនុវត្តទោសចំពោះអនីតិជនក្នុងមណ្ឌលឃុំនីតិសម្បទា ដោយការអនុវត្តទោសចំពោះអនីតិជនក្នុងមណ្ឌលឃុំនីតិសម្បទា ត្រូវបានបែងចែកជា ៣ (បី) ផ្នែកដាច់ដោយឡែកពីគ្នាគឺ[36] ៖

១. ផ្នែកសម្រាប់ឃុំខ្លួនអនីតិជនបណ្ដោះអាសន្ន

២. ផ្នែកសម្រាប់ឃុំខ្លួនទណ្ឌិតជាអនីតិជនដើម្បីទទួលកម្មវិធីស្ដារនីតិសម្បទា និង

៣. ផ្នែកសម្រាប់ត្រៀមដោះលែងអនីតិជន ដើម្បីទទួលកម្មវិធីសមាហរណកម្ម។

មួយវិញទៀត ក្រៅពីការបែងចែកផ្នែកសម្រាប់គ្រប់គ្រងអនីតិជននេះហើយ ក៏ត្រូវរក្សាអនីតិជនឱ្យនៅដាច់ដោយឡែកពីនីតិជនផងដែរ ពោលគឺត្រូវដាក់នៅក្នុងអគារដាច់ដោយឡែកទៅតាមភេទផ្សេងៗគ្នា តាមប្រភេទ និងស្ថានភាពនៃបទល្មើស អាយុ អត្តចរិត សុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្តរបស់អនីតិជននោះ។ ចំពោះអនីតិជនភេទស្រីវិញ ត្រូវស្ថិតនៅក្រោមការថែទាំរបស់បុគ្គលិកដែលមានភេទស្រីដូចគ្នា។ រីឯក្នុងករណីអនីតិជនដែលមានជំងឺផ្លូវចិត្ត ត្រូវនៅក្នុងអគារដាច់ដោយឡែក និងដឹកជញ្ជូនតាមមធ្យោបាយដាច់ដោយឡែកពីអនីតិជនផ្សេងៗជាកំហិត។ ប្រសិនបើទណ្ឌិតជាអនីតិជនឈានចូលអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ក្នុងពេលកំពុងតែអនុវត្តទោសនៅក្នុងមណ្ឌលឃុំនីតិសម្បទា ទណ្ឌិតនោះនឹងត្រូវបានរក្សាទុកនៅក្នុងមណ្ឌលឃុំនីតិសម្បទាបន្តរហូតដល់អាយុក្រោម ២៤ (ម្ភៃបួន) ឆ្នាំ។ នៅពេលដែលទណ្ឌិតនោះឈានចូលអាយុគ្រប់ ២៤ (ម្ភៃបួន) ឆ្នាំ ទណ្ឌិតនោះត្រូវផ្ទេរទៅអនុវត្តទោសបន្តនៅក្នុងមណ្ឌលឃុំឃាំងសម្រាប់នីតិជនវិញ[37]។

[34] ច្បាប់ស្ដីពីពន្ធនាគារ, មាត្រា ៤ ចំណុច ៣ ឆ្នាំ២០១១

[35] ច្បាប់ស្ដីពីពន្ធនាគារ, មាត្រា ៦ ឆ្នាំ២០១១

[36] ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន, មាត្រា ៧៧ ឆ្នាំ២០១៦

[37] ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន, មាត្រា៨២ កថាខណ្ឌ ២ ឆ្នាំ២០១៦

ដោយឡែកអ្វីដែលបានលើកឡើងខាងលើអំពីការអនុវត្តទោស ចំពោះអនីតិជននៅក្នុងមណ្ឌលឃុំ-នីតិសម្បទានេះ គ្រាន់តែជាសញ្ញាណថ្មីមួយនៃច្បាប់ពិសេសស្តីពីយុត្តិធម៌អនីតិជន ដែលនឹងត្រូវលើកយកមកអនុវត្តចំពោះអនីតិជននៅពេលអនាគតតែប៉ុណ្ណោះ។

ដូច្នេះ ជាបន្តទៅទៀតនេះ យើងនឹងធ្វើការសិក្សាអំពីប្រភេទនៃជនជាប់ចោទក្នុងពន្ធនាគារដែលត្រូវអនុវត្តក្នុងស្ថានភាពបច្ចុប្បន្ន ៖

**ជនត្រូវចោទ** គឺជាបុគ្គលដែលត្រូវបានព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ហើយបញ្ជូនទៅចៅក្រមស៊ើបសួរ ដោយចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[38]។ ការឃុំឃាំងជាបណ្តោះ-អាសន្នទៅលើអនីតិជនដែលជាជនត្រូវចោទ អាចធ្វើបានតែក្នុងលក្ខខណ្ឌដូចដែលមានចែងកំណត់ក្នុងច្បាប់[39]។ ហើយដើម្បីអាចអនុវត្តការឃុំខ្លួនទៅលើអនីតិជននេះបាន ទល់តែក្នុងករណីដែលអនីតិជននោះត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលច្បាប់បានកំណត់តម្រូវឱ្យធ្វើការផ្តន្ទាទោសដាក់ពន្ធនាគារតែប៉ុណ្ណោះ[40]។ ចំពោះរយៈពេលនៃការឃុំខ្លួនវិញ គឺមិនត្រូវឱ្យលើសពីរយៈពេលដូចដែលបានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនោះទេ ព្រោះនេះគឺជាកំណត់របស់ច្បាប់។

**ជនជាប់ចោទ** គឺជាជនដែលត្រូវបានបញ្ជូនខ្លួនទៅចំពោះមុខតុលាការ ដើម្បីបើកសវនាការធ្វើការជំនុំជម្រះតាមដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងទៅកាន់តុលាការជំនុំជម្រះដោយផ្ទាល់របស់ព្រះរាជអាជ្ញា[41]។ ការឃុំខ្លួនអនីតិជន ដែលជាជនជាប់ចោទក្នុងពន្ធនាគារ គឺត្រូវអនុវត្តទៅតាមនីតិវិធីនៃការឃុំខ្លួនជាបណ្តោះអាសន្ន ដូចដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្ម-ទណ្ឌដែលមានស្រាប់។ ចំពោះរយៈពេលនៃការឃុំខ្លួនវិញ ក៏មិនត្រូវឱ្យលើសពីរយៈពេលដូចដែលបានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែរ។

**ពិរុទ្ធជន** ជាជនដែលតុលាការមិនទាន់បានកាត់ទោស ហើយត្រូវបានសន្មតថាគ្មានកហុស។ ពិរុទ្ធជនអាចជាជនជាប់សង្ស័យ ឬជនជាប់ចោទក្នុងបទល្មើសណាមួយ ហើយត្រូវបានឃុំខ្លួនក្នុងមន្ទីរឃុំឃាំងស្របច្បាប់តាមអំណាចដីកា រងចាំការសម្រេចពីតុលាការ[42]។ ក្រោយពីជំនុំជម្រះរួចហើយ ក៏ត្រូវរងចាំរយៈពេលមួយសម្រាប់ឱ្យសេចក្តីសម្រេចនោះចូលជាស្ថាពរផងដែរ ដើម្បីបញ្ចប់នូវនីតិវិធីតាមផ្លូវបណ្តឹងរបស់អនីតិជននេះទៅកាន់តុលាការជាន់ខ្ពស់។

[38] មេរៀននីតិវិធីព្រហ្មទណ្ឌ, សាស្ត្រាចារ្យ មីន សំអុល ទំព័រ ១០

[39] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២០៣ ឆ្នាំ២០០៧

[40] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២០៤ ឆ្នាំ២០០៧

[41] នីតិព្រហ្មទណ្ឌទូទៅ, សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ ទំព័រ ៥៣៥

[42] នីតិព្រហ្មទណ្ឌទូទៅ, សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ ទំព័រ ៥៦៧

**ទណ្ឌិត** ជាជនដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសរួច ហើយសេក្តីសម្រេចនោះបានចូលជាស្ថាពរ[43]។ ការឃុំខ្លួនក្នុងពន្ធនាគារ ត្រូវអនុវត្តរហូតដល់រយៈពេលនៃការអនុវត្តទោសនោះត្រូវបានបញ្ចប់ ហើយអំឡុងពេលនៃការអនុវត្តទោសនេះដែរ ទណ្ឌិតជាអនីតិជនក៏ត្រូវគោរពនូវបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ និងស្តាប់តាមការណែនាំពីសំណាក់មន្ត្រីពន្ធនាគារឱ្យបានខ្ជាប់ខ្ជួនផងដែរ[44]។ ក្រៅពីស្តាប់តាមការណែនាំ និងគោរពតាមបទបញ្ជាផ្ទៃក្នុងហើយ ក៏មានកាតព្វកិច្ចត្រូវធ្វើពលកម្ម ព្រមទាំងបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងពន្ធនាគារថែមទៀតផង។

ដូច្នេះ ស្ថានភាពឃុំឃាំងនៅក្នុងពន្ធនាគារដែលអនុវត្តចំពោះអនីតិជន បានធ្វើការបែងចែកជនត្រូវចោទ និងជនជាប់ចោទ ធ្វើឡើងស្របទៅតាមនីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្នដូចមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ រីឯចំពោះពិរុទ្ធជនវិញ ការឃុំខ្លួនអាចធ្វើទៅបានទល់តែត្រូវរង់ចាំសេចក្តីសម្រេចរបស់តុលាការចូលជាស្ថាពរជាមុនសិន ទើបអាចឃុំខ្លួនជននោះបាន។ ងាកមកទណ្ឌិតឯនេះវិញ ការឃុំខ្លួនត្រូវអនុវត្តរហូតដល់រយៈពេលនៃការឃុំខ្លួនត្រូវបានបញ្ចប់ ទើបអាចដោះលែងជននោះឱ្យមានសេរីភាពដូចដើមវិញបាន។

### ២.១.២ ការត្រួតពិនិត្យការអនុវត្តទោសក្នុងពន្ធនាគារ

ការត្រួតពិនិត្យការអនុវត្តទោសក្នុងពន្ធនាគារ ជាភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធនាគារចំណុះឱ្យក្រសួងមហាផ្ទៃ និងពន្ធនាគាររាជធានី-ខេត្ត។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា ប្រធានសភាស៊ើបសួរ និងចៅក្រមស៊ើបសួរ ត្រូវធ្វើអធិការកិច្ចពន្ធនាគារស្របទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ។ យន្តការបង្ការថ្នាក់ជាតិក៏ត្រូវបានអនុញ្ញាតឱ្យចូលទស្សនៈកិច្ចពន្ធនាគារផងដែរ ក្នុងគោលបំណងត្រួតពិនិត្យលើលក្ខខណ្ឌនៃការឃុំខ្លួន និងការប្រព្រឹត្តចំពោះជនជាប់ឃុំ និងផ្តល់អនុសាសន៍បន្ថែម ដើម្បីកែលម្អការប្រព្រឹត្តទៅរបស់ពន្ធនាគារឱ្យមានភាពល្អប្រសើរ[45]។

រាល់ការអនុវត្តទោសដាក់ពន្ធនាគារ គឺត្រូវធ្វើឡើងស្របទៅតាមច្បាប់ស្តីពីពន្ធនាគារ និងប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ។ ក្រសួងមហាផ្ទៃ ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងពន្ធនាគារនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមានអគ្គនាយកដ្ឋានពន្ធនាគារជាសេនាធិការឱ្យក្នុងការគ្រប់គ្រងពន្ធនាគារ[46]។ ក្រសួងមហាផ្ទៃត្រូវធ្វើប្រតិភូកម្មមុខងារឱ្យរដ្ឋបាលរាជធានី-ខេត្ត ក្នុងការគ្រប់គ្រងពន្ធនាគាររាជធានី-ខេត្ត ហើយពន្ធនាគារនេះ ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់គណៈអភិបាលរាជធានី-ខេត្ត[47]។ ពន្ធនាគារ ត្រូវគ្រប់គ្រងដោយ

[43] នីតិព្រហ្មទណ្ឌទូទៅ, សាស្រ្តាចារ្យ រុន ពណ្ណារិទ្ធ ទំព័រ ៥៤០

[44] ច្បាប់ស្តីពីពន្ធនាគារ, មាត្រា ២០ ឆ្នាំ២០១១

[45] ច្បាប់ស្តីពីពន្ធនាគារ, មាត្រា ៥៤ ឆ្នាំ២០១១

[46] ច្បាប់ស្តីពីពន្ធនាគារ, មាត្រា ៥-៦ ឆ្នាំ២០១១

[47] ច្បាប់ស្តីពីពន្ធនាគារ, មាត្រា ៩ ឆ្នាំ២០១១

ប្រធានពន្ធនាគារមួយរូប ហើយមានអនុប្រធានពន្ធនាគារយ៉ាងតិចមួយរូប ដែលត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ពន្ធនាគារនីមួយៗ ត្រូវមានអ្នកផ្តល់ការថែទាំសុខភាពមួយរូប និងមន្ត្រីអនុរក្សពន្ធនាគារជាច្រើនរូបផ្សេងទៀតដែលមានតួនាទី និងភារកិច្ចថែរក្សា ព្រមទាំងជម្រុញឱ្យការងារពន្ធនាគារដំណើរការទៅបានប្រកបដោយប្រសិទ្ធភាពខ្ពស់[48]។

ប្រធានពន្ធនាគារ ជាអ្នកទទួលខុសត្រូវដោយផ្ទាល់ក្នុងការគ្រប់គ្រងពន្ធនាគារទៅតាមនីតិវិធី និងបទបញ្ជាផ្ទៃក្នុងដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃឱ្យបានត្រឹមត្រូវ[49]។ មន្ត្រីពន្ធនាគារ អាចធ្វើការឆែកឆេរជនជាប់ឃុំ និងកន្លែងនានាក្នុងពន្ធនាគារ ដើម្បីធានាសន្តិសុខ និងសុវត្ថិភាពរបស់ពន្ធនាគារប្រសិនបើជនជាប់ឃុំដែលបដិសេធមិនឱ្យមន្ត្រីពន្ធនាគារឆែកឆេរ ត្រូវចាត់ទុកថាជាការល្មើសនឹងបទបញ្ជាផ្ទៃក្នុងពន្ធនាគារ[50]។

### ២.២ ការអនុវត្តទោសពិន័យចំពោះអនីតិជន

ទោសពិន័យ គឺជាទោសព្រហ្មទណ្ឌមួយប្រភេទដែលស្ថិតក្នុងឋានៈជាមូលទោស ហើយខុសពីទណ្ឌកម្មផ្សេងៗទៀតដែលចៅក្រមបានធ្វើការប្រកាសផ្តន្ទាទោស ពោលគឺសំដៅទៅលើទោសមួយប្រភេទដែលមានគោលដៅធ្វើឱ្យជនល្មើសនោះមានការរាងចាលតែម្តង[51]។ ដូច្នេះ ក្នុងករណីអនីតិជនម្នាក់បានប្រព្រឹត្តបទល្មើស ចៅក្រមអាចប្រកាសឱ្យអនីតិជននោះបង់សំណងចូលថវិការដ្ឋផង និងសម្រេចឱ្យបង់សំណងរដ្ឋប្បវេណីទៅជនរងគ្រោះថែមទៀត។ ដើម្បីអាចធានាបាននូវការបង់ប្រាក់ពិន័យ វិធានការជាទូទៅដែលត្រូវលើកយកមកអនុវត្តចំពោះទណ្ឌិតដែលជាអនីតិជននោះ គឺការដាស់តឿនឱ្យបង់ប្រាក់ពិន័យធ្វើឡើងដោយអាជ្ញាធរតុលាការ។

យើងអាចនិយាយបានថា ទោសពិន័យជាប្រាក់ គឺជាទោសដែលចៅក្រមធ្វើការសម្រេចឱ្យពិរុទ្ធជនធ្វើការបង់ទៅខាងរតនាគារជាតិទៅតាមសេចក្តីសម្រេចរបស់តុលាការ ដោយមានការត្រួតពិនិត្យពីព្រះរាជអាជ្ញាផងដែរ។ ដែលការពិន័យត្រូវគិតជាប្រាក់រៀល ដូចមានកំណត់ក្នុងមាត្រា ៤៣ វាក្យខ័ណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ។

#### ២.២.១ ការដាស់តឿនឱ្យបង់ប្រាក់ពិន័យ[52]

ជាទូទៅ ប្រសិនបើដល់ការកំណត់ដែលត្រូវបង់ប្រាក់ពិន័យ ហើយទណ្ឌិតមិនបានបង់ទេនោះ អង្គភាពរតនាគារ ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង ក្រោយពីបានទទួលដំណឹងនេះហើយព្រះរាជអាជ្ញាត្រូវកំណត់រយៈពេលចុងក្រោយបង្អស់មួយ សម្រាប់ទុកដល់ទណ្ឌិតដែលជាអនីតិជននោះដើម្បីឱ្យ

---

[48] នីតិព្រហ្មទណ្ឌទូទៅ, សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ ទំព័រ ៤៣៤

[49] ច្បាប់ស្តីពីពន្ធនាគារ, មាត្រា ៤៣ ឆ្នាំ២០១១

[50] ច្បាប់ស្តីពីពន្ធនាគារ, មាត្រា ៤៤ ឆ្នាំ២០១១

[51] ទោសព្រហ្មទណ្ឌ, លោក កៅ សីហា ទំព័រ ៤៤

[52] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៥២៥ ឆ្នាំ២០០៧

បង់ប្រាក់ពិន័យ។ រីឯចំពោះរយៈពេលដែលព្រះរាជអាជ្ញាបានកំណត់នោះមិនអាចតិចជាង ១០ ថ្ងៃឡើយ។ មិនតែប៉ុណ្ណោះ ការជូនដំណឹងនេះទៀតសោតចាំបាច់ត្រូវធ្វើឡើងដោយផ្ទាល់មាត់ ឬតាមផ្លូវរដ្ឋបាល ឬតាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថផងដែរ។ លើសពីនេះទៅទៀត ការឱ្យដំណឹងនេះត្រូវតែមានការធ្វើជាកំណត់ហេតុដែលត្រូវចុះហត្ថលេខាដោយទណ្ឌិត ឬផ្តិតម្រាមដៃក្នុងករណីដែលទណ្ឌិតមិនចេះចុះហត្ថលេខា។

សូមបញ្ជាក់ផងដែរថា ទោះបីជាមានការជូនដំណឹងដោយព្រះរាជអាជ្ញា អំពីការដាស់តឿនឱ្យទណ្ឌិតដែលជាអនីតិជននោះ បង់ប្រាក់ពិន័យបែបនេះក៏ដោយ។ ដោយឡែក ក្នុងករណីដែលអនីតិជននោះនៅតែមិនព្រមបង់ប្រាក់ពិន័យ ព្រះរាជអាជ្ញាមិនអាចអនុវត្តវិធានការបង្ខំដល់រូបកាយចំពោះអនីតិជននោះបានឡើយ។

### ២.២.២ ការរួចខ្លួនពីការបង្ខំដល់រូបកាយ

ការបង្ខំដល់រូបកាយ ត្រូវអនុវត្តទៅលើបុគ្គលដែលត្រូវផ្តន្ទាទោសដោយតុលាការព្រហ្មទណ្ឌ ហើយដែលជននោះមិនបានបង់នូវប្រាក់ពិន័យ ប្រាក់ពន្ធនៃនីតិវិធី និងប្រាក់សំណងជំងឺចិត្តទៅឱ្យដើម្បីបណ្តឹងរដ្ឋប្បវេណីជាអាទិ៍។ ដូច្នេះ ដើម្បីធានាឱ្យបាននូវការបង់ប្រាក់ពិន័យ មានវិធានការពីរយ៉ាងដែលអាចលើកយកមកអនុវត្តបាន គឺ ការរឹបអូស និងការបង្ខំដល់រូបកាយ។ ជាគោលការណ៍ វិធានការបង្ខំដល់រូបកាយ ត្រូវអនុវត្តទោសទៅតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌចាប់ពីមាត្រា ៥២៣ រហូតដល់មាត្រា ៥៣៣។ រីឯវិធានការរឹបអូសទ្រព្យសម្បត្តិវិញ ត្រូវអនុវត្តទៅតាមបទប្បញ្ញត្តិដូចដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។ គេសង្កេតឃើញថាក្រមនីតិវិធីព្រហ្មទណ្ឌមិនបានកំណត់អំពីការបង្ខំដល់រូបកាយ អាចធ្វើទៅបានលុះត្រាតែទណ្ឌិតមានចេតនាគេចវេសមិនព្រមបង់ប្រាក់ពិន័យ។ ក្នុងន័យនេះ អាចនាំឱ្យមានការបកស្រាយបានថា ការបង្ខំដល់រូបកាយដើម្បីទាមទារប្រាក់ពិន័យអាចប្រព្រឹត្តទៅបាន បើទោះបីជាទណ្ឌិតលើកសំអាងថា ខ្លួនមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង់ប្រាក់ពិន័យក៏ដោយ[53]។ ក៏ប៉ុន្តែ ការបកស្រាយបែបនេះ នឹងធ្វើឱ្យមានការប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិរបស់បុគ្គលដែលមានជីវភាពក្រីក្រ ពីព្រោះថាពួកគាត់ពិតជាមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង់នូវប្រាក់ពិន័យពិតប្រាកដមែន ហើយទីបំផុតបែរជាត្រូវទទួលរងនូវការចាប់ដាក់ពន្ធនាគារដោយសារតែមូលហេតុនេះ។ ហេតុដូច្នេះថ្វីត្បិតតែក្រមនីតិវិធីព្រហ្មទណ្ឌមិនបានចែងយ៉ាងជាក់លាក់ តម្រូវឱ្យមានការគេចវេសដោយចេតនាក្នុងការបង់ប្រាក់ពិន័យ ដើម្បីអាចបង្ខំដល់រូបកាយបានក៏ដោយ ក៏គួរគប្បីកំណត់ជាយុត្តិសាស្ត្រនូវលក្ខខណ្ឌនេះ ដើម្បីធានាឱ្យមាននូវការគោរពសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់បុគ្គលដែរ[54]។

[53] នីតិព្រហ្មទណ្ឌទូទៅ, សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ ទំព័រ ៤៥១

[54] នីតិព្រហ្មទណ្ឌទូទៅ, សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ ទំព័រ ៤៤៨

ដោយឡែកក្នុងករណីនេះ ច្បាប់ក៏បានបញ្ញត្តិយ៉ាងជាក់លាក់ផងដែរថា ការបង្ខំដល់រូបកាយគឺមិនអាចអនុវត្តទៅលើទណ្ឌិតជាអនីតិជនបានឡើយនៅពេលដែលបានប្រព្រឹត្តបទល្មើស[55]។ មានន័យថា ការណ៍ដែលច្បាប់បានកំណត់បែបនេះ ព្រោះអាស្រ័យដោយហេតុថា អនីតិជនជាជនដែលស្ថិតនៅក្នុងវ័យមួយកំពុងមានការរីកលូតលាស់នៅឡើយ ប្រសិន បើអនុញ្ញាតឱ្យមានការអនុវត្តការបង្ខំដល់រូបកាយនោះ នឹងបង្កឱ្យមានការប៉ះពាល់ដល់ការវិវឌ្ឍន៍របស់ពួកគេជាមិនខាន។ លើសពីនេះទៅទៀត ក៏អាចបណ្តាលឱ្យពួកគេមាននូវស្លាកស្នាមអាក្រក់ជិតដាមជាប់ក្នុងអារម្មណ៍ និងជះឥទ្ធិពលដល់ការរស់នៅ ព្រមទាំងការវិវឌ្ឍន៍របស់ពួកគេទៅថ្ងៃអនាគតផងដែរ។

សរុបសេចក្តីមក ការបង្ខំដល់រូបកាយ គឺក្នុងគោលបំណងបង្ខំឱ្យទណ្ឌិតបង់នូវប្រាក់ពិន័យ, ប្រាក់ពន្ធនីតិវិធី ក៏ដូចជាសំណង និងជម្ងឺចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណី ជាពិសេសធានាឱ្យបាននូវការអនុវត្តសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌឱ្យមានប្រសិទ្ធិភាព ចំពោះការបង្ខំដល់រូបកាយនេះក៏មានការយោគយល់ក្រោមរូបភាពមនុស្សធម៌ផងដែរ ។

[55] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៥៣១ ឆ្នាំ២០០៧

# ជំពូកទី៣
# បញ្ហាប្រឈម និងដំណោះស្រាយ

# ជំពូកទី៣

# បញ្ហាប្រឈម និងដំណោះស្រាយ

សិទ្ធិរបស់អនីតិជនត្រូវបានការពារក្រោមច្បាប់កម្ពុជា។ ក៏ប៉ុន្តែ ជាការកត់សម្គាល់ឃើញថា កម្ពុជាមិនទាន់មានការកំណត់ច្បាស់លាស់នូវច្បាប់ដោយឡែកណាមួយពាក់ព័ន្ធទៅនឹងសិទ្ធិកុមារនោះទេ។ បទប្បញ្ញត្តិច្បាប់នានាធ្វើការកំណត់ផ្សេងគ្នាទៅលើអនីតិជន ដែលត្រូវដកស្រង់ចេញមកពីក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ ថ្វីត្បិតតែមាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌរបស់កម្ពុជាមានការប្តេជ្ញាចិត្តពិតប្រាកដចំពោះ *"វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ"* ដល់អនីតិជន និងផ្តល់ការគូសបញ្ជាក់ផ្សេងគ្នាពីកិច្ចការពារដែលគួរត្រូវផ្តល់ដល់អនីតិជនពេលដែលប្រព្រឹត្តបទល្មើស។ ប៉ុន្តែវិធានការទាំងនោះ ហាក់បីដូចជានូវមានភាពខ្វះខាត់ និងការខ្វះចន្លោះនៅឡើយ ដោយសារវិធានទាំងអស់នេះមិនមានវិសាលភាពត្រូវអនុវត្តផ្អែកតាមមូលដ្ឋានក្រមនីតិវិធីព្រហ្មទណ្ឌ។ កត្តាទាំងនេះហើយ ធ្វើឱ្យមានបញ្ហាប្រឈមមួយចំនួននៅពេលដែលអនីតិជនបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។ បញ្ហាទាំងនោះមានដូចជា ការអនុវត្តទោសទៅលើអនីតិជនច្រើនពេក និងបញ្ហាទីពីរ គឺទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្នអនីតិជនលើសច្បាប់កំណត់ជាដើម។

បញ្ហារបស់អនីតិជន គឺជាប្រធានបទដែលកំពុងតែមានការចាប់អារម្មណ៍ជាច្រើនពីស្ថាប័នពាក់ព័ន្ធ និងសំណាក់ប្រជាពលរដ្ឋ ដោយសារថាសម័យបច្ចុប្បន្នអ្នកខ្លះត្រូវបានបណ្តុះបណ្តាល និងប្រឹងលូតលាស់ចេញផ្លែផ្កា ប៉ុន្តែទំពាំង ឬយុវជនខ្លះមិនប្រឹងប្រែងទេហើយថែមទាំងបំពុលសង្គមថែមទៀត។ កត្តាទាំងនេះវាបណ្តាលឱ្យមានបន្ទុកដល់ដើមឫស្សី ឬមនុស្សចាស់ ជាពិសេសរាជរដ្ឋាភិបាល និងតុលាការ ត្រូវរិះរកដំណោះស្រាយណាមួយដើម្បីជួយអប់រំ និងកែលម្អយុវជនឱ្យដើរបានត្រឹមត្រូវហើយអាចជួយដល់សង្គមជាតិ។ ជាក់ស្តែងបញ្ហារបស់យុវជនមិនអាចត្រូវបានទុកចោល និងមិនអើពើបាននោះទេ មិនថាទាំងស្ថាប័ននៃរាជរដ្ឋាភិបាល ស្ថាប័នតុលាការ និងសង្គមស៊ីវិលនោះទេ បានខិតខំស្វះស្វែងរកដំណោះស្រាយ ដើម្បីបង្វែរយុវជនដែលប្រព្រឹត្តបទល្មើសមកជាគាំទ្រដល់ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មអនីតិជនទៅក្នុងសង្គម និងសហគមន៍ ក៏ដូចជាការធានាការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់អនីតិជនដែលប្រព្រឹត្តបទល្មើស។

## ៣.១ បញ្ហាប្រឈម

តាមស្ថានភាពជាក់ស្តែងនៃសង្គមបច្ចុប្បន្ន នៅពេលកើតមានបទល្មើសណាមួយដែលមានចរិតលក្ខណៈធ្ងន់ធ្ងរជនដែលបានប្រព្រឹត្តបទល្មើសអាចនឹងត្រូវបានគេឃាត់ខ្លួនភ្លាមៗ ឬអាចសម្រេចឃុំខ្លួនជាដើម ដើម្បីធានាបាននូវសណ្តាប់ធ្នាប់ ឬកើតមានផលប៉ះពាល់កាន់តែធ្ងន់ធ្ងរជាងមុនពីអំពើល្មើសនោះ។ ក៏ប៉ុន្តែមិនមែនគ្រប់ពេលដែលមានបទល្មើសកើតឡើងការសម្រេចឃុំត្រូវតែធ្វើឡើងនោះទេពោលគេត្រូវសិក្សាទៅលើស្ថានភាព

នៃបទល្មើស ក៏ដូចជាស្ថានភាពជនដែលបានប្រព្រឹត្តបទល្មើសជាមុនសិន ដើម្បីជៀសវាងថាការសម្រេចឃុំខ្លួននោះនឹងអាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងសេរីភាពរបស់បុគ្គល ជាពិសេសបទល្មើសដែលទាក់ទងទៅនឹងជនជាប់ចោទជាអនីតិជនតែម្តង។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏គេសង្កេតឃើញថានៅតែមានបញ្ហាប្រឈមមួយចំនួនកើតមានចំពោះអនីតិជនពេលដែលបានប្រព្រឹត្តល្មើសនឹងច្បាប់ព្រហ្មទណ្ឌ។ បញ្ហាទាំងនោះមានដូចជា៖

***បញ្ហាទីមួយ*** គឺពាក់ព័ន្ធនឹងសវនាការធ្វើការជំនុំជម្រះរឿងក្តីអនីតិជន តុលាការភាគច្រើនគឺមិនសូវបានអនុវត្តទៅតាមគោលការណ៍មានចែងនៅក្នុងច្បាប់ជាតិ និងអន្តរជាតិនោះទេ ថាតើអនីតិជនទទួលបានសិទ្ធិអ្វីខ្លះពេលដែលខ្លួនជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ? ហើយទទួលបានការការពារអ្វីខ្លះពីច្បាប់? ជាពិសេសទាក់ទងនឹងសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដែលមានចែងនៅក្នុងមាត្រា ៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ កត្តាដែលខ្វះការពិចារណាបែបនេះ ធ្វើឱ្យមានរឿងក្តីមួយចំនួនពាក់ព័ន្ធនឹងអនីតិជន គឺមានការផ្តន្ទាទោសមានលក្ខណៈធ្ងន់ធ្ងរពេកបានធ្វើឱ្យប៉ះពាល់សល់សតិអារម្មណ៍របស់អនីតិជន និងធ្វើឱ្យអនីតិជនបាត់បង់នៅសិទ្ធិសេរីភាព ក៏ដូចជាឧត្តមប្រយោជន៍របស់អនីតិជន។

***បញ្ហាទីពីរ*** គឺទាក់ទងចំពោះការឃុំខ្លួនបណ្តោះអាសន្នលើអនីតិជន យើងឃើញថាអនីតិជនមួយចំនួនត្រូវបានអនុវត្តការឃុំខ្លួនបណ្តោះអាសន្នរងចាំពេលវេលាសវនាការ រហូតដល់ពេលណាមួយដែលចៅក្រមអាចកំណត់ពេលវេលាសវនាការជំនុំជម្រះ ហើយចៅក្រមរកឃើញថាអនីតិជននោះគ្មានទោសទើបធ្វើការដោះលែង។ ការធ្វើបែបនេះបានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ ក៏ដូចជាសេចក្តីថ្លៃថ្នូរ និងបង្កភាពអាម៉ាស់យ៉ាងខ្លាំងដល់អនីតិជន ពីព្រោះថាការដែលធ្វើឡើងនេះគឺមិនបានគិតដល់ប្រយោជន៍របស់អនីតិជន ជាពិសេសមិនបានគោរពទៅតាមគោលការណ៍ដែលច្បាប់បានចែងថា ការចាប់ខ្លួន ការឃុំខ្លួន ឬការដាក់ពន្ធនាគារកុមារ ត្រូវប្រើសម្រាប់តែវិធានការចុងក្រោយប៉ុណ្ណោះ ហើយសម្រាប់តែក្នុងរយៈពេលខ្លីបំផុតតាមតែអាចធ្វើទៅបាន។ ហើយមានអនីតិជនជាច្រើនត្រូវបានឱ្យជាប់ឃុំបណ្តោះអាសន្នអស់រយៈពេលរាប់ខែលើសការកំណត់នៃច្បាប់ដោយពួកគេមិនមានកាលបរិច្ឆេទច្បាស់លាស់ទាក់ទងនឹងសវនាការ ឬមិនមានជំនួយផ្នែកច្បាប់ ហើយអ្នកទាំងនោះមិនដឹងអំពីព័ត៌មានលម្អិតនៃបទចោទប្រកាន់មកលើខ្លួននោះទេ។[56]

សរុបសេចក្តីមកវិញ យើងអាចសន្និដ្ឋានបានថា ទោះបីជាច្បាប់បានចែងអំពីគោលការណ៍ការការពារសិទ្ធិជាច្រើនទាក់ទងនឹងអនីតិជន ក៏នៅតែមានការរំលោភបំពានសិទ្ធិមួយចំនួនកើតមានចំពោះអនីតិជន ពេលដែលពួកគេបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ទាំងដែលខ្លួនកំពុងតែស្ថិតនៅក្នុងវ័យកុមារភាពនៅឡើយ ដោយហេតុតែខ្វះការយល់ដឹងពីផ្នែកច្បាប់បានធ្វើឱ្យពួកគេប្រព្រឹត្តនូវអំពើដែលសង្គមមិនឱ្យតម្លៃ។ ហេតុដូច្នេះ ស្ថាប័ន

[56] សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្សលីកាដូ, របាយការណ៍សង្ខេបចេញផ្សាយ ខែតុលា ឆ្នាំ២០១៨

ដែលពាក់ព័ន្ធគួរតែមានវិធានការចំពោះរឿងក្តីដែលពាក់ព័ន្ធនឹងអនីតិជនយកមកធ្វើការជំនុំជម្រះ និងចាត់ការជាអាទិភាព ជាពិសេសរឿងក្តីអនីតិជនដែលជាប់ឃុំខ្លួនបណ្តោះអាសន្ន[57]។

### ៣.១.១ ការអនុវត្តទោសលើអនីតិជនច្រើនពេក

យើងឃើញថា កុមាមួយចំនួនដែលគាត់មិនបានយល់ច្បាស់ពីផលប៉ះពាល់ផ្នែករាង្គកាយ ប៉ះពាល់ផ្នែកច្បាប់។ អញ្ចឹងជំរុញឱ្យគាត់ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ដែលប្រាសចាកពីច្បាប់ដែលយើងបានចែង។ ទី២យើងឃើញថាកុមារ ដែលគាត់បានប្រព្រឹតបទល្មើសអីផ្សេងៗ អត្តសញ្ញាណរបស់គាត់មិនត្រូវបានលាក់បាំងទៅតាមសិទ្ធិដែលគាត់បានទទួលទេ។ ច្បាប់កម្ពុជាបានចែងពីការអនុវត្តពិសេសលើងអនីតិជន។ *ឧទាហរណ៍ ច្បាប់ស្តីពីយុត្តិធម៌អនីជនត្រូវបានអនុម័តនៅក្នុងឆ្នាំ ២០១៦ ដើម្បីការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។* លើសពីនេះទៀត អនីតិជនដែលរងការចោទប្រកាន់ទទួលបានសិទ្ធិ និងការជំនុំជម្រះដោយយុត្តិធម៌ដូចគ្នាទៅនឹងនីតិជនដែរ ព្រមទាំងមានការបន្ថែមដែលយោងតាមអាយុ ភាពចាស់ទុំ និងការអភិវឌ្ឍផ្នែកបញ្ញាស្មារតីរបស់ពួកគេ។ ជាពិសេស ការសួរដេញដោលសាក្សី និងជនជាប់ចោទត្រូវធ្វើឡើងក្នុងសវនាការអសាធារណៈ ដែលសាធារណជនមិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងគោលបំណងដើម្បីគោរពឯកជនភាពរបស់អនីតិជន។ ឧត្តមប្រយោជន៍របស់កុមារត្រូវតែយកចិត្តទុកដាក់ជាចម្បង នៅពេលដែលមានការបង្គាប់ ឬការដាក់ទោសលើអនីតិជនដែលត្រូវបានរកឃើញថាបានប្រព្រឹត្តល្មើសនឹងច្បាប់ព្រហ្មទណ្ឌ[58]។ ការជំនុំជម្រះរឿងក្តីអនីតិជនត្រូវធ្វើឡើងនៅចំពោះមុខ "ទីប្រឹក្សាច្បាប់ ឬជំនួយសមស្របផ្សេងទៀត" និងឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់កុមារ[59]។ ហើយម្យ៉ាងវិញទៀត អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារបានចែងថា ការដាក់ទោសពន្ធនាគារទៅលើអនិតិជន ត្រូវតែធ្វើឡើងសម្រាប់តែវិធានការចុងក្រោយ និងត្រូវបានប្រើសម្រាប់តែករណីពិសេសប៉ុណ្ណោះ[60]។ ក្រមព្រហ្មទណ្ឌរបស់កម្ពុជាគោរពតាមបទប្បញ្ញត្តិនេះដោយលើកកម្ពស់វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ជាជាងវិធានការឃុំឃាំង។ ប៉ុន្តែប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវតុលាការអាចប្រកាសព្រហ្មទណ្ឌកម្មបាន[61]។ មាត្រា ៤០ នៃក្រមព្រហ្មទណ្ឌកម្ពុជាក៏អនុញ្ញាត ឬក៏ឱ្យមានវិធានការដទៃទៀតក្រៅពីទោសពន្ធនាគារ ដូចជាវិធានការការពារតាមផ្លូវតុលាការដោយការប្រគល់អនីតិជនទៅឱ្យសេវាសាធារណៈ ឬអង្គការឯកជនដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន។

[57] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៤៥ ឆ្នាំ២០១៦

[58] អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ, មាត្រា ៣ (១)

[59] អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ, មាត្រា ៤០ (ខ) (iii)

[60] អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ, មាត្រា ៣៧ (ខ)

[61] ក្រមព្រហ្មទណ្ឌ, មាត្រា ៣៩ ឆ្នាំ២០០៩

យើងឃើញថាទាំងបទដ្ឋានជាតិ និងអន្តរជាតិ គឺបានចែងអំពីការការពារសិទ្ធិ ក៏ដូចជាឧត្តមប្រយោជន៍របស់អនីតិជនយ៉ាងនេះក៏ដោយ ក៏គេនៅតែសង្កេតឃើញថា មានរឿងក្តីពាក់ព័ន្ធទៅនឹងអនីតិជនមួយចំនួនត្រូវបានធ្វើការជំនុំជម្រះនៅសាលាដំបូងរាជធានីភ្នំពេញ ក៏ដូចសាលាដំបូងនៅតាមបណ្តាខេត្តមួយចំនួនផ្សេងទៀត ហាក់បីដូចជាមិនសូវបានអនុវត្តទៅតាមគោលការណ៍ដែលមានចែងនៅក្នុងច្បាប់ជាតិ និងអន្តរជាតិនោះទេ។ គឺថាមានរឿងក្តីអនីតិជនមួយចំនួនត្រូវបានតុលាការធ្វើការជំនុំជម្រះ និងផ្តន្ទាទោសទៅលើអនីតិជនមានលក្ខណៈធ្ងន់ធ្ងរពេក។ កត្តាទាំងនេះហើយ បានធ្វើឱ្យមានបញ្ហាប្រឈមជាច្រើននៅពេលដែលមានរឿងក្តីទាក់ទងទៅនឹងអនីតិជន ជាពិសេសបានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ ក៏ដូចជាឧត្តមប្រយោជន៍របស់អនីតិជន ដែលផ្ទុយទៅនឹងអ្វីមានចែងនៅក្នុងច្បាប់ជាតិ និងអន្តរជាតិ។

***តាមរបាយការណ៍ និងទន្និ័យរបស់អង្គការមិនមែនរដ្ឋាភិបាល បានសង្កេតការណ៍ឃើញថា ការជនុំជម្រះរឿងក្តីលើអនីតិជននៅសាលាដំបូងរាជធានី ចន្លោះពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧ ដល់ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ ក្នុងសំណុំរឿងជិត ៣០០ ករណីគឺមានជនជាប់ចោទជិត ៤០០ នាក់ ក្នុងនោះមានសំណុំរឿង ៩ ដែលមានជនជាប់ចោទជាអនីតិជនចំនួន ១៤ នាក់។ មិនទទួលបានការអនុវត្តសិទ្ធិរបស់ពួកគេពេញលេញនោះទេ។ បញ្ហាទាំងនោះមានដូចជា ទីមួយ គ្មានវិធានការការពារឯកជនភាពរបស់អនីតិជន។ ទីពីរ ជនជាប់ជាអនីតិជនភាគច្រើនត្រូវឃុំខ្លួន។ ទីបី ខណៈពេលចន្លោះពីខែសីហា ឆ្នាំ២០១៧ ដល់ខែមីនា ឆ្នាំ២០១៨ មានបីភាគបួននៃអនីតិជនស្លៀកពាក់ឯកសណ្ឋានដូចគ្នាទៅនឹងទណ្ឌិត ដែលរំលោភលើការសន្មតទុកជាមុនថាគ្មានទោស។***[62]

***ឧទាហរណ៍:*** *ក្នុងខែមករា ឆ្នាំ២០១៤ មានការតវ៉ានានាបានកើតមានឡើងក្នុងរាជធានីភ្នំពេញពាក់ព័ន្ធទៅនឹងការទាមទារប្រាក់ឈ្នួលរបស់កម្មកររោងចក្រកាត់ដេរ។ ហើយក៏មានការបង្ក្រាបពីនគរបាលជាបន្តបន្ទាប់ដែលនាំឱ្យមានការចាប់ខ្លួនអ្នកតវ៉ាជាច្រើននាក់ មនុស្ស ២៦ នាក់ត្រូវបានសាលាដំបូងរាជធានីភ្នំពេញចោទប្រកាន់ និងកាត់ទោសពីបទ "**ហិង្សាដោយមានស្ថានទម្ងន់ទោស**" និងពីបទ "**ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស**"។ ជនជាប់ចោទមួយរូបក្នុងចំណោមជនជាប់ចោទទាំងនោះគឺជាអនីតិជនមានអាយុ ១៧ ឆ្នាំ។ អនីតិជនរូបនោះបានថ្លែងនៅពេលសវនាការថា ខ្លួនត្រូវបាននគរបាលវាយបាក់ដៃ ខ្លួនជឿថារបួសនោះធ្វើឱ្យគាត់មិនអាចត្រឡប់ទៅធ្វើការងារនៅរោងចក្របានវិញនោះទេ។ ចុងក្រោយអនីតិជននោះត្រូវបានតុលាការកាត់ទោសជាមួយមនុស្សពេញវ័យ ដោយគ្មានការពិចារណាច្បាស់លាស់ដល់អាយុរបស់គាត់។*

ដូច្នេះយើងឃើញថាការដែលតុលាការធ្វើការសម្រេចបែបនេះ គឺមិនបានពិចារណាទៅលើអាយុរបស់ជនជាប់ចោទ និងមិនបានពិចារណាទៅតាមគោលការណ៍ដែលមានចែងនៅក្នុងច្បាប់នោះទេ ជាពិសេសតុលាការ

[62] កំណត់ត្រាសង្ខេបកុមារនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ, ខែតុលា ឆ្នាំ២០១៤

បានធ្វើការកាត់ទោសគាត់ជាមួយនឹងមនុស្សពេញវ័យតែម្តង ដែលច្បាប់បានចែងថារឿងក្តីពាក់ព័ន្ធនឹងអនីតិជន ត្រូវធ្វើការជំនុំជម្រះដាច់ដោយឡែកពីនីតិជន និងជាអសាធារណៈ។ ហើយប្រសិនបើសំណុំរឿងនោះ ជនដែលពាក់ព័ន្ធមានទាំងនីតិជនផង និងអនីតិជនផង ព្រះរាជអាជ្ញាអាចសម្រេចចេញដីកាបំបែកសំណុំរឿងរវាងអនីតិជន និងនីតិជនឱ្យដាច់ដោយឡែកពីគ្នា។ ការដែលមិនបានពិចារណាបែបនេះ បានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងឧត្តមប្រយោជន៍របស់អនីតិជនជាច្រើន ជាពិសេសគឺមិនបានគោរពទៅតាមគោលការណ៍ដែលបានចែងនៅក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដែលកម្ពុជាបានផ្តល់សច្ចាប័នរួចហើយ។

### ៣.១.២ ការឃុំខ្លួនបណ្តោះអាសន្នអនីតិជនលើសច្បាប់កំណត់

បទដ្ឋានអន្តរជាតិបានហាមប្រាមយ៉ាងខ្លាំង ដល់ការឃុំខ្លួនជាបណ្តោះអាសន្នពាក់ព័ន្ធទៅនឹងអនីតិជនច្រើនជាងករណីពាក់ព័ន្ធជាមួយជនជាប់ចោទជាមនុស្សពេញវ័យ។ ក្នុងករណីភាគច្រើនផលប្រយោជន៍ល្អបំផុតសម្រាប់កុមារគឺត្រូវការពារពួកគេមិនឱ្យឃ្លាតចេញពីឪពុកម្តាយ។ ការឃុំខ្លួនកុមារក្នុងនោះ រួមទាំងក្រោយការឃុំខ្លួន និងនៅមុនពេលធ្វើការជំនុំជម្រះ គួរតែត្រូវបានចៀសវៀងតាមកាលៈទេសៈណាមួយដែលអាចធ្វើទៅបាន ហើយធ្វើឡើងតែក្នុងករណីវិធានការចុងក្រោយបង្អស់ក្នុងរយៈពេលសមរម្យខ្លីបំផុតប៉ុណ្ណោះ។

តាមទ្រឹស្តីច្បាប់ជាតិ និងនីតិវិធីរបស់កម្ពុជា បានផ្តល់កិច្ចការពារមួយចំនួនប្រឆាំងទៅនឹងការឃុំខ្លួនជាបណ្តោះអាសន្នទៅលើអនីតិជន។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាហាមប្រាមការឃុំខ្លួនបណ្តោះអាសន្នចំពោះជនទាំងឡាយណាដែលមានអាយុក្រោម ១៤ ឆ្នាំ។ ទោះបីជាមាត្រា ២១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌធ្វើការកំណត់ការឃុំខ្លួនជាបណ្តោះអាសន្នចំពោះជនទាំងឡាយណាដែលមានអាយុចន្លោះពី ១៤ ដល់ ១៨ នោះក្តីក៏មាត្រានេះមិនបានចែងឱ្យច្បាស់លាស់ពីការឃុំខ្លួនបណ្តោះអាសន្ននោះទេ[63]។

*យោងតាមទិន្នន័យរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល បានសង្កេតការណ៍ឃើញថា មានករណីចំនួន ៩៧% នៃអនីតិជនត្រូវបានគេដាក់ឱ្យស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន ករណីនេះច្បាស់ណាស់ថា ការរៀបចំយុត្តិធម៌អនីតិជនរបស់កម្ពុជាជាលក្ខណៈប្រព័ន្ធខកខានក្នុងការប្រតិបត្តិតាមច្បាប់អន្តរជាតិស្តីអំពីការឃុំខ្លួនបណ្តោះអាសន្ន។ ការដាក់ពន្ធនាគារទៅលើអនីតិជន ជាពិសេសអនីតិជនដែលមិនទាន់បានកាត់ទោស ត្រូវធ្វើឡើងតែក្នុងវិធានការចុងក្រោយបង្អស់តែប៉ុណ្ណោះ។ ការដែលថា ការឃុំខ្លួនបណ្តោះអាសន្នគឺរឿងធម្មតាសម្រាប់ជនជាប់ចោទជាអនីតិជនដែលមានចំនួនភាគច្រើនបំ ផុតនោះបង្ហាញពីបរាជ័យដ៏ធំធេងក្នុងការសន្មតពីភាពគ្មានទោស និងសិទ្ធិទទួលបានសេរីភាព។ ម្យ៉ាងវិញទៀត ករណីនេះកំពុងតែឱ្យសញ្ញាឃើញថាភាពរីករាលដាលនៃការឃុំខ្លួនបណ្តោះអាសន្នទៅលើអនីតិជន គឺបានកើនមានឡើងច្រើនជាងការឃុំខ្លួនបណ្តោះអាសន្នទៅលើមនុស្សពេញវ័យ*

[63] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា, ២១២, ២១៣ ឆ្នាំ២០០៧

*ក្នុងរយៈពេលសង្កេតសវនាការនៅសាលាដំបូងរាជធានីកន្លងមកនេះ គឺចន្លោះពីខែកក្កដា ដល់ ខែធ្នូ ឆ្នាំ ២០១១ ដោយ ៩៥% នៃអនីតិជនពាក់ព័ន្ធក្នុងសំណុំរឿងត្រូវបានគេដាក់ឱ្យស្ថិតនៅក្នុងការឃុំខ្លួនបណ្ដោះអាសន្ន ដោយមនុស្សពេញវ័យមានតែ ៧០% ហើយចន្លោះពីខែមករា ដល់ ខែមិថុនា ឆ្នាំ២០១២ ការឃុំខ្លួនបណ្ដោះអាសន្នទៅលើអនីតិជនមាន ៩១,៥% ខណៈដែលការឃុំខ្លួនបណ្ដោះអាសន្នទៅលើមនុស្សពេញវ័យមាន ៧១%*[64]។

ទិន្នន័យស្ដីពីអនីតិជនស្ថិតនៅក្នុងការឃុំខ្លួនបណ្ដោះអាសន្ន បង្ហាញថាប្រព័ន្ធយុត្តិធម៌មិនបានអនុវត្តឱ្យបានពេញលេញនូវប្រព័ន្ធយុត្តិធម៌អនីតិជន ទាក់ទងទៅនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នោះទេ ព្រោះសិទ្ធិទាំងនេះពាក់ព័ន្ធយ៉ាងជាក់លាក់ជាមួយកុមារ។ ករណីនេះប្រហែលជាបង្ហាញពីកង្វះខាតផ្នែកធនធានសង្គម និងរចនាសម្ព័ន្ធ ហើយគាំទ្រឱ្យមានជម្រើសផ្សេងជំនួសវិញដើម្បីជួយសម្រួលដល់ការសន្មតថាអនីតិជនមិនគួរត្រូវបានឃុំខ្លួនរហូតដល់ការជំនុំជម្រះឡើយ។

*ក្រោយពីបានចុះទៅសម្ភាសនៅសាលាដំបូងរាជធានីភ្នំពេញ មន្ត្រីតុលាការនៃសាលាដំបូងរាជធានីភ្នំពេញបានពន្យល់ដល់រូបខ្ញុំថា ហេតុផលសំខាន់មួយចំនួនក្នុងការកំណត់ការឃុំខ្លួនបណ្ដោះអាសន្នក្នុងករណីពាក់ព័ន្ធទៅនឹងជនជាប់ចោទជាអនីតិជន គឺដោយសារតែសភាពធ្ងន់ធ្ងរនៃបទល្មើស និងថាជនជាប់ចោទភាគច្រើនមិនមានអាស័យដ្ឋានពិតប្រាកដ ព្រមទាំងពុំមានធនធានគ្រប់គ្រាន់ដើម្បីឃ្លាំមើលការត្រួតពិនិត្យតាមផ្លូវតុលាការ។ សមាជិកចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ បានគូសបញ្ជាក់ឧទាហរណ៍របស់ជនជាប់ចោទដោយសំដៅទៅលើអាយុ និងការប្រព្រឹត្តបទល្មើស បន្ថែមជាហេតុផលនៅពីក្រោយក្រោយតួលេខខ្ពស់នៃការឃុំខ្លួនបណ្ដោះអាសន្នលើអនីតិជន។ នេះជារឿងសំខាន់ដែលចៅក្រមធ្វើសេចក្ដីសម្រេចលើការឃុំខ្លួនជាបណ្ដោះអាសន្ន ដោយបានអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលមិនបានបញ្ចូលនូវភាពធ្ងន់ធ្ងរនៃបទល្មើសជាលក្ខណៈវិនិច្ឆ័យមួយសម្រាប់កំណត់ការឃុំខ្លួនបណ្ដោះអាសន្ននោះ។*[65]

***ឧទាហរណ៍៖*** *ទាក់ទងទៅនឹងការជំនុំជម្រះនៅសាលាដំបូងរាជធានីភ្នំពេញនៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ ២០១២ ពាក់ព័ន្ធទៅនឹងអនីតិជនជាបងប្អូនបង្កើតចំនួនពីររូប។ អនីតិជនជាប្អូនមានអាយុ ១៤ ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើសដែលត្រូវបានកាត់ទោសពីបទចោរកម្មក្រោមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ហើយត្រូវបានតុលាការកាត់ទោសដាក់ពន្ធនាគាររយៈពេល ១ ឆ្នាំ។ អនីតិជនជាបង មានអាយុ ១៧ ឆ្នាំ ត្រូវបានកាត់ទោសពីបទទទួលផលចោរកម្មក្រោមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ និងត្រូវបាន*

[64] កំណត់ត្រាសង្ខេបរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ការអនុវត្តការឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងតុលាការកម្ពុជា, នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៣

[65] កិច្ចសម្ភាសនៅសាលាដំបូងរាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២១

*តុលាការកាត់ទោសដាក់ពន្ធនាគាររយៈពេល ២ ឆ្នាំ ដោយព្យួរទោសរយៈពេល ១ ឆ្នាំ។ មានការចោទប្រកាន់ថា ក្មេងប្រុសជាប្អូនបានលួចគ្រឿងអលង្ការពីផ្ទះនៅកន្លែងខ្លួនធ្វើការ ហើយបានប្រគល់គ្រឿងអលង្ការមានតម្លៃ ២៧០០ ដុល្លារនោះទៅបងប្រុសខ្លួនដើម្បីរក្សាទុក។ ឪពុកម្តាយរបស់ក្មេងៗទាំងនេះត្រូវបានតុលាការបង្គាប់ឱ្យសងជំងឺចិត្តចំនួន ២៦០០ ដុល្លារទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណី។*[66]

បើទោះបីជាការកាត់ទោសនោះ បានអនុលោមតាមលក្ខខណ្ឌតម្រូវទោសអប្បបរមាសម្រាប់កុមារនោះក៏ដោយ ក៏មានការព្រួយបារម្ភថាវិធីផ្សេងៗ នៃការកាត់ទោសមិនត្រូវបានគិតគូរនៅក្នុងអំឡុងពេលជំនុំជម្រះក្តី។ ករណីនេះគួរត្រូវបានលើកឡើងថា ការដាក់កុមារក្នុងពន្ធនាគារចំពោះបទមជ្ឈិមរយៈពេល ១ ឆ្នាំ គឺមិនសមស្រប និងសមហេតុផលទាល់តែសោះ ហើយជាការផ្ទុយទៅនឹងការចម្រើនលូតលាស់រយៈពេលយូរវែង និងសុខមាលភាពរបស់កុមារ។ ហើយអ្វីដែលផ្ទុយទៀតនោះ គឺផ្ទុយនឹងបទដ្ឋានជាតិ និងអន្តរជាតិបានចែងថា អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ។ ហើយម្យ៉ាងវិញទៀត "ការចាប់ខ្លួន ការឃុំខ្លួន ឬការដាក់ពន្ធនាគារកុមារ ត្រូវប្រើសម្រាប់តែវិធានការចុងក្រោយប៉ុណ្ណោះ ហើយសម្រាប់តែក្នុងរយៈពេលខ្លីបំផុតតាមតែអាចធ្វើទៅបាន"។

អនីតិជនជាប្អូនបានរត់គេចពីការចាប់ខ្លួន ហើយអវត្តមាននៅពេលជំនុំជម្រះក្តី។ ប៉ុន្តែ អនីតិជនបងត្រូវបានចាប់ខ្លួននៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១២ និងត្រូវស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេល ៥ ខែ រហូតដល់កាលបរិច្ឆេទនៃការជំនុំជម្រះក្តីនៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២។ ករណីនេះជាការព្រួយបារម្ភ ព្រោះថាមិនត្រឹមតែមិនគួរឃុំខ្លួននៅមុនពេលជំនុំជម្រះ ដែលត្រូវគិតថាជាជម្រើសចុងក្រោយបង្អស់ប៉ុណ្ណោះទេ ប៉ុន្តែរយៈពេលនៃការឃុំខ្លួននោះមិនគួរហួសរយៈពេល ៤ ខែ នោះដែរ។ ក្នុងករណីបទមជ្ឈិមចំពោះកុមារមានអាយុ ១៦ ដល់ អាយុ ១៨ ឆ្នាំ។ ក្នុងករណីការឃុំខ្លួនបណ្តោះអាសន្នមានរយៈពេលហួសចិរវេលាអនុញ្ញាត បង្ហាញថាជាការមិនគោរពទាំងស្រុងដល់សិទ្ធិរបស់កុមារ និងជាការរីករាលដាល ព្រមទាំងជារឿងសាមញ្ញជុំវិញការឃុំខ្លួននៅមុនពេលការជំនុំជម្រះរបស់តុលាការ។ បន្ថែមលើការព្រួយបារម្ភនោះ កុមារក្នុងតុលាការស្ថិតនៅក្នុងឯកសណ្ឋានពន្ធនាគារ ដោយបានរំលោភសិទ្ធិត្រូវបានសន្មតថាគ្មានទោសរបស់អនីតិជន[67]។ ករណីនេះបង្ហាញថាមិនត្រឹមតែមិនគោរពដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ទេ ប៉ុន្តែបង្ហាញឱ្យឃើញពីកង្វះខាតខាង

[66] កំណត់ត្រាសង្ខេបរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ការអនុវត្តការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងតុលាការកម្ពុជា, នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៣

[67] កំណត់ត្រាសង្ខេបរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ការអនុវត្តការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងតុលាការកម្ពុជា, នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៣

ការយល់ដឹងក្នុងចំណោមចៅក្រមទៅលើការថែទាំបន្ថែម និងឆន្ទានុសិទ្ធិដែលគួរត្រូវបានគេបង្ហាញដល់កុមារក្នុងពេលដំណើរការនីតិវិធីក្តី។

សច្ចធារណ៍នៃនិរទោស គឺជាគោលការណ៍ច្បាប់ជាមូលដ្ឋាន និងជាសិទ្ធិមួយ ដែលត្រូវបានការពារតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ នៅខណៈដែលមានពេលខ្លះ ជាចាំបាច់សម្រាប់តុលាការក្នុងការប្រើប្រាស់ការឃុំខ្លួនបណ្តោះអាសន្ន ដើម្បីជួយក្នុងការគ្រប់គ្រងយុត្តិធម៌ឱ្យបានត្រឹមត្រូវ ព្រមទាំងដើម្បីការពារដល់ជនរងគ្រោះ និងសាក្សី ការប្រើប្រាស់វិធាននៃការឃុំខ្លួនបណ្តោះអាសន្នដ៏ហួសហេតុ ក៏បានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការដែលត្រូវបានសន្មតទុកជាមុនថាគ្មានទោស ល្គឹកណាមិនទាន់បានផ្តន្ទាទោសជាស្ថាពរដោយតុលាការមិនលម្អៀង និងពេញសមត្ថភាពទេនោះ។

ក្រមនីតិវិធីព្រហ្មទណ្ឌមិនបានបញ្ញត្តិពីប្រព័ន្ធយុត្តិធម៌ដាច់ដោយឡែកសម្រាប់អនីតិជននោះទេ។ ដូច្នេះ បទប្បញ្ញត្តិដែលពាក់ព័ន្ធទៅនឹងការឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការគឺអនុវត្តដូចគ្នាលើជនត្រូវចោទជានីតិជន និងអនីតិជន។ ប្រការនេះ ពិតជាមានសារៈសំខាន់ចំពោះករណីរបស់អនីតិជន ដែលការឃុំខ្លួនត្រូវប្រើប្រាស់ជាវិធានការចុងក្រោយតែប៉ុណ្ណោះ។ ខណៈដែលភាពខុសគ្នាពុំមានចែងនៅក្នុងច្បាប់កម្ពុជារវាងនីតិជន និងអនីតិជន។ ពាក់ព័ន្ធនឹងការផ្តល់ការពិចារណាលើការឃុំខ្លួនបណ្តោះអាសន្ន ច្បាប់អន្តរជាតិចែងយ៉ាងច្បាស់ថា ការឃុំខ្លួនលើកុមារ រួមទាំងការឃុំខ្លួនបណ្តោះអាសន្ន គួរតែត្រូវចៀសវៀងនៅពេលណាដែលអាចធ្វើបាន។ ក្នុងហេតុផលដើម្បីការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ។

## ៣.២ ដំណោះស្រាយ

កម្ពុជាពិតជាមានក្របខ័ណ្ឌច្បាប់ចែងអំពីអនីតិជនក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដែលអនុលោមតាមវិសាលភាពច្បាស់លាស់នឹងបទដ្ឋានអន្តរជាតិ។ ប៉ុន្តែក្តីព្រួយបារម្ភជុំវិញច្បាប់នេះ និងនីតិវិធីសម្រាប់អនុវត្តទៅលើអនីតិជន។ ក្តីបារម្ភទាំងនេះ គឺស្ថិតក្នុងលក្ខណៈវិនិច្ឆ័យធំៗចំនួនពីរ។ ទីមួយ ដូចបានរៀបរាប់ខាងលើហើយ ច្បាប់ដែលកំពុងតែធរមានពុំទាន់មានលក្ខណៈគ្រប់គ្រាន់ ព្រមទាំងមានគម្លាតគ្នាក្នុងច្បាប់នោះដែលធ្វើឱ្យពុំមានប្រសិទ្ធភាព។ ទីពីរ កិច្ចការពារតាមច្បាប់ និងនីតិវិធីមិនត្រូវបានខ្ជាប់ខ្ជួនតាមការអនុវត្តជាក់ស្តែង។

កង្វះការកំណត់ផ្នែកវិធាននីតិវិធីដែលចែងច្បាស់លាស់អំពីអនីតិជន គឺជាកត្តារួមចំណែកសំខាន់មួយ។ ក្នុងចំណោមបទប្បញ្ញត្តិក្នុងព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌបានចែងសំដៅទៅលើអនីតិជនដែលភាគច្រើននៃបទប្បញ្ញត្តិទាំងនេះឱ្យនិយមន័យសង្ខេប និងទន់ខ្សោយចំពោះទង្វើដែលជាការណែនាំពិតប្រាកដដល់ការរៀបចំយុត្តិធម៌អនីតិជន។ ហេតុដូច្នេះ រដ្ឋាភិបាល ក៏ដូចស្ថាប័នតុលាការ គួរតែរកដំណោះស្រាយ និងកែទម្រង់ទៅលើប្រព័ន្ធច្បាប់មួយចំនួនដែលកំពុងតែអនុវត្តទៅលើអនីតិជនដូចជា៖

- រដ្ឋាភិបាលត្រូវធានាថា ពង្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជនត្រូវបានអនុម័តជារឿងអាទិភាព។ ច្បាប់ត្រូវតែដាក់បញ្ចូលការណែនាំឱ្យបានត្រឹមត្រូវពីរបៀបផ្តល់ការពិនិត្យនានាទៅលើអនីតិជន ***ឧទាហរណ៍ លើ*** *ភាពឯកជន ការអនុវត្តការឃុំខ្លួនបណ្តោះអាសន្ន។* នេះគួរតែមានការតស៊ូមតិដើម្បីឱ្យមានការអនុវត្តជម្រើសផ្សេងចំពោះទោសជាប់ឃុំ ផ្តោតសំខាន់លើការអប់រំ សមាហរណកម្ម និងនីតិសម្បទាហើយត្រូវបង្កើតឱ្យមានកិច្ចពិគ្រោះយោបល់ជាមួយអ្នកអនុវត្តច្បាប់ និងសង្គមស៊ីវិល។
- ចៅក្រមស៊ើបសួរ គួរតែធានាថា បទប្បញ្ញត្តិនានានៃច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដែលបង្កើតសច្ចធារណ៍រឹងមាំប្រឆាំងទៅនឹងការឃុំខ្លួនបណ្តោះអាសន្នទៅលើអនីតិជន ត្រូវបានប្រកាន់ខ្ជាប់ខ្ជួន។ ការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើឡើងតែក្នុងកាលៈទេសៈពិសេសប៉ុណ្ណោះ ជាវិធានការចុងក្រោយបង្អស់ និងក្នុងរយៈពេលខ្លីបំផុត។
- នៅមុនពេលកាន់សំណុំរឿង ឬករណីពាក់ព័ន្ធជាមួយអនីតិជនមកកាត់ទោស ចៅក្រម និងព្រះរាជអាជ្ញាគួរតែទទួលបានការបណ្តុះបណ្តាល ច្បាស់លាស់អំពីបញ្ហាពាក់ព័ន្ធនឹងយុត្តិធម៌អនីតិជន ការបណ្តុះ-បណ្តាលនេះគួរតែត្រូវអនុវត្តរួមគ្នាដោយក្រសួងយុត្តិធម៌ និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។
- ប្រសិនបើអាច នៅក្នុងតុលាការដែលមានបន្ទប់សវនាការច្រើន ពេលជំនុំជម្រះក្តីម្តងៗ គួរតែមានការរៀបចំបន្ទប់ដាច់ដោយឡែកដើម្បីធ្វើឱ្យដាច់ស្រឡះជាមួយករណីពាក់ព័ន្ធនឹងអនីតិជន។ ហាមការចូលរួមជាសាធារណៈ (ឪពុកម្តាយ/អាណាព្យាបាលរបស់ជនជាប់ចោទជាអនីតិជន) គួរត្រូវបានអនុញ្ញាត និងត្រូវធ្វើការរឹតត្បិតការធ្វើរបាយការណ៍នានា។ ក្នុងករណីមិនអាចរៀបចំបន្ទប់សវនាការដាច់ដោយឡែកបានទេនោះ សាធារណៈជនមិនត្រូវបានគួរអនុញ្ញាតឱ្យចូលរួមសវនាការនោះទេ ហើយឈ្មោះរបស់កុមារ ឬព័ត៌មានលម្អិតពីអត្តសញ្ញាណដទៃៗទៀត នឹងមិនត្រូវបានគេដាក់បង្ហាញនៅលើបញ្ជរផ្តល់ព័ត៌មាននោះឡើយ។
- អនីតិជនគ្រប់រូបមានសិទ្ធិមានមនុស្សពេញវ័យជាតំណាង (ឪពុកម្តាយ/អាណាព្យាបាល ឬបុគ្គលមាននីតិសម្បទាមានអាយុលើសពី១៨ឆ្នាំ) ក្នុងកំឡុងពេលសាកសួររបស់នគរបាល និងនៅគ្រប់សវនាការតុលាការ។
- ការកាត់ទោសទៅលើអនីតិជនត្រូវតែមានជម្រើសច្រើនយ៉ាង។ ក្រសួងយុត្តិធម៌ គាំទ្រដោយក្រសួងសង្គមកិច្ច គួរតែអនុវត្តនូវសំណុំនៃគោលការណ៍ណែនាំស្តីពីការកាត់ទោសពាក់ព័ន្ធនឹងអនីតិជន តាមរយៈការផ្តោតការយកចិត្តទុកដាក់ឱ្យបានខ្លាំងទៅលើនីតិសម្បទា ជាជាងការផ្តន្ទាទោសតែម្យ៉ាង។ ការដាក់ពន្ធនាគារកុមារត្រូវតែបញ្ចៀសនៅគ្រប់កាលៈទេសៈទាំងអស់ ហើយគួរតែត្រូវបានអនុវត្តតែក្នុងករណី

ធ្ងន់ធ្ងរបំផុតតែប៉ុណ្ណោះ ក្នុងករណីទម្រង់នៃការកាត់ទោសដទៃៗ ទៀតត្រូវបានប្រើប្រាស់អស់លទ្ធភាព ហើយ ឬក្នុងករណីដាក់ពន្ធនាគារជាហេតុផលតម្រូវដើម្បីការពារសាធារណៈជន។

- ក្រសួងយុត្តិធម៌ និងក្រសួងសង្គមកិច្ច គួរតែអនុវត្តគម្រោងផ្សេងទៀត ដែលជនល្មើសជាអនីតិជនត្រូវទទួលបានការឧបត្ថម្ភ និងផ្តល់នីតិសម្បទានៅក្នុងសហគមន៍ដែលជាជម្រើសផ្សេងក្រៅពីការកាត់ទោសផ្លូវការ។ គម្រោងនេះត្រូវតែធ្វើឡើងនៅមុនដំបូងសម្រាប់អ្នកប្រព្រឹត្តបទល្មើសគ្រប់រូបលើកលែងតែបទល្មើសឧក្រិដ្ឋធ្ងន់ធ្ងរបំផុត។

### ៣.២.១ ការអនុវត្តទោសលើអនីតិជនគឺត្រូវធ្វើឡើងតាមលក្ខខណ្ឌច្បាប់

បទដ្ឋានអន្តរជាតិនានាទទួលស្គាល់ថា កុមារជាប់ចោទពីការរំលោភច្បាប់ព្រហ្មទណ្ឌ តម្រូវឱ្យមានការថែទាំ និងផ្តល់កិច្ចការពារជាពិសេស។ កុមារជាប់ចោទពីបទល្មើសព្រហ្មទណ្ឌមានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដូចគ្នានឹងមនុស្សពេញវ័យផងដែរ ព្រមទាំងទទួលបានកិច្ចការពារនានាបន្ថែមដើម្បីឆ្លុះបញ្ចាំងឱ្យឃើញថា កុមារខុសពីមនុស្សពេញវ័យក្នុងការវិវឌ្ឍន៍ផ្នែករាងកាយ និងផ្នែកសតិស្មារតី។ នៅពេលរៀបចំឱ្យមានយុត្តិធម៌ដល់អនីតិជនរដ្ឋត្រូវតែមាននីតិវិធីនានាដើម្បីធានាថា សិទ្ធិ និងកិច្ចការពារទាំងនេះត្រូវបានគេគោរពតាម និងធានាថា ផលប្រយោជន៍របស់កុមារត្រូវបានគេគិតគូរនៅគ្រប់ដំណាក់កាលទាំងអស់។

មាត្រា ៣ (១) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារចែងថា ផលប្រយោជន៍ល្អបំផុតរបស់កុមារត្រូវតែយកចិត្តទុកដាក់ជាចម្បង នៅពេលបង្គាប់ ឬកំណត់ទោសទៅលើអនីតិជនដែលរកឃើញថាបានរំលោភបំពាន់លើច្បាប់ព្រហ្មទណ្ឌ[68]។ មាត្រា ៣៧ (ខ) កំណត់ឱ្យតុលាការទទួលខុសត្រូវក្នុងការពិចារណាទៅលើការដាក់ពន្ធនាគារទៅលើអនីតិជន ជាវិធានការមួយចុងក្រោយបង្អស់ដែលត្រូវធ្វើឡើងក្នុងកាលៈទេសៈពិសេសតែប៉ុណ្ណោះ[69]។ ឯមាត្រា ៤០ បញ្ជាក់ថា ការថែទាំ ការណែនាំ ការបង្គាប់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ការប្រឹក្សាយោបល់ ការសាកល្បង ការចិញ្ចឹមបីបាច់ ការអប់រំ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងវិធីក្រៅពីនេះដើម្បីទទួលបានការថែទាំពីស្ថាប័ន គួរតែត្រូវបានធ្វើឡើងជាចម្បងជាជាងការដាក់ពន្ធនាគារ[70]។

ចំណែកឯបទដ្ឋានជាតិវិញ ចែងថា សិទ្ធិរបស់អនីតិជនត្រូវបានការពារក្រោមច្បាប់កម្ពុជា។ មាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌ ចែងថា អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ។ ឯច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៧ នៃច្បាប់នេះចែងថា «នីតិភាពនៃការ

[68] អនុសញ្ញាស្តីពីសិទ្ធិកុមារ, មាត្រា ៣ (១)

[69] អនុសញ្ញាស្តីពីសិទ្ធិកុមារ, មាត្រា ៣៧ (ខ)

[70] អនុសញ្ញាស្តីពីសិទ្ធិកុមារ, មាត្រា ៤០

ទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់ចាប់ពីអាយុ ១៨ ឆ្នាំ ឡើងទៅ[71]។ ចំណែកមាត្រា ១៣ ចែងថា «អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ បានប្រព្រឹត្តបទលហុ នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការអប់រំណែនាំ ព្រមានដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ រួចហើយប្រគល់អនីតជននោះទៅតំណាងដែលច្បាប់បានកំណត់ជាបន្ទាន់»[72]។ ច្បាប់នោះចែងទៀតថា «អនីតិជនមានអាយុក្រោម ១៤ ឆ្នាំ ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើសពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែប្រគល់អនីតិជននោះទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់»[73]។ បន្ថែមពីលើនេះផងដែរ មាត្រា ២៣ បានចែងបន្តទៀតថា «មន្ត្រីនគរបាលយុត្តិធម៌ មិនត្រូវយកអនីតិជនដាក់បង្ហាញមុខជាជួរឡើង ក្នុងករណីដែលគ្មានការយល់ព្រមជាមុនពីអនីតិជន។ អនីតិជនដែលត្រូវឃាត់ខ្លួនត្រូវដាក់ដាច់ដោយឡែកពិនីតិជន និងទៅតាមភេទ។ អនីតិជនមិនត្រូវបានទទួលរងទារុណកម្ម ការបង្ខិតបង្ខំ ការគំរាមកំហែង ការសម្លុតបំភិតបំភ័យ ឬទង្វើណាមួយផ្សេងទៀតដែលនាំឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់អនីតិជន ឬទទួលរងអំពើអមនុស្សធម៌ណាមួយឡើយ»[74]។

សរុបសេចក្តីមកយើងថា ទាំងបទដ្ឋានជាតិ និងបទដ្ឋានអន្តរជាតិ គឺបានចែងអំពីគោលការណ៍ជាច្រើនដែលទាក់ទងទៅនឹងអនីតិជននៅពេលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។ ក៏ប៉ុន្តែ យើងឃើញថាទោះបីជាច្បាប់ជាតិ និងអន្តរជាតិបានចែងអំពីការការពារសិទ្ធិជាច្រើនចំពោះអនីតិជនដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌក៏ដោយក៏គេនៅតែសង្កេតឃើញថា មានរឿងក្តីពាក់ព័ន្ធនឹងអនីតិជនមួយចំនួននូវតែមានការរំលោភបំពានលើសិទ្ធិដែលបានផ្ទុយទៅនឹងគោលការណ៍មានចែងនៅក្នុងច្បាប់ជាតិ និងអន្តរជាតិ។

កត្តាទាំងនេះហើយទាមទារឱ្យស្ថាប័នពាក់ពន្ធទាំងអស់ មានដូចជាស្ថាប័នរដ្ឋាភិបាល ស្ថាប័នតុលាការក៏ដូចជាអង្គការសង្គមស៊ីវិល ត្រូវតែមានវិធានការ ឬដំណោះស្រាយ ដើម្បីចៀសវៀងកុំឱ្យមានការរំលោភបំពាន់មានភាពរាលដាលកាន់តែច្រើនឡើង ដែលផ្ទុយទៅនឹងលក្ខខណ្ឌមានចែងនៅក្នុងច្បាប់ជាតិ និងអន្តរជាតិ។ ហើយដំណោះស្រាយទាំងនោះរួមមានដូចជា ៖

- អនុម័តសេចក្តីព្រាងច្បាប់ស្តីពីអនីតិជនជារឿងអាទិភាព។
- ធ្វើវិសោធនកម្មច្បាប់ដែលមានស្រាប់ដើម្បីធានាដល់ការអនុវត្តត្រឹមត្រូវ។
- ការអនុវត្តទោសលើអនីតិជនត្រូវតែធ្វើឡើងតាមលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់។

[71] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៧ ឆ្នាំ២០១៦
[72] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ១៣ ឆ្នាំ២០១៦
[73] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ១៤ ឆ្នាំ២០១៦
[74] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ២៣ ឆ្នាំ២០១៦

- រៀបចំវគ្គបណ្តុះបណ្តាលដោយឡែកសម្រាប់ចៅក្រម និងព្រះរាជអាជ្ញានៅមុនពេលចៅក្រម និងព្រះរាជអាជ្ញាកាន់សំណុំរឿង ឬលើកយកករណីពាក់ព័ន្ធនឹងជនជាប់ចោទជាអនីតិជនមកកាត់ទោស។
- បង្កើតឱ្យមានបទប្បញ្ញត្តិដោយឡែកដែលត្រូវតាក់តែងឡើងជាពិសេសសម្រាប់តម្រូវការរបស់អនីតិជនដែលត្រូវផ្តោតសំខាន់លើការស្តារនីតិសម្បទា និងមិនមែនជាការដាក់ទណ្ឌកម្មទេ។
- ក្រសួងយុត្តិធម៌ គួរតែធ្វើកិច្ចសហការជាមួយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ សាលាចៅក្រម និងព្រះរាជអាជ្ញា គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងអង្គការស្ថាប័នខាងក្រៅ ដើម្បីផ្តល់វគ្គបណ្តុះ-បណ្តាលដល់ចៅក្រម និងមេធាវីអំពីបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌដែលមានផលប៉ះពាល់លើអនីតិជនជាពិសេសសច្ចធារណ៍ប្រឆាំងនឹងការផ្តន្ទាទោសដាក់ពន្ធនាគារនៅក្នុងមាត្រា ៣៩ និងទោសមិនមែនពន្ធនាគារជំនួសការដាក់ទោសពន្ធនាគារ។
- ផ្តល់ការបណ្តុះបណ្តាលឱ្យបានទូលំទូលាយដល់ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីអនុវត្តច្បាប់ទាំងឡាយស្តីពីបទប្បញ្ញត្តិថ្មីៗទាំងនេះ និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់អនីតិជន ដែលត្រូវបានធានាតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិ។
- ជំរុញចៅក្រម និងព្រះរាជអាជ្ញា ចេញដីកាបង្គាប់ឱ្យត្រួតពិនិត្យលើអនីតិជនដែលមិនមែនជាទោសពន្ធនាគារជាជាងការដាក់ឱ្យស្ថិតនៅក្នុងការឃុំខ្លួននៅពេលដែលសមរម្យ។
- យោងតាមច្បាប់ និងគោលការណ៍អន្តរជាតិ ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល គួរតែធានាថាតុលាការប្រតិបត្តិតាមការអនុវត្តខាងក្រោម នៅពេលដែលនីតិវិធីពាក់ព័ន្ធនឹងជនជាប់ចោទជាអនីតិជន៖
    - ការជំនុំជម្រះជាអសាធារណៈ
    - ការរៀបចំដោយឡែកសម្រាប់ការផ្តល់ភស្តុតាង ដូចជាការបង្ហាញតាមរយៈអេក្រង់
    - អនុញ្ញាតឱ្យមានសេចក្តីថ្លែងការណ៍តាមរយៈខ្សែអាត់វីដេអូ ពាក់ព័ន្ធនឹងភស្តុតាងរបស់កុមារ។
- ចៅក្រម គួរតែធានាថាការដាក់ពន្ធនាគារអនីតិជនជាមធ្យោបាយចុងក្រោយបង្អស់ និងប្រើជំនួសដោយបទប្បញ្ញត្តិផ្តន្ទាទោសថ្មីនៅក្នុងក្រមព្រហ្មទណ្ឌដោយការដាក់ទោសមិនមែនពន្ធនាគារ ដែលមានដូចជាការបំពេញការងារសហគមន៍ ការពន្យាពេលព្យួរទោសសាកល្បង ការដាក់ក្រោមវិធានការតាមដានអប់រំការពារ និងវិធានការឧបត្ថម្ភ ដែលមានចែងនៅក្នុងមាត្រា ៣៩ និងមាត្រា ៤០ នៃក្រមព្រហ្មទណ្ឌ។
- អង្គការមិនមែនរដ្ឋាភិបាល និងស្ថប័នឯកជន គួរតែស្វែងរកកិច្ចសហការជាមួយតុលាការ ក្រសួងយុត្តិធម៌ និងក្រសួងអប់រំយុវជន និងកីឡា ដើម្បីផ្តល់ការគាំទ្រ និងស្តារនីតិសម្បទាយុវជន ដែលបានប្រព្រឹត្តល្មើសច្បាប់ព្រហ្មទណ្ឌ ដោយផ្តល់មធ្យោបាយដែលអាចអនុវត្តបាន និងពិតប្រាកដ ផ្សេងពីការកាត់ទោសព្រហ្មទណ្ឌ និងដាក់ពន្ធនាគារ និងផ្តល់នូវវិធានការផ្សេងជំនួសឱ្យការចោទប្រកាន់។

### ៣.២.២ ការឃុំខ្លួនបណ្តោះអាសន្នអនីតិជនត្រូវតែធ្វើឡើងតាមការកំណត់នៃច្បាប់

ការឃុំខ្លួនបណ្តោះអាសន្ន ជានីតិវិធីមួយដែលធ្វើឡើងនៅមុនពេលជម្រះក្តី ក្នុងពេលដែលសំណុំរឿងព្រហ្មទណ្ឌស្ថិតនៅក្នុងដំណាក់កាលរបស់ចៅក្រមស៊ើបសួរ។ ការឃុំខ្លួនបណ្តោះអាសន្ន អាចធ្វើឡើងបានក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬមជ្ឈិមដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១ (មួយ) ឆ្នាំឡើងទៅ។

យោងតាមមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ការឃុំខ្លួនបណ្តោះអាសន្នអាចត្រូវបានបង្គាប់ កាលណាការឃុំខ្លួនបណ្តោះអាសន្ននេះជាការចាំបាច់[75] ៖

1. ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី។
2. ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។
3. ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ។
4. ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី។
5. ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ។
6. ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។

ជាទូទៅការឃុំខ្លួនបណ្តោះអាសន្ន អាចធ្វើឡើងតាមរយៈគំនិតផ្តើមពីចៅក្រមស៊ើបសួរ ឬតាមរយៈដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ដោយយោងតាមការពិចារណាការឈ្វេងយល់ដោយផ្ទាល់ទៅលើបុគ្គលិកលក្ខណៈ របស់ជនត្រូវចោទ ឬស្ថានភាពជាក់ស្តែងនៃបទល្មើសដែលបានប្រព្រឹត្ត។

នៅពេលដែលចៅក្រមស៊ើបសួរសម្រេចពីការឃុំខ្លួនបណ្តោះអាសន្ន នោះគឺត្រូវធ្វើឡើងតាមរយៈ *«ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន»* ដែលត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ ចំពោះថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ដាច់ដោយឡែកពីគ្នាទៅតាមស្ថានភាពនៃជនត្រូវចោទ (នីតិជន ឬអនីតិជន) ឬលក្ខណៈនៃបទល្មើស  (បទមជ្ឈិម ឬបទឧក្រិដ្ឋ)។ ក្នុងករណីជនត្រូវចោទជាអនីតិជនថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នត្រូវកំណត់ដូចខាងក្រោម៖

1) **មាត្រា ២១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា ចំពោះអនីតិជនមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋថិរវេលាឃុំខ្លួនបណ្តោះអាសន្នមានដូចតទៅ[76] ៖**

[75] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២០៥ ឆ្នាំ២០០៧

[76] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២១៣ ឆ្នាំ២០០៧

- ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៤ (បួន) ខែបានទេ កាលណាអនីតិជនមានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ។
- ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៦ (ប្រាំមួយ) ខែបានទេ កាលណាអនីតិជនមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។

2) **ចំណែកមាត្រា ២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងបន្តទៀតថា ចំពោះអនីតិជនមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ នឹងត្រូវបានចោទប្រកាន់ពីបទមជ្ឈិម ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នមាន ដូចតទៅ**[77] ៖

- ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ២ (ពីរ) ខែបានទេ កាលណាអនីតិជននេះមានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ។
- ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៤ (បួន) ខែបានទេ កាលណាអនីតិជននេះមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។

ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន តាមចំណុចទី (១) និងចំណុច (២) ខាងលើនេះ មិនត្រូវលើសពីពាក់កណ្តាលនៃអប្បបរមានៃទោស ដែលច្បាប់បានកំណត់សម្រាប់អនីតិជនោះឡើយ។ ចំពោះអនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំវិញ មិនអាចត្រូវបានឃុំខ្លួនបណ្តោះអាសន្នទេ។

ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននេះឱ្យឪពុកម្តាយ អ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអ្នកអាណាព្យាបាល ត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្តោះអាសន្នរង់ចាំសេចក្តីសម្រេចរបស់តុលាការ (មាត្រា ២១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) និងមាត្រា ៣៩ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន បានចែងថា អនីតិជនអាយុក្រោម ១៤ ឆ្នាំ មិនត្រូវបានឃុំខ្លួនបណ្តោះអាសន្នឡើយ។ ក្នុងករណីអនីតិជនដែលកំពុងជាប់ឃុំត្រូវរកឃើញថាមានអាយុក្រោម ១៤ ឆ្នាំ ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយ លើកលែងចោទប្រកាន់ និងបង្គាប់ឱ្យដោះលែងអនីតិជននោះជាបន្ទាន់ ទោះបីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់ ។

ដូច្នេះយើងអាចសន្និដ្ឋានបានថា ច្បាប់កម្ពុជារបស់យើងគឺបានផ្តល់កិច្ចការពារចំពោះអនីតិជនជាច្រើនទាក់ទងទៅនឹងការឃុំខ្លួនជាបណ្តោះអាសន្ន ជាពិសេសចំពោះថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន។ មូលហេតុដែលច្បាប់ចែងច្បាស់បែបនេះ គឺក្នុងគោលបំណងដើម្បីចៀសវាងការរំលោភបំពានសិទ្ធិលើអនីតិជន នៅពេលដែលអនីតិជនប្រព្រឹត្តល្មើសនឹងច្បាប់ ឬអាចនិយាយបានថាក្នុងគោលបំណងដើម្បីការពារឧត្តមប្រយោជន៍របស់

[77] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ២១៤ ឆ្នាំ២០០៧

អនីតិជន ធ្វើយ៉ាងណាកុំឱ្យមានការឃុំខ្លួនក៏ដូចជាការដាក់ពន្ធនាគារចំពោះពួកគេ ដោយប្រើប្រាស់នូវវិធានការផ្សេងក្រៅពីនេះ ដូចជា វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានឧបត្ថម្ភ។ ហើយម្យ៉ាងវិញទៀត គឺដើម្បីទទួលបាននូវការជំនុំជម្រះដោយយុត្តិធម៌ នៅពេលដែលមានរឿងក្តីពាក់ព័ន្ធនឹងអនីតិជន ជាពិសេសត្រូវគោរពតាមគោលការណ៍ដែលមានចែងនៅក្នុងច្បាប់ជាមូលដ្ឋាន។

ចំណែកឯបទដ្ឋានអន្តរជាតិវិញ គឺមិនជម្រុញឱ្យមានការអនុវត្តការឃុំខ្លួនបណ្តោះអាសន្នលើអនីតិជនឡើយ ទោះបីជាករណីនោះពាក់ព័ន្ធនឹងជនជាប់ចោទជានីតិជនក៏ដោយ។ ក្នុងករណីភាគច្រើន ផលប្រយោជន៍ដ៏ល្អបំផុតរបស់កុមារត្រូវបានការពារដោយមិនត្រូវបំបែកពួកគេឱ្យទៅឆ្ងាយពីឪពុកម្តាយ។ ការឃុំខ្លួនកុមារ រួមទាំងបន្ទាប់ពីការចាប់ខ្លួន និងមុនពេលសវនាការគួរតែត្រូវបានចៀសវាងតាមដែលអាចធ្វើទៅបាន និងគួរតែត្រូវបានប្រើជាវិធានការចុងក្រោយបង្អស់ក្នុងរយៈពេលមួយខ្លីសមល្មម។

តាមការបកស្រាយទាំងច្បាប់ជាតិ និងច្បាប់អន្តរជាតិខាងលើនេះ យើងអាចសន្និដ្ឋានបានថា ទាំងច្បាប់ជាតិ និងរួមទាំងច្បាប់អន្តរជាតិ គឺបានការពារសិទ្ធិ និងផលប្រយោជន៍របស់អនីតិជនជាច្រើន នៅពេលដែលអនីតិជននោះបានប្រព្រឹត្តបទល្មើសនឹងច្បាប់ព្រហ្មទណ្ឌ។ ក៏ប៉ុន្តែ ទោះបីជាច្បាប់ជាតិ និងអន្តរជាតិ បានចែងយ៉ាងនេះក៏ដោយ ក៏គេនៅតែសង្កេតឃើញថា មានការរំលោភបំពានសិទ្ធិលើអនីតិជនជាច្រើន នៅពេលដែលមានរឿងក្តីពាក់ព័ន្ធទៅនឹងអនីតិជន ជាពិសេសគឺនៅដំណាក់កាលជំនុំជម្រះ គេឃើញថាចៅក្រមជំនុំជម្រះ និងព្រះរាជអាជ្ញាភាគតិចណាស់ ដែលគោរពទៅគោលការណ៍ជាមូលដ្ឋានមានចែងនៅក្នុងច្បាប់។ ដូច្នេះហើយ គឺជាបញ្ហាប្រឈមមួយចំពោះអ្នកកាន់ច្បាប់ គួរតែរកវិធាននឹងដំណោះស្រាយបែបណា ដើម្បីធ្វើយ៉ាងណាកុំឱ្យមានរឿងបែបនេះកើតឡើងកាន់តែច្រើនឡើងនៅថ្ងៃខាងមុខ។ ដើម្បីចៀសវាងបញ្ហានេះ កើតមានឡើងជាបន្តបន្ទាប់ទៀត រដ្ឋាភិបាល និងក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ គួរតែមានដំណោះស្រាយមួយចំនួនដូចតទៅ៖

- ធានាថាការឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានតុលាការអនុវត្តឱ្យបានត្រឹមត្រូវ និងគួរតែជាមធ្យោបាយចុងក្រោយដោយយោងតាមគោលការណ៍សន្មតជាមុនថាគ្មានទោស។
- ធានាថាការឃុំខ្លួនបណ្តោះអាសន្ន អាចធ្វើឡើងតែក្នុងករណីពិសេសប៉ុណ្ណោះ ហើយជាវិធានការចុងក្រោយបង្អស់ និងមានចិរវេលាសមស្របខ្លីបំផុត។
- អនុវត្តន៍តាមដីកាបង្គាប់ឱ្យត្រួតពិនិត្យលើអនីតិជន ដែលផ្តោតសំខាន់លើការយកចិត្តទុកដាក់ការថែទាំ និងការឃ្លាំមើល ជាជម្រើសផ្សេងពីការឃុំខ្លួនបណ្តោះអាសន្ន និងដីកាបង្គាប់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។
- ចៅក្រមស៊ើបសួរ គួរតែធានាថាបទប្បញ្ញត្តិច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដែលបង្កើតសច្ចធារណ៍រឹងមាំប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជនត្រូវបានគោរព។ ការឃុំខ្លួនបណ្តោះអាសន្ន គួរតែ

ត្រូវបានយកមកអនុវត្តតែក្នុងករណីពិសេសប៉ុណ្ណោះ ហើយជាមធ្យោបាយចុងក្រោយបង្អស់ និងក្នុងរយៈពេលខ្លីសមស្របបំផុត។ ប្រព័ន្ធគ្រប់គ្រងទិន្នន័យដាច់ដោយឡែកសម្រាប់អនីតិជន ឬប្រព័ន្ធលេខកូដជាពណ៌ សម្រាប់ចងក្រងសំណុំរឿងដែលពាក់ព័ន្ធនឹងអនីតិជន គួរតែត្រូវបង្កើតឡើងដើម្បីជាការរំលឹកដល់ចៅក្រមអំពីភាពខុសគ្នារវាងការប្រព្រឹត្តទៅលើនីតិជន និងអនីតិជន។

- កម្រិតការឃុំខ្លួនបណ្ដោះអាសន្នរបស់អនីតិជនចំពោះករណីពិសេស នៅពេលដែលគ្មានជម្រើសដទៃទៀត និងធានាថាក្នុងករណីបែបនេះគ្រប់វិធានការចាំបាច់ត្រូវបានអនុវត្តដើម្បីគោរពសិទ្ធិរបស់អនីតិជនជាពិសេសត្រូវតែអនុវត្តទៅតាមគោលការណ៍ដែលមានចែងនៅក្នុងច្បាប់ ចំពោះចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នលើអនីតិជន។

# សេចក្ដីសន្និដ្ឋាន
# និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ ទៅលើប្រធានបទ "**ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជននៅសាលាដំបូងរាជធានីភ្នំពេញ**" រួចមក យើងឃើញថា អនីតិជននៅពេលបានប្រព្រឹត្តបទល្មើស គឺមិនអាចជៀសផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនោះឡើយ ពោលគឺអនីតិជននៅតែត្រូវទទួលខុសត្រូវទៅលើទង្វើដែលពួកគេបានប្រព្រឹត្តផ្ទុយទៅនឹងច្បាប់ ដូចទៅនឹងនីតិជនផងដែរ។ ប៉ុន្តែដោយហេតុផលថា អនីតិជនគឺស្ថិតនៅក្នុងដំណាក់កាលកំពុងវិវឌ្ឍន៍ ចម្រើនលូតលាស់ផ្នែកចិត្តគំនិត ប្រាជ្ញាស្មារតី ព្រមទាំងការគិតពិចារណារបស់ពួកគេនៅមានភាពក្មេងខ្ចីនៅឡើយ។ ដោយសារកត្តាទាំងអស់នេះ បានធ្វើឱ្យតុលាការមុននឹងធ្វើការជំនុំជម្រះលើរឿងក្តីអនីតិជន និងសម្រេចផ្តន្ទាទោសទៅលើពួកគេ ចាំបាច់ធ្វើការពិចារណាទៅលើចំណុចមួយចំនួន ដើម្បីអាចកំណត់បានថា តើអនីតិជននោះមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌហើយ ឬនៅ? ចំណុចទាំងនោះរួមមានដូចជា កត្តាអាយុ កាលៈទេសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈរបស់អនីតិជន។ ចៅក្រមក៏ដូចជាតំណាងអយ្យការត្រូវយកបញ្ហាទាំងនេះមកពិចារណាឱ្យបានល្អិតល្អន់ និងហ្មត់ចត់បំផុតមុននឹងធ្វើការសន្និដ្ឋានថា អនីតិជនត្រូវទទួលខុសត្រូវ ឬមិនទទួលខុសត្រូវព្រហ្មទណ្ឌ? ពីព្រោះថា ប្រសិនបើគ្មានការពិចារណាឱ្យបានល្អិតល្អន់ទេនោះ វាអាចនឹងមានផលអវិជ្ជមានចំពោះអនីតិជនទៅថ្ងៃអនាគត។

ក្នុងន័យនេះ គឺចង់ឱ្យតុលាការមុននឹងសម្រេចផ្តន្ទាទោសទៅលើអនីតិជន គួរតែគិតគូរឱ្យបានល្អិតល្អន់ទៅលើឧត្តមប្រយោជន៍របស់អនីតិជនជាសំខាន់ ស្របទៅតាមគោលការណ៍ដែលមានចែងនៅក្នុងបទដ្ឋានជាតិ និងអន្តរជាតិ ក៏ដូចជាលិខិតុបករណ៍អន្តរជាតិនានា។ ដែលកំណត់ថា អនីតិជនពេលដែលប្រព្រឹត្តបទល្មើសជាកម្មវត្ថុនៃវិធានការតាមដាន វិធានអប់រំ វិធានការការពារ និងវិធានឧបត្ថម្ភ។

ទោះបីជាយ៉ាងនេះក៏ដោយ ក៏គេមិនអាចឱ្យជនដែលបានធ្វើអំពើមិនគប្បីទៅលើជនដទៃឱ្យរួចផុតពីការទទួលទោសទណ្ឌបានឡើយ ពីព្រោះថាអំពើដែលគេបានធ្វើនោះគឺជាអំពើដែលផ្ទុយទៅនឹងច្បាប់ នឹងជាអំពើមួយដែលសង្គមមិនឱ្យតម្លៃ។ ហេតុដូច្នេះ គេត្រូវតែទទួលចំពោះការអនុវត្តទោសនៅក្នុងពន្ធនាគារ ឬមណ្ឌលកែប្រែណាមួយដែលច្បាប់បានកំណត់ គ្រាន់តែការអនុវត្តទោសចំពោះពួកគេគឺមានលក្ខណៈស្រាលជាងចំពោះជនជាទណ្ឌិតដទៃ។ ដោយហេតុផល ពួកគេគឺជាអនីតិជន ឬអនីតិភាពនៃទណ្ឌិតនេះឯង។

យើងឃើញថា ទោះបីជាច្បាប់បានការពារផលប្រយោជន៍ចំពោះអនីតិជន ក៏ដូចជាឧត្តមប្រយោជន៍ និងសិទ្ធិរបស់អនីតិជនជាច្រើនបែបនេះក៏ដោយ នៅតែមិនអាចចៀសផុតនៅបញ្ហាមួយចំនួនកើតឡើងដដែលចំពោះពួកគេ នៅពេលដែលអនីតិជនបានប្រព្រឹត្តល្មើសនឹងច្បាប់ព្រហ្មទណ្ឌ ដោយពួកគេប្រឈមទៅនឹងការផ្តន្ទាទោសច្រើនពេក ឬការឃុំខ្លួនបណ្តោះអាសន្នលើសការកំណត់នៃច្បាប់ជាដើម។ កត្តាទាំងអស់នេះ ទាមទារឱ្យស្ថាប័នពាក់ព័ន្ធទាំងអស់ គួរតែមានដំណោះស្រាយ និងធ្វើបែបណាដើម្បីចៀសវាងកុំឱ្យបញ្ហានេះកាន់តែកើត

មានឡើងទៀត។ ហើយម្យ៉ាងវិញ គឺដើម្បីឱ្យប្រជាពលរដ្ឋមានទំនុកចិត្តទៅលើប្រព័ន្ធយុត្តិធម៌នៅកម្ពុជាផង ថាស្ថាប័នតុលាការនៅកម្ពុជាពិតជាមានយុត្តិធម៌ពិតប្រាកដមែន។

បញ្ហាដែលបានរៀបរាប់ខាងលើ គឺសុទ្ធសឹងតែជាបញ្ហាចោទសំខាន់ ដែលរាជរដ្ឋាភិបាល និងស្ថាប័នតុលាការគួរយកចិត្តទុកដាក់ និងរកដំណោះស្រាយឱ្យបានឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន។ ពីព្រោះថាបញ្ហាទាំងអស់នេះ វាបានធ្វើឱ្យរាំងស្ទះដល់ការអនុវត្តច្បាប់ និងបញ្ញត្តិនានាដែលទាក់ទងទៅនឹងអនីតិជនឱ្យមានប្រសិទ្ធភាព។ ដូច្នេះ ដំណោះស្រាយដែលអាចយកទៅអនុវត្តនៅថ្ងៃខាងមុខមានដូចជា ៖

- បង្កើតឱ្យមានតុលាការអនីតិជន ដែលមានមន្ត្រីជំនាញធ្វើការលើរឿងក្តីដែលពាក់ព័ន្ធទៅនឹងអនីតិជន។
- ផ្សព្វផ្សាយច្បាប់ដែលពាក់ព័ន្ធទៅនឹងអនីតិជនឱ្យបានទូលំទូលាយ ទៅគ្រប់មជ្ឈដ្ឋានផ្សេងៗ ទាំងអាជ្ញាធរ និងប្រជាពលរដ្ឋ ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងស្រុកនានាឱ្យបានជ្រាបអំពីច្បាប់ស្តីពីយុត្តិធម៌អនីតិជន។
- នៅពេលមានរឿងក្តីពាក់ព័ន្ធទៅនឹងអនីតិជន ព្រះរាជអាជ្ញា និងចៅក្រមគួរតែពិចារណាប្រើប្រាស់នូវវិធានការតាមដាន វិធានការការពារ វិធានអប់រំ និងវិធានការឧបត្ថម្ភ ជាជាងប្រើនូវវិធានការឃុំខ្លួនទៅលើអនីតិជន ដើម្បីសម្រាប់ជាឧត្តមប្រយោជន៍ដល់អនីតិជន។
- មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែអនុវត្តនូវតួនាទី និងភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមច្បាប់កំណត់ ជាពិសេសក្នុងពេលដែលធ្វើការឃាត់ខ្លួន ចាប់ខ្លួន ឃុំខ្លួន និងការសួរចម្លើយទៅលើអនីតិជនជាដើម។
- រាល់ការឃុំខ្លួនបណ្តោះអាសន្ន និងការអនុវត្តទោសលើអនីតិជន ត្រូវតែប្រើប្រាស់ជាវិធានការចុងក្រោយ ហើយមានរយៈពេលខ្លីបំផុតតាមដែលអាចធ្វើទៅបាន។
- រឿងក្តីដែលពាក់ព័ន្ធនឹងអនីតិជន គួរតែអនុវត្តទៅតាមគោលការណ៍ដែលមានចែងនៅក្នុងបទដ្ឋានជាតិ និងអន្តរជាតិ ជៀសវាងចំពោះការរំលោភបំពាន់លើសិទ្ធិ។
- នៅតាមពន្ធនាគារនីមួយៗ ត្រូវតែយកចិត្តទុកដាក់ជាទីបំផុតចំពោះជនជាប់ឃុំជាអនីតិជន និងត្រូវដាក់ឱ្យនៅដាច់ដោយឡែកពីជនជាប់ឃុំជានីតិជន ដើម្បីជៀសវាងកុំឱ្យមានការរំលោភបំពាន និងកេងប្រវ័ញ្ចលើផ្លូវភេទ៕

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិជាតិ និងអន្តរជាតិ

1. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០២០៨/០០៨ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៨
2. អនុសញ្ញាស្តីពីសិទ្ធិកុមារ ឆ្នាំ២០០៩
3. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
4. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
5. ច្បាប់ស្តីពីពន្ធនាគារ ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១
6. ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៦

## សៀវភៅ និងអត្ថបទផ្សេងៗ

1. លោកសាស្ត្រាចារ្យ មីន សំអុល, នីតិព្រហ្មទណ្ឌទូទៅ, បោះពុម្ព ឆ្នាំ២០១៧
2. លោកសាស្ត្រាចារ្យ ហ៊ី សោភា, នីតិព្រហ្មទណ្ឌទូទៅ, បោះពុម្ព ឆ្នាំ២០១៦
3. លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ កែសម្រួលដោយលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, នីតិព្រហ្មទណ្ឌទូទៅ, បោះពុម្ព ឆ្នាំ២០១២
4. លោក កៅ សីហា, ព្រហ្មទណ្ឌទូទៅ, បោះពុម្ព ឆ្នាំ២០១៣
5. លោក កៅ សីហា, ទោសព្រហ្មទណ្ឌ, បោះពុម្ព ឆ្នាំ២០១១
6. កំណត់ត្រាសង្ខេបរបស់ ម.ស.ម.ក ការអនុវត្តការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងតុលាការកម្ពុជា ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៣
7. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្សលីកាដូ, របាយការណ៍សង្ខេបចេញផ្សាយ ខែតុលា ឆ្នាំ២០១៨

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្ត រាជធានី

សំណុំរឿងព្រហ្មទណ្ឌលេខ............

ចុះថ្ងៃទី..................................

សំណុំរឿងស៊ើបសួរលេខ..................

ចុះថ្ងៃទី..................................

លេខ[1]..................................

# ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន

យើង...............................ចៅក្រមស៊ើបសួរនៃសាលាដំបូង.........................អមដោយលោក/លោកស្រី.......................................ជាក្រឡាបញ្ជី។

- បានឃើញមាត្រា២០៣ ដល់មាត្រា២០៦ និងមាត្រាផ្សេងៗទៀត នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលទាក់ទងនឹងការឃុំខ្លួនបណ្ដោះអាសន្ន

- បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ...........ចុះថ្ងៃទី.......ខែ........ឆ្នាំ........... ដែលបានបើកការស៊ើបសួរលើ

ឈ្មោះ.............................ឈ្មោះហៅក្រៅ......................ភេទ.......ថ្ងៃខែឆ្នាំកំណើត.....................

សញ្ជាតិ...............មុខរបរ.........................មានអត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែនលេខ.....................:

កំរិតវប្បធម៌............................ទីកន្លែងកំណើតនៅភូមិ.........................ឃុំ/សង្កាត់.....................

ស្រុក/ខណ្ឌ.........................ខេត្ត/រាជធានី................................។

ទីលំនៅផ្ទះលេខ.......................ផ្លូវលេខ...................ភូមិ...........................ឃុំ/សង្កាត់......................

ស្រុក/ខណ្ឌ.......................រាជធានី/ខេត្ត................។

ឪពុកឈ្មោះ....................................រ☐ ស☐ ម្ដាយឈ្មោះ..................................រ☐ ស☐

ប្ដី/ប្រពន្ធឈ្មោះ.............................រ☐ ស☐ មានកូន......នាក់ ឬនៅលីវ☐ នីតិជន☐ អនីតិជន☐។

មុខរបរ.............................................

[1] លេខរបស់ដីកាសម្រេច

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ..............................................................................។
ជននេះត្រូវបានដាក់នៅក្រោមការពិនិត្យពីបទ..............................តាមមាត្រា..............................
នៃក្រមព្រហ្មទណ្ឌ/ច្បាប់...........................................................................................................។

ប្រព្រឹត្តនៅផ្ទះលេខ..............................ផ្លូវលេខ..............ភូមិ........................ឃុំ/សង្កាត់..................
ស្រុក/ខណ្ឌ..............................ខេត្ត/រាជធានី...............................................................................
កាលពីថ្ងៃទី..................ខែ..................ឆ្នាំ..............។

បានឃើញកំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង
បានឃើញកំណត់ហេតុស្តីពីការពិភាក្សាដេញដោល និងការកត់សម្គាល់របស់ភាគី

## I. ស្ថានភាពអង្គហេតុ និងអង្គច្បាប់

១ ក្នុងករណីបច្ចុប្បន្ន ជនត្រូវចោទឈ្មោះ ..........................ត្រូវចោទពីបទ..............................
(បញ្ចូលបទល្មើសដែលមានកំណត់នៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ............)

២. ប្រព្រឹត្តិនៅ...........................................................................................................................
(សង្ខេបអង្គហេតុនៃរឿង)

៣. តំណាងអយ្យការ បានស្នើឲ្យឃុំខ្លួន☐ មិនឲ្យឃុំខ្លួន☐ បណ្ដោះអាសន្នលើជនត្រូវចោទឈ្មោះ....................................ផ្អែកលើសំអាងហេតុដូចតទៅ......................................
...........................................................................................................................................
...........................................................................................................................................
...........................................................................................................................................

៤. ជនត្រូវចោទឈ្មោះ ....................................ឬមេធាវីការពារ ស្នើសុំ(កុំឲ្យ)នៅក្រៅឃុំបណ្ដោះអាសន្ន☐ ដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ☐ ដោយសំអាងហេតុផលថា
...........................................................................................................................................
...........................................................................................................................................
...........................................................................................................................................

## II. សំអាងហេតុនៃសេចក្ដីសម្រេច

៥. ជនត្រូវចោទឈ្មោះ....................................ត្រូវចោទពីបទឧក្រិដ្ឋ/មជ្ឈិម ដែលច្បាប់កំណត់ដាក់ពន្ធនាគារស្មើ ឬលើសពី ១(មួយ)ឆ្នាំ (មាត្រា២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

## <u>លិខិតបញ្ជូន</u>

យើង.................................បានប្រគល់ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលេខ..........
ចុះថ្ងៃទី........ខែ............ឆ្នាំ..........
ដល់ឈ្មោះខាងក្រោម នៅថ្ងៃទី........ខែ.........ឆ្នាំ...............

អ្នកប្រគល់

អ្នកទទួល

| | | |
|---|---|---|
| តំណាងអយ្យការ | មេធាវីជនត្រូវចោទ | ជនត្រូវចោទ |

**សំគាល់៖** *តាមរយៈការជូនដំណឹងនេះ ជនត្រូវចោទ ត្រូវបានប្រាប់ថា៖*

*ជនត្រូវចោទមានសិទ្ធិប្តឹងឧទ្ធរណ៍ និងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់ចៅក្រមស៊ើបសួរ ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៦៦៧ និងមាត្រា៦៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអមសាលាដំបូង
រាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ ៣២១០
ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៩
លេខ.៣៧៥/៣៧.. អ.យ.ក

# ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

**យើង កែវ សុធា ព្រះរាជអាជ្ញា នៃ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។**

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៣២១០ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩ របស់ឈ្មោះ ឈុន ណារី ។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

យល់ឃើញថា មានតម្រុយសន្និដ្ឋានថា:

១-នាមត្រកូល-នាមខ្លួន ស្រី សុធា ភេទប្រុស អាយុ ៦១ឆ្នាំ ជនជាតិខ្មែរ មុខរបរ ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន 7NG មានទីលំនៅបច្ចុប្បន្ននៅអាគារលេខ១២៤ ផ្លូវសម្តេចសុធារស ភូមិ១៥ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ជានីតិជន។

២-នាមត្រកូល-នាមខ្លួន ស្រី ចន្ទ ភេទប្រុស អាយុ ៣៨ឆ្នាំ ជនជាតិខ្មែរ មុខរបរ នាយកក្រុមហ៊ុន 7NG កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០២០២៥១១៨២ មានទីលំនៅបច្ចុប្បន្ននៅអាគារលេខ១២៤ ផ្លូវសម្តេចសុធារស ភូមិ១៥ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ជានីតិជន។

បានប្រព្រឹត្តដូចតទៅ[1]៖ កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៨ ឈ្មោះ ឈុន ណារី ភេទស្រី អាយុ ៣៨ឆ្នាំ បានទិញដីទំហំ ១ ហិកតា (១០.០០០ម៉ែត្រការ៉េ) បណ្តោយ ២០០ ម៉ែត្រ×ទទឹង ៥០ ម៉ែត្រ ដែលមានទីតាំងស្ថិតនៅភូមិព្រៃចាស់ ឃុំហៃហាស្ទិត ខាងជើងទល់ផ្លូវ៣០ ម៉ែត្រ ខាងកើត ខាងត្បូង និងខាងលិចទល់នឹងដីរបស់ឈ្មោះ ស្រី ចាន់ថា ដែលជាដីរបស់ក្រុមហ៊ុន 7NG ពីឈ្មោះ ស្រី ចន្ទ ដោយមានការទុកចិត្ត ឈ្មោះ ឈុន ណារី ពុំបានទាមទារប័ណ្ណកម្មសិទ្ធិពីឈ្មោះ ស្រី សុធា ដែលជាប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន 7NG នោះទេ គឺមានឯកសារត្រឹមតែលិខិតផ្ទេរសិទ្ធិកាន់កាប់ដីតែប៉ុណ្ណោះ។ នៅដើមឆ្នាំ២០១៩ នេះ ឈ្មោះ ឈុន ណារី មានបំណងធ្វើ

[1] សេចក្តីសង្ខេបអង្គហេតុ



អាស័យដ្ឋានៈ អាគារលេខ ២៥-២៧ ផ្លូវលេខ ២១៧.២១៣ សង្កាត់វាលវង់ ខណ្ឌ ៧ មករា, ភ្នំពេញ
Adress : #25-27, Street 217-213, Sangkat Vealvong, Khan 7makara, Phnom Penh, Cambodia
ទូរសារ-ទូរស័ព្ទ: (៨៥៥)-២៣ ៨៨ ២០ ៥៩
Fax-Phone : (855)-23 88 20 59

របងថ្ម រឹងមាំ ជុំវិញដីរបស់ខ្លួន ស្រាប់តែឈ្មោះ ស្រី សុធា និងឈ្មោះ ស្រី ចន្ទ ពុំមានដីដុំចក្នុងទីតាំងខាងលើឲ្យឈ្មោះ ឈុន ណារី ឡើយ។

អំពើខាងលើជាបទល្មើសៈ ឆបោក

ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០០៨-២០១៩ បទល្មើសដែលមានបញ្ញត្តិឲ្យផ្ដន្ទាទោស តាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌព្រះរាជណាចក្រកម្ពុជា។

បានឃើញ មាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ។

## សម្រេច

បើកការស៊ើបសួរលើអង្គហេតុខាងលើ និងស្នើសុំ៖

☑ *ដាក់ឲ្យស្ថិតក្រោមការពិនិត្យលើ[2]៖*

១-ឈ្មោះ ស្រី សុធា ភេទប្រុស អាយុ ៦១ឆ្នាំ ជនជាតិខ្មែរ *(ព្រាយុំ)*

២-ឈ្មោះ ស្រី ចន្ទ ភេទប្រុស អាយុ ៣៨ឆ្នាំ ជនជាតិខ្មែរ *(ព្រាយុំ)*

ពីបទៈ ឆបោក

ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០០៨-២០១៩ តាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

☑ *ដាក់ឲ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្ន [3] លើឈ្មោះខាងលើដើម្បីបង្ការ ឬបញ្ចប់បទល្មើស កុំឲ្យកើតឡើងជាថ្មី និងជាធានាឲ្យជនត្រូវចោទនុកជូនតុលាការចាត់ការតាមនីតិវិធី។*

ថ្ងៃ សុក្រ ១០រោច ខែស្រាពណ៍ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៩

ព្រះរាជអាជ្ញា

កែច~សុវណា

---

[2] ឈ្មោះជនត្រូវចោទ

[3] មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្នដែលមានចែងក្នុងមាត្រា ២០៥

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ : ០១[illegible]/០៤

# សារាចរ
# ស្តីពី
# ការអនុវត្តបទប្បញ្ញត្តិដាក់ជនត្រូវចោទឲ្យនៅក្រោម ការត្រួតពិនិត្យតាមផ្លូវតុលាការ

ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា បទប្បញ្ញត្តិ និងគោលការណ៍ស្តីពីការដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌចាប់ពីមាត្រា ២២៣ ដល់ មាត្រា ២៣០ មិនទាន់អនុវត្តឲ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ ដែលជាហេតុធ្វើឲ្យការអនុវត្តមិនទាន់បានល្អប្រសើរ។

ដើម្បីធានាការអនុវត្តបទប្បញ្ញត្តិ និងគោលការណ៍ទាំងនេះឲ្យមានប្រសិទ្ធភាព ក្រសួងយុត្តិធម៌សូមធ្វើការណែនាំដូចខាងក្រោម ៖

## ក-ចៅក្រមស៊ើបសួរ

១-គប្បីធានាឲ្យបាននូវការអនុវត្តតាមគោលការណ៍នេះ ដោយយកចិត្តទុកដាក់ឲ្យបានហ្មត់ចត់អំពីកាលៈទេសៈនៃបទល្មើស ឬ បុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ ឲ្យបានសមស្រប និងឲ្យមានតុល្យភាពទៅនឹងស្ថានភាពសង្គម ក្នុងការសម្រេចមិនឃុំខ្លួនជនត្រូវចោទ ហើយដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

២-ត្រូវគិតអំពីវិធានការនៃការត្រួតពិនិត្យ និងឃ្លាំមើលដើម្បីធានាថា ជនត្រូវចោទនឹងអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានត្រឹមត្រូវ។

ករណីនេះ ចៅក្រមស៊ើបសួរគប្បីចាត់តាំងបុគ្គលណាមួយដែលមានសមត្ថកិច្ច អាចជួយតាមឃ្លាំមើល និងធ្វើរបាយការណ៍ជូនព្រះរាជអាជ្ញាតាមការកំណត់។

ក្នុងករណីចាំបាច់ដើម្បីធានាដល់ការឃ្លាំមើលជនត្រូវចោទ គប្បីដាក់កាតព្វកិច្ចឲ្យជនត្រូវចោទចូលបង្ហាញខ្លួនតាមការកំណត់ នៅអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ដែលស្ថិតនៅជិតលំនៅដ្ឋានស្នាក់នៅជាក់លាក់ណាមួយរបស់ជនត្រូវចោទ។

៣-ត្រូវផ្តល់ដីកាសម្រេចដាក់ជនត្រូវចោទ ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនេះមួយច្បាប់ ឲ្យដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬគ្រប់បុគ្គលដែលត្រូវបានចាត់តាំងក្នុងមូលដ្ឋានដែលជនត្រូវចោទត្រូវទៅរស់នៅ ដើម្បីអនុវត្តកាតព្វកិច្ច ក្រៅពីជូនដំណឹងដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។

៤-ត្រូវណែនាំជនត្រូវចោទ ដែលត្រូវបានដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឲ្យយកដីកាសម្រេចនេះ ទៅបង្ហាញដល់ប្រធានអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬបុគ្គលដែលត្រូវបានចាត់តាំង ក្នុងមូលដ្ឋានដែលខ្លួនត្រូវទៅរស់នៅ។

៥-ត្រូវពិចារណាលើរបាយការណ៍ ឬព័ត៌មានរបស់អង្គភាព ឬបុគ្គលដែលត្រូវបានចាត់តាំងពាក់ព័ន្ធនឹងជនត្រូវចោទ ដើម្បីជាមូលដ្ឋានក្នុងការសម្រេចតាមបទប្បញ្ញត្តិ នៃមាត្រា ២២៧-២២៨-២២៩ និង ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ខ-ព្រះរាជអាជ្ញា**

១-គប្បីជានាឲ្យបាននូវការអនុវត្តតាមគោលការណ៍នេះ ដោយយកចិត្តទុកដាក់ពិនិត្យឲ្យបានហ្មត់ចត់អំពីកាលៈទេសៈនៃបទល្មើស ឬ បុគ្គលិកលក្ខណៈរបស់ជនត្រូវចោទឲ្យបានសមស្រប និងឲ្យមានតុល្យភាពទៅនឹងស្ថានភាពសង្គម ក្នុងការស្នើសុំដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

២-បន្ទាប់ពីទទួលបានដីកាបង្គាប់ ដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវចាត់វិធានការដូចខាងក្រោម ៖

-ណែនាំជនត្រូវចោទអំពីរបៀបដែលត្រូវអនុវត្តកាតព្វកិច្ច ដូចបានកំណត់ក្នុងដីកាបង្គាប់របស់ចៅក្រមស៊ើបសួរ

-ណែនាំដល់អង្គភាព ឬបុគ្គលដែលត្រូវបានចាត់តាំងដោយចៅក្រមស៊ើបសួរឲ្យត្រួតពិនិត្យ តាមដាននិងធ្វើរបាយការណ៍តាមការកំណត់ ។

៣-ក្នុងករណីចៅក្រមស៊ើបសួរ បង្គាប់ឲ្យជនត្រូវចោទទៅបង្ហាញខ្លួន នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ត្រូវបង្គាប់ទៅអង្គភាពនោះឲ្យចាត់វិធានការដូចខាងក្រោម ៖

-រៀបចំឲ្យមានសៀវភៅសម្រាប់ចុះវត្តមានជនត្រូវចោទ ដែលត្រូវមកបង្ហាញខ្លួនតាមការកំណត់របស់ចៅក្រមស៊ើបសួរ

-ចាត់ភ្នាក់ងាររបស់ខ្លួនឲ្យតាមឃ្លាំមើលសកម្មភាពរបស់ជនត្រូវចោទ ក្នុងការបំពេញកាតព្វកិច្ច

-ធ្វើរបាយការណ៍អំពីសកម្មភាពរបស់ជនត្រូវចោទ (វត្តមាន និងសកម្មភាព) ក្នុងការបំពេញកាតព្វកិច្ចតាមការកំណត់ជូនទៅព្រះរាជអាជ្ញា។

សូមលោក លោកស្រី ជាចៅក្រម ព្រះរាជអាជ្ញា គ្រប់ស្ថាប័នតុលាការ និងអយ្យការ ត្រូវអនុវត្តសារាចរនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែ[illegible] ឆ្នាំ២០១៤

អង្គ វង្សវឌ្ឍនា

<u>ចម្លងជូន ៖</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-តុលាការ និងមហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
-សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ : ០២.[illegible]/១៤

# សារាចរ
## ស្តីពី
## ការអនុវត្តបទប្បញ្ញត្តិ នៃការព្យួរទោសសាកល្បង

ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា បទប្បញ្ញត្តិ និងគោលការណ៍ស្តីពីការអនុវត្តរបបនៃការព្យួរទោសសាកល្បង ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌចាប់ពីមាត្រា ១១៧ ដល់ មាត្រា ១២៣ និងមាត្រា ១៦៥ មិនទាន់អនុវត្តឲ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ ដែលជាហេតុធ្វើឲ្យការអនុវត្តនៃការព្យួរទោសសាកល្បង មិនទាន់បានល្អប្រសើរ។

ដើម្បីអនុវត្តបទប្បញ្ញត្តិ និងគោលការណ៍ទាំងនេះឲ្យមានប្រសិទ្ធភាព ក្រសួងយុត្តិធម៌ សូមធ្វើការណែនាំដូចខាងក្រោម ៖

### ក-ចៅក្រមជំនុំជម្រះ

១-យោងតាមមាត្រា ១១៧ នៃក្រមព្រហ្មទណ្ឌ ចៅក្រមគប្បីត្រូវពិចារណាសម្រេចព្យួរសាកល្បងនៃទោស ឲ្យបានជាអតិបរិមានូវទោស ដែលបានសម្រេចដាក់ពន្ធនាគារ ក្នុងបទល្មើសមជ្ឈិម។

២-តុលាការត្រូវចេញសម្រង់សាលក្រមស្តារពរចំនួនបីច្បាប់។ ចំនួនពីរច្បាប់ប្រគល់ជូនព្រះរាជអាជ្ញា និងមួយច្បាប់ទៀតប្រគល់ឲ្យទៅទណ្ឌិតដើម្បីអនុវត្ត។

### ខ-ព្រះរាជអាជ្ញា

១-ត្រូវដឹកនាំសម្របសម្រួល ការអនុវត្តសេចក្តីសម្រេចព្យួរទោសសាកល្បងរបស់តុលាការគ្រប់ជាន់ថ្នាក់ ឲ្យមានប្រសិទ្ធភាព។

២-ត្រូវចាត់តាំងបុគ្គលនៅក្នុងមូលដ្ឋានដែលទណ្ឌិតរស់នៅ ឬ បំពេញកាតព្វកិច្ច ឲ្យតាមដានសកម្មភាពរបស់ទណ្ឌិត។ បុគ្គលដែលគប្បីចាត់តាំង ដូចជានគរបាលប៉ុស្តិ៍រដ្ឋបាល សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ មន្ត្រីទទួលបន្ទុកអប់រំ និងស្តារនីតិសម្បទា...។

៣-ត្រូវបង្គាប់ណែនាំដល់ទណ្ឌិត ឲ្យទៅបង្ហាញខ្លួននៅចំពោះមុខបុគ្គលដែលត្រូវបានចាត់តាំងឲ្យតាមដាន។

៤-ត្រូវប្រគល់សម្រង់សាលក្រម ឬ សម្រង់សាលដីកាស្ដាពរដល់បុគ្គលដែលត្រូវបានចាត់តាំងឲ្យតាមដានទណ្ឌិត និងធ្វើការដឹកនាំសម្របសម្រួលការអនុវត្ត។

៥-ក្នុងករណីចាំបាច់ ត្រូវបង្គាប់ទៅអង្គភាពនគរបាលយុត្តិធម៌ ឲ្យចាត់វិធានការជួយតាមដានរាល់សកម្មភាពរបស់ទណ្ឌិត និងត្រូវធ្វើរបាយការណ៍តាមការកំណត់ ពីការគត់សម្គាល់ឃើញរបស់ខ្លួនចំពោះសកម្មភាពរបស់ទណ្ឌិតជូនទៅព្រះរាជអាជ្ញា ដើម្បីស្នើសុំយោបល់ ឬ ចាត់វិធានការ។

សូមលោក លោកស្រី ជាចៅក្រម ព្រះរាជអាជ្ញា គ្រប់ស្ថាប័នតុលាការ និងអយ្យការ ត្រូវអនុវត្តសារាចរនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី..២២..ខែមករា.. ឆ្នាំ..២០១៤..

រដ្ឋមន្ត្រី

អង្គ វង្សវឌ្ឍានា

ចម្លងជូន ៖
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-តុលាការ និងមហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
-សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ០៣ អយក.សរ/១៤

## សារាចរ

## ស្តីពី

## ការអនុវត្តបទប្បញ្ញត្តិនៃ ការអនុវត្តទោសការងារសហគមន៍

ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា បទប្បញ្ញត្តិ និងគោលការណ៍ស្តីពីការអនុវត្តទោសការងារសហគមន៍ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌចាប់ពីមាត្រា ៧២ ដល់មាត្រា ៧៥ មាត្រា ៩៨ មាត្រា ១០១ ដល់ ១០៣ និងមាត្រា ១៦២ មិនទាន់អនុវត្តបានគ្រប់ជ្រុងជ្រោយនៅឡើយ ដែលជាហេតុធ្វើឲ្យការអនុវត្តទោសការងារសហគមន៍ មិនទាន់មានប្រសិទ្ធិភាព និងមិនទាន់មានភាពរលូន។

ដើម្បីធានាការអនុវត្តបទប្បញ្ញត្តិ និងគោលការណ៍ទាំងនេះឲ្យមានប្រសិទ្ធភាព ក្រសួងយុត្តិធម៌សូមធ្វើការណែនាំដូចខាងក្រោម ៖

### ក-ចៅក្រមជំនុំជម្រះ

១-គប្បីធានាឲ្យបាននូវការអនុវត្តតាមបទប្បញ្ញត្តិ និងគោលការណ៍ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌស្តីពីទោសការងារសហគមន៍ ចំពោះទណ្ឌិតណាដែលតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើ ៣ (បី) ឆ្នាំ ។

២-តុលាការត្រូវប្រគល់សម្រង់សាលក្រម ជូនព្រះរាជអាជ្ញាមួយច្បាប់ និងប្រគល់ឲ្យទៅទណ្ឌិតមួយច្បាប់។

### ខ-ព្រះរាជអាជ្ញា

១-ត្រូវសហការជាមួយអង្គការរដ្ឋ សមាគមន៍ ឬអង្គការមិនមែនរដ្ឋាភិបាល ដើម្បីកសាង និងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះនីតិបុគ្គល និងប្រភេទការងារ ដែលមានតម្រូវការផ្តល់ការងារឲ្យទណ្ឌិតធ្វើ។ បញ្ជីនេះត្រូវដាក់បង្ហាញជូនតុលាការដើម្បីជ្រើសរើសការងារ ឲ្យទណ្ឌិតដែលយល់ព្រមទទួលយក។

២-ការផ្តល់ការងារសហគមន៍ដល់អនីតិជន ត្រូវពិភាក្សាបន្ថែមជាមួយមន្ត្រីសង្គមកិច្ចអំពីការងារដែលមានលក្ខណៈជាការងារបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ។

៣-ត្រូវរៀបចំបែបបទនៃការអនុវត្តទោសការងារសហគមន៍ សម្រាប់នីតិបុគ្គលដែលទទួលទណ្ឌិតឲ្យធ្វើការងារ ដោយឲ្យនីតិបុគ្គលនោះ បំពេញនូវកាតព្វកិច្ចដូចតទៅ ៖

-ណែនាំដល់ទណ្ឌិតអំពីការបំពេញកាតព្វកិច្ច និងអប់រំទណ្ឌិតឲ្យយកចិត្តទុកដាក់ក្នុងការកសាងខ្លួនចូលក្នុងសង្គមវិញ

-គ្រប់គ្រងតាមដានសកម្មភាពរបស់ទណ្ឌិត ក្នុងពេលបំពេញកាតព្វកិច្ច

-ធ្វើរបាយការណ៍អំពីសកម្មភាពរបស់ទណ្ឌិតជូនដល់ព្រះរាជអាជ្ញា

-ត្រូវចុះហត្ថលេខាលើកំណត់ហេតុទទួលស្គាល់ អំពីការអនុវត្តការងាររបស់ទណ្ឌិត

៤-ត្រូវយកចិត្តទុកដាក់តាមដានត្រួតពិនិត្យការអនុវត្តការងាររបស់ទណ្ឌិតដែលមានដូចខាងក្រោម ៖

-គ្រប់គ្រង តាមដាន រក្សាទុករបាយការណ៍ កំណត់ហេតុអំពីការអនុវត្តការងារសហគមន៍

-តាមដានការអនុវត្តរបស់ទណ្ឌិតទៅតាមលក្ខខណ្ឌរបស់សាលក្រម

-ណែនាំទណ្ឌិតអំពីការអនុវត្តការងារសហគមន៍ និងកាតព្វកិច្ចដែលត្រូវអនុវត្ត

-ណែនាំដល់នីតិបុគ្គលដែលទទួលទណ្ឌិត អំពីបែបបទអនុវត្តការងារគ្រប់គ្រង

-ចេញដីកាសម្រេចបញ្ចប់ការអនុវត្តទោសរបស់ទណ្ឌិត ដែលបានអនុវត្តទោសការងារសហគមន៍ដោយជោគជ័យ។

សូមលោក លោកស្រី ជាចៅក្រម ព្រះរាជអាជ្ញា គ្រប់ស្ថាប័នតុលាការ និងអយ្យការ ត្រូវអនុវត្តសារាចរនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៤

រដ្ឋមន្ត្រី

អង្គ វង្សវឌ្ឍនា

ចម្លងជូន ៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-តុលាការ និងមហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
-សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

◆◆◆

ក្រសួងយុត្តិធម៌

លេខ ៦២០ កសល.គរ.ក/១៤

រាជធានីភ្នំពេញ,ថ្ងៃទី២៣ខែ មករា ឆ្នាំ២០១៤

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ជំរាបជូន**

**ឯកឧត្តម លោក ប្រធានសាលាដំបូងរាជធានី ខេត្ត**

**ឯកឧត្តម លោក លោកស្រី ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត**

**កម្មវត្ថុ ៖** ការដាក់ឲ្យប្រើរូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ។

តាមកម្មវត្ថុខាងលើ ខ្ញុំសូមជំរាបជូន ឯកឧត្តម លោក លោកស្រី ប្រធានសាលាដំបូងរាជធានី ខេត្ត ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត ជាកន្លងមកក្រសួងយុត្តិធម៌បានផ្ដល់នូវរូបមន្តនៃដីកាសំរេចឃុំខ្លួនបណ្ដោះអាសន្នប្រើប្រាស់សាកល្បង ឃើញថានៅមានការខ្វះចន្លោះដែលមិនអាចធានាបាននូវការជឿជាក់ពីសំណាក់សាធារណៈជន។ ដូច្នេះក្រសួងយុត្តិធម៌បានបង្កើតរូបមន្តថ្មីដែលអាចបង្ហាញពីតម្លាភាព និងគណនេយ្យភាពក្នុងការធ្វើសេចក្ដីសម្រេច ដែលអាចពង្រឹងនូវការជឿទុកចិត្តរបស់សាធារណៈជនលើប្រព័ន្ធតុលាការ។

ក្រសួងយុត្តិធម៌សូមធ្វើការណែនាំសម្រាប់ការបំពេញតាមចំណុចមួយចំនួន ដែលមាននៅក្នុងរូបមន្តនៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នតាមគំរូថ្មីនេះដូចតទៅ ៖

- នៅផ្នែកខាងដើមនៃរូបមន្តពុំមានអ្វីផ្លាស់ប្ដូរច្រើននោះឡើយ ហើយក៏ពុំមានអ្វីដែលពិបាកយល់ក្នុងការបំពេញនោះទេ។

នៅផ្នែកនេះ ចៅក្រមស៊ើបសួរត្រូវព្យាយាមសួរព័ត៌មានឲ្យបានច្រើនពាក់ព័ន្ធនឹងស្ថានភាពរស់នៅរបស់ជនត្រូវចោទ ដើម្បីជាមូលដ្ឋានក្នុងការសម្រេច ឃុំខ្លួន ឬ មិនឃុំខ្លួន ដូចជាជនត្រូវចោទ ជាអនីតិជន ជាស្ត្រីមានផ្ទៃពោះ ជាស្ត្រីមានកូនតូចៗនៅជាមួយ ដោយគ្មានអ្នកណាផ្សេងទៀតជួយមើលថែរក្សាកូនតូចៗទាំងនោះ ឬ ជនត្រូវចោទ ជាចាស់ជរា។ល។ ក្នុងស្ថានភាពបែបនេះបើអាចជៀសវាងបាន មិនគួរគប្បីសម្រេចឃុំខ្លួននោះឡើយ។

ដើម្បីធានាបានករណីខាងលើនេះ នៅក្នុងនីតិវិធីសួរដេញដោលចំពោះមុខគប្បីមានការចូលរួមពីតំណាងអយ្យការ ជនត្រូវចោទ និង ឬ មេធាវីជនត្រូវចោទ ដើម្បីបង្ហាញអំពីការអះអាងរបស់ពួកគេរៀងៗខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីគាំទ្រ ឬ ប្រឆាំងនឹងការសម្រេចឃុំខ្លួន។ នៅពេលបញ្ចប់ការសួរដេញដោលនេះ ចៅក្រមស៊ើបសួរត្រូវធ្វើការសម្រេចពីការឃុំខ្លួនបណ្ដោះអាសន្ន ឬ មិនឃុំខ្លួនបណ្ដោះអាសន្ន។ ប្រសិនបើសំរេចថាត្រូវឃុំខ្លួនបណ្ដោះអាសន្នចៅក្រមត្រូវចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នដោយប្រើគំរូតាមរូបមន្តថ្មីនេះ។

ការប្រើនីតិវិធីសួរដេញដោលបែបនេះ អាចឲ្យចៅក្រមស៊ើបសួរទទួលបាននូវអំណះអំណាងគ្រប់ជ្រុងជ្រោយក្នុងការសម្រេច ប្រកបដោយតម្លាភាព និងគណនេយ្យភាព ។

I. ស្ថានភាពអង្គហេតុ និងអង្គច្បាប់

1. ចំណុចលេខ១តូចនេះ: ចៅក្រមស៊ើបសួរត្រូវដាក់បញ្ចូលឈ្មោះបទល្មើសដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ។

2. ចំណុចលេខ២តូចនេះ: ចៅក្រមស៊ើបសួរត្រូវសរសេរសង្ខេបពីអង្គហេតុនៃរឿងក្តី។

3. ចំណុចលេខ៣តូចនេះ: ចៅក្រមស៊ើបសួរត្រូវសង្ខេបពីសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ២ឬ៣ បន្ទាត់ដាក់បញ្ចូល។ តើតំណាងអយ្យការមានសំអាងអ្វីខ្លះ ដែលស្នើសុំឲ្យឃុំខ្លួន ឬ មិនឲ្យឃុំខ្លួន ធ្វើយ៉ាងនេះដើម្បីបង្ហាញថា ចៅក្រមស៊ើបសួរបានពិចារណាទៅលើមូលហេតុដែលតំណាង អយ្យការបានលើកឡើង។

4. ចំណុចលេខ៤តូចនេះ: ចៅក្រមស៊ើបសួរត្រូវធ្វើសេចក្តីសង្ខេបពីការកត់សម្គាល់ ឬ ការអះអាង របស់ជនត្រូវចោទ ឬ មេធាវីរបស់ជនត្រូវចោទ២ឬ៣ បន្ទាត់។

II. សំអាងហេតុសេចក្តីសម្រេច ៖

5. ចំណុចលេខ៥តូចនេះ: ចៅក្រមស៊ើបសួរត្រូវតែប្រាកដថាជនត្រូវចោទ ជាប់ចោទពីបទឧក្រិដ្ឋ ឬ មជ្ឈិម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬ លើសពី១ឆ្នាំ (យោងតាមមាត្រា២០៤នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ អាស្រ័យហេតុនេះ: ចៅក្រមស៊ើបសួរត្រូវពិនិត្យមើលថាប្រសិនបើរកឃើញពិរុទ្ធភាព ក្រោយពេលសវនាការជនត្រូវចោទអាចទទួលទោសជាប់ពន្ធនាគារស្មើ ឬ លើសពី១ឆ្នាំ ឬ អត់។

6. ចំណុចលេខ៦តូច ចៅក្រមស៊ើបសួរ ត្រូវសរសេរនូវការយល់ឃើញរបស់ខ្លួនឆ្លើយតបទៅនឹងសំអាងហេតុនានា ដែលបានលើកឡើងដោយភាគីដូចជា តំណាងអយ្យការ ជនត្រូវចោទ ឬ មេធាវីរបស់ជនត្រូវចោទ។

ទន្ទឹមនេះ: នៅក្នុងចំណុចនេះដែរ ចៅក្រមស៊ើបសួរត្រូវបង្ហាញអំពីមូលហេតុនៃការឃុំខ្លួនចំនួនមួយ ឬ ច្រើនដែលមានចែងនៅក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយពន្យល់បង្ហាញពីសំអាងហេតុសំរប់គាំទ្រទៅនឹងមូលហេតុនីមួយៗ ដែលចៅក្រមស៊ើបសួរលើកឡើង ឬ មិនត្រូវយកមកអនុវត្ត ដែលមានជាអាទិ៍ដូចខាងក្រោម៖

ក. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនអាចបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី - តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងប្រព្រឹត្តបទល្មើស ដែលខ្លួនត្រូវចោទឬទេ? តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចបន្តប្រព្រឹត្តបទល្មើស ឬប្រព្រឹត្តបទល្មើសនោះជាថ្មីឬទេ?

ខ. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនអាចរាំងដល់ការគាបសង្កត់សាក្សី ឬជនរងគ្រោះ ឬរាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងជនសមគំនិត - តើមានហេតុផលសមរម្យ ដើម្បីជឿជាក់ថា ជនត្រូវចោទអាចគាបសង្កត់សាក្សី ឬជនរងគ្រោះដែរឬទេ? តើជនសមគំនិតនៅតែមានសេរីភាពឬទេ (មិនបារម្ភពីការត្រូវរ៉ូវគ្នាទេ ប្រសិនបើពួកគេត្រូវបានឃុំខ្លួន)?

គ. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចរាំងជនត្រូវចោទពីការធ្វើអោយខូចភស្តុតាង ឬ តម្រុយជាសម្ភារៈ - តើនៅតែមានភស្តុតាង ឬ តម្រុយជាសម្ភារៈ ដែលនគរបាលមិនទាន់មានដែរឬ ទេ? តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងរត់គេចខ្លួន ឬ បំផ្លាញភស្តុតាង ឬតម្រុយជាសម្ភារៈ ឧ: អាវុធពាក់ព័ន្ធនឹងបទល្មើសជាដើម?

ឃ. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចធានារក្សាវត្តមានជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី - តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងរត់គេចខ្លួន ឬភៀសខ្លួនទៅក្រៅប្រទេសដែរឬទេ?

ង. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចការពារសន្តិសុខឲ្យជនត្រូវចោទ - តើមានយោបល់ណាមួយដែលថាជនរងគ្រោះ ឬជនផ្សេងទៀតអាចចង់បង្កគ្រោះថ្នាក់ដល់ជនត្រូវចោទ ដែរឬទេ?

ច. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនជនត្រូវចោទ អាចរក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឲ្យមានភាពច្របូកច្របល់ណាមួយដែលបណ្តាលមកពីបទល្មើសនេះ។

ឆ. ចៅក្រមស៊ើបសួរក៏គួរពិចារណាពីធាតុផ្សំហានិភ័យជាសក្តានុពលដើម្បីជាយុត្តិកម្មដល់ការដាក់នរណាម្នាក់ក្នុងការឃុំជាបណ្តោះអាសន្ន ហើយក៏ពិចារណាផងដែរពីធាតុផ្សំដែលអាចបំបាត់ហានិភ័យនេះ ឧទាហរណ៍: ការងារជាប់លាប់នៅក្នុងសហគមន៍ ចំណងគ្រួសារជាដើម។ល។

នៅក្នុងផ្នែកចុងក្រោយនេះ ចៅក្រមស៊ើបសួរត្រូវធ្វើការសន្និដ្ឋានដោយកំណត់ឲ្យច្បាស់ នូវមូលហេតុមួយ ឬច្រើន ក្នុងចំណោមមូលហេតុទាំង៦ ដែលមានចែងក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនេះ ដើម្បីយកមកអនុវត្តចំពោះរឿងក្តីនេះ និងដើម្បីធ្វើយុត្តិកម្មដល់ការសំរេចរបស់ខ្លួនក្នុងការឃុំខ្លួន។ ក្នុងផ្នែកនេះ ចៅក្រមស៊ើបសួរត្រូវកំណត់ផងដែរ នូវមាត្រានៃក្រមនីតិវិធីព្រហ្មទណ្ឌដែលចែងអំពីថិរវេលាអតិបរមានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងករណីនេះ។ ថិរវេលានេះ អាស្រ័យលើចរិតលក្ខណៈនៃបទល្មើស និងអាយុរបស់ជនត្រូវចោទ (សូមពិនិត្យមើលតារាងខាងក្រោម)។ នៅទីបញ្ចប់ យោងតាមមាត្រា២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលចែងថា ជនត្រូវចោទត្រូវមានសេរីភាពនោះ ចៅក្រមត្រូវបង្ហាញថាគ្មានការដាក់កាតព្វកិច្ចណាមួយតាមរយៈការដាក់ឲ្យស្ថិតនៅ

ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ អាចនឹងមានលក្ខណ:គឹងរឹងគ្រប់គ្រាន់ ដើម្បីសម្រេចបាន គោលដៅនានា ដូចបានកំណត់នៅក្នុងផ្នែកខាងដើមនោះឡើយ។

ចៅក្រមស៊ើបសួរត្រូវសម្រេចផងដែរ ពីរយៈពេលអតិបរមានៃការឃុំខ្លួនបណ្តោះអាសន្ន ក្នុងករណីនេះ។ តារាងខាងក្រោមបង្ហាញពីថិរវេលាអតិបរមានៃការឃុំខ្លួនបណ្តោះអាសន្ន សំរាប់ ប្រភេទនីមួយៗនៃរឿងក្តី។

| ប្រភេទនៃបទល្មើស និង មាត្រានៃក្រមនីតិវិធី ព្រហ្មទណ្ឌពាក់ព័ន្ធ | អាយុជន ត្រូវចោទ | ថិរវេលាអតិបរមាដំបូងនៃការឃុំខ្លួន | ការពន្យារថិរវេលាឃុំខ្លួន តាមរយៈដីកាឃុំខ្លួន មួយទៀត |
|---|---|---|---|
| បទឧក្រិដ្ឋ - មាត្រា២០៨ | ១៨ឆ្នាំ ឬចាស់ជាងនេះ | ៦ខែ | ៦ខែ - ៦ខែ |
| បទមជ្ឈិម - មាត្រា២០៨ | ១៨ឆ្នាំ ឬចាស់ជាងនេះ | ៤ខែ | ២ខែ - ថិរវេលាសរុបមិនត្រូវលើសពីពាក់កណ្តាលអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ |
| បទឧក្រិដ្ឋ - មាត្រា២១៣ | ១៤ - ១៦ឆ្នាំ | ៤ខែ | មិនអាចពន្យារពេលឃុំខ្លួនបានឡើយ |
| បទមជ្ឈិម - មាត្រា២១៤ | ១៤ - ១៦ ឆ្នាំ | ២ខែ ឬ ១/២ នៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សំរាប់ អនីតិជន (ថិរវេលាមួយណាក៏បាន ដែលជាថិរវេលាខ្លីបំផុតរវាងថិរវេលាទាំង២នេះ) | មិនអាចពន្យារពេលឃុំខ្លួនបានឡើយ |
| បទឧក្រិដ្ឋ - មាត្រា២១៣ | ១៦ - ១៨ឆ្នាំ | ៦ខែ | មិនអាចពន្យារពេលឃុំខ្លួនបានឡើយ |
| បទមជ្ឈិម - មាត្រា២១៤ | ១៦ - ១៨ឆ្នាំ | ៤ខែ ឬ ១/២ នៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សំរាប់ អនីតិជន (ថិរវេលាមួយណាក៏បាន ដែលជាថិរវេលាខ្លីបំផុតរវាងថិរវេលាទាំង២នេះ) | មិនអាចពន្យារពេលឃុំខ្លួនបានឡើយ |

ចៅក្រមស៊ើបសួរគួរធ្វើការកត់សំគាល់ថា ក្នុងករណីបទមជ្ឈិម អប្បបរមានៃទោសត្រូវបន្ថយមកត្រឹមពាក់កណ្តាល ប្រសិនបើជនត្រូវចោទជាអនីតិជន នៅពេលប្រព្រឹត្តបទល្មើស (មាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ)។

ចៅក្រមស៊ើបសួរត្រូវចុះហត្ថលេខា និងចុះកាលបរិច្ឆេទលើដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

ផ្នែកបញ្ចប់នៃរូបមន្តនេះ គឺជាបង្កាន់ដៃដែលបញ្ជាក់ថាបានប្រគល់ - បុគ្គលដែលបញ្ជូនដីកានេះត្រូវតែចុះហត្ថលេខាលើដីកានេះ ដើម្បីបញ្ជាក់ថាដីកានេះត្រូវបានបញ្ជូនហើយ។ អ្នកទទួលត្រូវចុះហត្ថលេខាលើដីកានេះផងដែរ បន្ទាប់ពីបានទទួល។ ជនត្រូវចោទត្រូវបានគេប្រាប់ឲ្យដឹងអំពីសិទ្ធិប្តឹងឧទ្ធរណ៍របស់គេ និងពេលកំណត់ប្តឹងឧទ្ធរណ៍។

ទទួលបានការណែនាំនេះ សូមឯកឧត្តម លោក លោកស្រី ប្រធានសាលាដំបូង ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត ចាត់វិធានការអនុវត្តឲ្យមានប្រសិទ្ធភាព។

សូមឯកឧត្តម លោក លោកស្រី ប្រធានសាលាដំបូង ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត ទទួលនូវការរាប់អានអំពីខ្ញុំ ។

រដ្ឋមន្ត្រី

អង្គ វង្សវឌ្ឍនា

ជូនភ្ជាប់ :

- គំរូរូបមន្តដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ០១ច្បាប់

ចម្លងជូន :

- គុណាការកំពូល
- មហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍
- មហាអយ្យការអមសាលាឧទ្ធរណ៍

"ដើម្បីជូនជ្រាប"

**ព្រះរាជាណាចក្រកម្ពុជា**

អយ្យការអម　　　　　　ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្ត-ក្រុង　　　　　　*********

.........................

## ដីកាបង្គាប់ឱ្យចាប់ខ្លួន

លេខ..................　　　　　　********

យើង..............................................តំណាងអយ្យការអមតុលាការខេត្ត-ក្រុង............................................ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ .......................... ចុះថ្ងៃទី...........ខែ..............ឆ្នាំ.............................. ។

បានឃើញ.........................................................................................................................................

.........................................................................................................................................................

.........................................................................................................................................................

....................................................................................................................................................... ។

យល់ឃើញថា:-

ឈ្មោះ.......................................................... ភេទ........... អាយុ.............ឆ្នាំ ជាតិ..........................................

របររកស៊ី.................................... កើតនៅភូមិ..............................ឃុំ-សង្កាត់...........................................................

ស្រុក-ខណ្ឌ..................................... ខេត្ត-ក្រុង................................ ។ ទីលំនៅបច្ចុប្បន្នភូមិ...........................................

ឃុំ-សង្កាត់.............................ស្រុកខណ្ឌ............................ ខេត្ត-ក្រុង........................... ទោសពីមុន....................... ។

ឪពុកឈ្មោះ.........................................................."រ-ស" ម្ដាយឈ្មោះ....................................................................."រ-ស"

ប្ដីឬប្រពន្ធឈ្មោះ.............................."រ-ស" មានកូនឬនៅលីវ.................................... ។

ត្រូវចោទប្រកាន់ពីបទ...............................................................ប្រព្រឹត្តនៅភូមិ.................................................................

ឃុំ-សង្កាត់............................................ស្រុក-ខ័ណ្ឌ.........................................ខេត្ត-ក្រុង...............................................

កាលពីថ្ងៃទី................ខែ..........................ឆ្នាំ .................... តាមមាត្រា....................នៃច្បាប់.........................................

..........................................................................................................ហើយជននេះមានសាវតាជាតិគ្រប់គ្រាន់ ។

បង្គាប់ទៅភ្នាក់ងារមានសមត្ថកិច្ចឱ្យចាប់ខ្លួនឈ្មោះខាងលើនេះមកប្រគល់ជូន ព្រះរាជអាជ្ញា ដើម្បីចាត់ការតាមច្បាប់ ។

ធ្វើនៅ......................................... ថ្ងៃទី........ ខែ ...............ឆ្នាំ.........

**ព្រះរាជអាជ្ញា**

---

**កំណត់សំគាល់:**　　- លេខ និងថ្ងៃ ខែ ឆ្នាំ ដីកានេះយកចេញពីសៀវភៅចាប់ខ្លួន

- ដីកានេះចេញបានលុះត្រាតែជនល្មើសមានសាវតាជាតិគ្រប់គ្រាន់

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
**********

**អយ្យការអម**
តុលាការខេត្ត-ក្រុង
..........................
*********

# ដីកាបង្គាប់ឱ្យចូលខ្លួន(១)

********

លេខ ......................

យើង ................................................ តំណាងអយ្យការអម តុលាការខេត្ត-ក្រុង ..............................។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ .................. ចុះថ្ងៃទី ............. ខែ .................... ឆ្នាំ......................។

បានឃើញដីកាកោះលេខ.............. ចុះថ្ងៃទី .......... ខែ ............ឆ្នាំ ............... ដែលតំណាងអយ្យការបានចាត់ការតាមនីតិវិធីត្រឹមត្រូវរួចហើយ ប៉ុន្តែឈ្មោះនេះ មិនព្រមចូលខ្លួនមកបំភ្លឺនៅចំពោះមុខអយ្យការតាមកាលកំណត់ទេ ។

បង្គាប់មកឈ្មោះ ...................................... ភេទ.............. អាយុ ........... ឆ្នាំ ជាតិ ............................
ទីលំនៅបច្ចុប្បន្ន នៅភូមិ.......................ឃុំ-សង្កាត់ ................................ ស្រុក-ខណ្ឌ .......................................
ខេត្ត-ក្រុង ............................................ឱ្យចូលខ្លួនទៅកាន់អយ្យការអមតុលាការ ខេត្ត-ក្រុង ............................
នៅថ្ងៃទី............................ ខែ ............................ ឆ្នាំ ............................ វេលាម៉ោង ..................................
ដើម្បី .......................................................................................................................................................
......................................................................................................................................................។

ក្នុងករណីមិនចូលខ្លួនតាមកាលកំណត់ខាងលើនេះទេ ***យើងនឹងចេញដីកាបង្គាប់ឱ្យនាំខ្លួន*** ។

ធ្វើនៅ....................... ថ្ងៃទី......... ខែ.......... ឆ្នាំ ............

**ព្រះរាជអាជ្ញា**

យើង........................................ ជា ...........................................................................................

បានប្រគល់ដីកាបង្គាប់ឱ្យចូលខ្លួននេះដល់ឈ្មោះ.........................................ទីលំនៅបច្ចុប្បន្ននៅភូមិ...............
ឃុំ-សង្កាត់ ...........................ស្រុក-ខណ្ឌ .................................. ខេត្ត-ក្រុង ........................................
នៅថ្ងៃទី ........................ ខែ .................................. ឆ្នាំ ........................... ហើយយើងបានប្រាប់ថា
ឱ្យយកចុងដីកានេះទៅប្រគល់ដល់ក្រឡាបញ្ជី នៅពេលដែលខ្លួនចូលទៅចំពោះមុខអយ្យការអមតុលាការខេត្ត-
ក្រុង ...................................................... ។

ក្នុងករណីមិនចូលខ្លួនតាមកាលកំណត់ខាងលើនេះទេ យើងនឹងចេញដីកាបង្គាប់ឱ្យនាំខ្លួន ។

| **អ្នកទទួល** | **អ្នកប្រគល់** |
| --- | --- |
| ហត្ថលេខា ឬ ស្នាមមេដៃ | ហត្ថលេខា |

**កំណត់សំគាល់:** ˚១˚ អ្នកប្រគល់ដីកានេះ ក្រោយពីអ្នកទទួលដីកា បានចុះហត្ថលេខា ឬផ្តិតមេដៃលើដីកាទាំងពីរសន្លឹករួចហើយ ត្រូវប្រគល់សន្លឹក ˚ចុងដីកា˚ ទៅឱ្យអ្នកទទួល និងបង្វិលសន្លឹក ˚ដើមដីកា˚ ទៅអយ្យការអមតុលាការខេត្ត-ក្រុងវិញឱ្យបានមុនថ្ងៃកំណត់ក្នុងដីកា ។

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

*********

អយ្យការអម

តុលាការ ខេត្ត-ក្រុង

........................

*******

## ដីកាបង្គាប់ឱ្យនាំខ្លួន

*********

លេខ ..................

យើង............................................ តំណាងអយ្យការអមតុលាការខេត្ត-ក្រុង ............................................ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ............ ចុះថ្ងៃទី ................ខែ................. ឆ្នាំ........................។

បានឃើញ..........................................................................................................................................
.........................................................................................................................................................។

យល់ឃើញថា.....................................................................................................................................
.........................................................................................................................................................
.........................................................................................................................................................
.........................................................................................................................................................។

យល់ឃើញថា ដើម្បីធានាដល់ការកំណត់បទល្មើសឱ្យបានច្បាស់លាស់ គប្បីសំរេចនាំខ្លួនឈ្មោះ .................................. មកចំពោះមុខ តំណាងអយ្យការដើម្បីបំភ្លឺការពិត ក្នុងសំណុំរឿងក្តីនេះ ។

### ហេតុដូច្នេះ សម្រេច

បង្គាប់ឱ្យនាំខ្លួនឈ្មោះ.......................................................... ភេទ........... អាយុ..............ឆ្នាំ

ជាតិ.................... របររកស៊ី......................................................... ទីលំនៅបច្ចុប្បន្នភូមិ.........................................

ឃុំ-សង្កាត់................................................ ស្រុក-ខណ្ឌ............................... ខេត្ត-ក្រុង......................................

ដើម្បីសាកសួរយកពត៌មានផ្សេងៗ ទាក់ទងនឹងសំណុំរឿងព្រហ្មទណ្ឌខាងលើ ។

បង្គាប់មកលោក............................................ជា.......................................................................................
........................................................................................................ អនុវត្តដីកានេះ ឱ្យបានសម្រេច។

ធ្វើនៅ......................... ថ្ងៃទី......... ខែ................ ឆ្នាំ........

**ព្រះរាជអាជ្ញា**

**ព្រះរាជាណាចក្រកម្ពុជា**

**អយ្យការអម** ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្ត-ក្រុង **********

........................

*********** **ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ**

លេខ..................... ************

យើង.......................................... តំណាងអយ្យការអមតុលាការខេត្ត-ក្រុង ..................................... ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ.................... ចុះថ្ងៃទី............ ខែ ............ ឆ្នាំ ............. និងសំណុំលិខិតភ្ជាប់មកជាមួយ ព្រមទាំងភស្តុតាងនានា ។

សម្រេចផ្តើមចោទប្រកាន់ឈ្មោះ ......................................... ភេទ............ អាយុ ..........ឆ្នាំ ជាតិ........... របររកស៊ី....................................... ទីលំនៅបច្ចុប្បន្ននៅភូមិ..........................ឃុំ-សង្កាត់.................................. ស្រុក-ខណ្ឌ.............................................ខេត្ត-ក្រុង......................................ទោសពីមុន ......................... និងគូកន ។ ឪពុកឈ្មោះ............................................ "រ-ស" ម្តាយឈ្មោះ ........................................ "រ-ស" ប្តីឬប្រពន្ធឈ្មោះ...................................................."រ-ស"មានកូន ឬនៅលីវ ................................ ត្រូវជាប់ចោទពីបទ............................................................................... ប្រព្រឹត្តនៅភូមិ....................................................... ឃុំ-សង្កាត់........................... ស្រុក-ខណ្ឌ................................. ខេត្ត-ក្រុង............................................កាលពីថ្ងៃទី ......... ខែ ................ ឆ្នាំ ................... តាមមាត្រា................................................................ នៃច្បាប់ ........................................................................................................................................ ។

........................................................................................................................................

........................................................................................................................................

........................................................................................................................................ ។

........................................................................................................................................

........................................................................................................................................

........................................................................................................................................ ។

........................................................................................................................................

........................................................................................................................................

បញ្ជូនសំណុំរឿង វត្ថុតាង និងជនល្មើស "មានខ្លួន, គ្មានខ្លួន" ទៅចៅក្រមស៊ើបអង្កេត នៃតុលាការខេត្ត-ក្រុង ..... ................................................................ ដើម្បីចាត់ការតាមច្បាប់ និងស្នើសុំ ..............................................។

ធ្វើនៅ............................ ថ្ងៃទី........... ខែ................. ឆ្នាំ.............

**ព្រះរាជអាជ្ញា**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**********

**អយ្យការអម**

តុលាការខេត្ត-ក្រុង

..........................

**********

លេខ........................

## ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បទល្មើសថ្មីបន្ថែម

********

យើង...................................... តំណាងអយ្យការអមតុលាការខេត្ត-ក្រុង ........................................ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ.......................... ចុះថ្ងៃទី................ ខែ................ ឆ្នាំ...............

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ........................ ចុះថ្ងៃទី.............. ខែ...................... ឆ្នាំ.................... និងសំណុំលិខិតភ្ជាប់មកជាមួយ ព្រមទាំងភស្តុតាងនានា។

បានឃើញដីកាសម្រេចសុំចោទប្រកាន់បទល្មើសថ្មីបន្ថែមលេខ.................. ចុះថ្ងៃទី............ ខែ................ ឆ្នាំ........................ របស់ចៅក្រមស៊ើបអង្កេត ។

យល់ឃើញថា :.................................................................................................................

...................................................................................................................................

...................................................................................................................................

...................................................................................................................................

...................................................................................................................................

...................................................................................................................................

សម្រេចផ្តើមចោទប្រកាន់ឈ្មោះ ..................................ភេទ............ អាយុ .........ឆ្នាំ ជាតិ.................. របររកស៊ី...................................... ទីលំនៅបច្ចុប្បន្ននៅភូមិ..........................ឃុំ-សង្កាត់.................................. ស្រុក-ខណ្ឌ............................................ខេត្ត-ក្រុង.........................................ទោសពីមុន ......................... និងតួកន ។ ឪពុកឈ្មោះ.......................................... "រ-ស" ម្តាយឈ្មោះ ....................................... "រ-ស" ប្តីឬប្រពន្ធឈ្មោះ..................................................."រ-ស"មានកូន ឬនៅលីវ .........................................នាក់ បន្ថែមពីបទ.................................................................. ប្រព្រឹត្តនៅភូមិ......................................... ឃុំ-សង្កាត់........................... ស្រុក-ខណ្ឌ.............................. ខេត្ត-ក្រុង.........................................កាលពី ថ្ងៃទី ......... ខែ ................ ឆ្នាំ .................... តាមមាត្រា............................................................ នៃច្បាប់ ...................................................................................................................................។

បញ្ជូនសំណុំរឿង វត្ថុតាង និងជនល្មើស "មានខ្លួន, គ្មានខ្លួន" ទៅចៅក្រមស៊ើបអង្កេត នៃតុលាការខេត្ត-ក្រុង ..... ......................................... ដើម្បីចាត់ការតាមច្បាប់ និងស្នើសុំ .......................................................................។

ធ្វើនៅ.............................. ថ្ងៃទី............ ខែ............ ឆ្នាំ............

***ព្រះរាជអាជ្ញា***

---

*កំណត់សំគាល់:* ក្នុងករណីព្រះរាជអាជ្ញាមិនសុំឱ្យចៅក្រមស៊ើបអង្កេតចាប់ឃុំខ្លួនជនល្មើសទេ ត្រូវឆូតលុបពាក្យ "និងសុំចាប់ឃុំខ្លួនជនល្មើសជាបណ្តោះអាសន្ន" ខាងលើចោល ។